វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សា
ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម
និងជនបទ

វិទ្យាស្ថាន
ស្រាវជ្រាវគោលនយោបាយ
ស្បៀងអន្តរជាតិ

# ការពិនិត្យមើលឡើងវិញនូវ គោលនយោបាយកសិកម្ម និង ការស្រាវជ្រាវគោលនយោបាយ

## ឯកសារពិភាក្សាគោលនយោបាយ



បណ្ឌិត ថេង វុឌ្ឍី អ្នកសម្របសម្រួលកម្មវិធី PARD
បណ្ឌិត កុយ រ៉ា អ្នកសម្របសម្រួលកម្មវិធី NRE
នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

ខែមីនា ឆ្នាំ២០១១

របាយការណ៍ពិសេស លេខ ៦

ឧបត្ថម្ភដោយ USAID FROM THE AMERICAN PEOPLE

# ការពិនិត្យមើលឡើងវិញ នូវគោលនយោបាយកសិកម្ម និងការស្រាវជ្រាវគោលនយោបាយ

## ឯកសារពិភាក្សាគោលនយោបាយ

**រៀបរៀងសម្រាប់**
**កិច្ចប្រជុំតុមូលស្តីពីសន្តិសុខស្បៀង**
**និងគោលនយោបាយកសិកម្មកម្ពុជា**
**ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ នៅសណ្ឋាគារភ្នំពេញ**
CDRI **ក្នុងកិច្ចសហការជាដៃគូជាមួយ** CARD **និង** IFPRI
**ឧបត្ថម្ភដោយ** USAID

**បណ្ឌិត ថេង វុឌ្ឍី អ្នកសម្របសម្រួលកម្មវិធី** PARD
**បណ្ឌិត កុយ រ៉ា អ្នកសម្របសម្រួលកម្មវិធី** NRE[1]
**នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

**ភ្នំពេញ-កម្ពុជា**

1 អ្នកស្រី ខៀវ ភិរម្យ និងលោក ឈឹម ឈន់ បានជួយរកឯកសារ និងទិន្នន័យសម្រាប់ឯកសារនេះ ។

## បេសកកម្ម វបសអ

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹងនិងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

© **រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

## ការពិនិត្យមើលឡើងវិញនូវគោលនយោបាយកសិកម្ម និងការស្រាវជ្រាវគោលនយោបាយ

ឯកសារពិភាក្សាគោលនយោបាយ

ខែមីនា ឆ្នាំ២០១១

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@wicam.com.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ទា សាវរា

# មាតិកា


បញ្ជីអក្សរកាត់ ....... 7

ខ្លឹមសារសង្ខេប ....... 9

១. សេចក្តីផ្តើម ....... 15

២. ស្ថានភាពកសិកម្មនៅកម្ពុជា ....... 15

៣. គោលនយោបាយសម្រាប់លើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា ....... 22

  ៣.១ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច (SEDP) ....... 22

  ៣.២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥ ....... 24

  ៣.៣ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ២០០៣-២០១៥ ....... 25

  ៣.៤ យុទ្ធសាស្ត្រចតុកោណ ....... 25

  ៣.៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ....... 26

  ៣.៦ ឯកសារគោលនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ....... 27

  ៣.៧ គោលនយោបាយជាតិស្តីពីធនធានទឹក ....... 28

  ៣.៨ គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ ....... 29

    *៣.៨.១ យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក ....... 29*

    *៣.៨.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០ ....... 29*

    *៣.៨.៣ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ស្តីពីធនធានទឹក និងឧតុនិយម ឆ្នាំ២០០៩-២០១៣ ....... 30*

    *៣.៨.៤ គោលនយោបាយកសិកម្មពាក់ព័ន្ធដទៃទៀត និងគោលនយោបាយសន្តិសុខស្បៀង ....... 30*

៤. ការស្រាវជ្រាវគោលនយោបាយមានស្រាប់ស្តីពីកសិកម្មកម្ពុជា ....... 33

  ៤.១ ការស្រាវជ្រាវស្តីពីការគ្រប់គ្រងការស្រោចស្រព និងការគ្រប់គ្រងទឹកក្នុងវិស័យកសិកម្ម ....... 34

  ៤.២ ការស្រាវជ្រាវពីពាណិជ្ជកម្មកសិកម្ម ....... 36

  ៤.៣ ការអភិវឌ្ឍកសិកម្ម ភាពក្រីក្រ និងសន្តិសុខស្បៀង ....... 37

  ៤.៤ ការស្រាវជ្រាវអនុវិស័យស្រូវ ....... 41

  ៤.៥ កសិកម្មនិងការប្រែប្រួលធាតុអាកាស ....... 42

  ៤.៦ កសិកម្ម និងសន្តិសុខស្បៀង ក្នុងវិបត្តិហិរញ្ញវត្ថុពិភពលោក ....... 43

៥. កង្វះការយល់ដឹងពីគោលនយោបាយ និងការស្រាវជ្រាវគោលនយោបាយ ក្នុងវិស័យកសិកម្ម ....... 43

៦. សំណួរសម្រាប់សន្តិសុខស្បៀងនាពេលអនាគត ....... 46

៧. សេចក្តីសន្និដ្ឋាន ....... 49

# បញ្ជីក្រាហ្វិក និងតារាង


ក្រាហ្វិក ១៖ កំណើន ផសស ឆ្នាំ១៩៩៥-២០០៨ ........ 16
ក្រាហ្វិក ២៖ អត្រាភាគរយនៃ ផសស (%) ឆ្នាំ១៩៩៥-២០០៨ ........ 16
ក្រាហ្វិក ៣៖ កំណើនតាមវិស័យនៃ ផសស ឆ្នាំ១៩៩៨-២០០៩ ........ 17
ក្រាហ្វិក ៤៖ ការងារតាមវិស័យ ឆ្នាំ១៩៩៨-២០០៧ ........ 18
ក្រាហ្វិក ៥៖ ផលិតកម្ម និងផ្ទៃដីដាំស្រូវឆ្នាំ១៩៩៩-២០០៨ ........ 20
ក្រាហ្វិក ៦៖ ផលិតកម្មស្រូវ និងអតិរេកផលស្រូវ ២០០០-២០០៩ ........ 20
ក្រាហ្វិក ៧៖ ផលនេសាទ ........ 21
ក្រាហ្វិក ៨៖ ផលិតកម្មបសុសត្វ និងបសុបក្សី ........ 21

តារាង ១៖ ផសស តាមអនុវិស័យកសិកម្ម និងកំណើនពីឆ្នាំ១៩៩៩-២០០៨ ........ 18
តារាង ២៖ ទិន្នផលស្រូវរបស់កម្ពុជា និងការប្រៀបធៀបក្នុងតំបន់ (តោនក្នុងមួយហិកតា) ........ 19
តារាង ៣៖ ធាតុចូលកសិកម្ម ........ 21
តារាង ៤៖ ចំណាយចរន្តរបស់រដ្ឋាភិបាលចំពោះវិស័យមួយចំនួន ........ 28

# បញ្ជីអក្សរកាត់

| | |
|---|---|
| CBNRM-LI | វិទ្យាស្ថានរៀនសូត្រ (Learning Institute ) |
| CMDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (Cambodian Millennium Development Goals) |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក (Farmer Water User Community) |
| ICT | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (Information and Communication Technology) |
| MRC | គណៈកម្មាធិការទន្លេមេគង្គ (Mekong River Committee) |
| MSME | សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (Micro, Small and Medium Enterprise) |
| NARS | ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (National Agricultural Research Systems) |
| NPRD | កម្មវិធីជាតិដើម្បីស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| NSDP/ ផយអជ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( National Strategic Development Plan) |
| PIMD | កម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ការស្រោចស្រពដែលមានការចូលរួម (Participatory Irrigation Management and Development) |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម (Royal University of Agriculture) |
| SAW | យុទ្ធសាស្ត្រជាតិ សម្រាប់កសិកម្ម និងទឹក (Strategy for Agriculture and Water) |
| SEDP-I | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី ១ (Socio-Economic Development Plan 1996-2000) |
| SEDP-II | ផែនការអភិវឌ្ឍន៍សង្គមកិច្ច-សេដ្ឋកិច្ចលើកទី ២ (Socio-Economic Development Plan 2001-2005) |
| SFFSN | ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (Strategic Framework for Food Security and Nutrition) |
| SIDS | វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍កម្ពុជា (Cambodia Institute of Development Studies) |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (Supreme National Economic Council) |
| TWGAW | ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក (Technical Working Group of Agricultural and Water Strategy ) |

## ខ្លឹមសារសង្ខេប

### គោលនយោបាយជម្រុញការអភិវឌ្ឍវិស័យកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ច្បាស់ អំពីគោលនយោបាយកសិកម្មរបស់ខ្លួននៅក្នុងយុទ្ធសាស្ត្រចតុកោណ៖ "ដើម្បីបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ហើយតាមនេះបង្កលក្ខណៈឱ្យវិស័យកសិកម្មដើរតួជាកត្តាជម្រុញប្រកបដោយថាមភាពដើម្បីកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ធាតុសំខាន់ៗនៃគោលនយោបាយអភិវឌ្ឍន៍កសិកម្មផ្អែកលើគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG) ឆ្នាំ២០០៣ ផែនការអភិវឌ្ឍន៍សង្គមកិច្ច-សេដ្ឋកិច្ចលើកទីពីរ (SEDP-II) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ និងផ្តោតលើ ១) ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ២) កំណែទម្រង់ដីធ្លី និងការដោះមីន ៣) កំណែទម្រង់ជលផល និង ៤) កំណែទម្រង់ព្រៃឈើ ។

គោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ (NSDP) គឺដើម្បីកាត់បន្ថយភាពក្រីក្រ និងអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់វិស័យកសិកម្ម ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏បានចែងអំពីតម្រូវការចំបងក្នុងការរៀបចំយុទ្ធសាស្ត្រជាតិ សម្រាប់កសិកម្ម និងទឹក (SAW) នៅឆ្នាំ២០០៦ផងដែរ ។ ទោះយ៉ាងណា SAW (២០០៦-២០១០) ទើបបានបញ្ចប់នៅឆ្នាំ២០០៧ ដែលយឺតជាងផែនការអស់រយៈពេលមួយឆ្នាំ ។ SAW បានដាក់ចេញនូវកម្មវិធីចំនួនប្រាំ គឺការកសាងសមត្ថភាពស្ថាប័ន សន្តិសុខស្បៀង កសិកម្ម និងកសិពាណិជ្ជកម្ម ការគ្រប់គ្រងធនធានទឹក និង ការស្រាវជ្រាវនិងការអភិវឌ្ឍកសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០ ដោយគូសបញ្ជាក់អំពីគោលដៅអាទិភាពប្រាំពីរ ព្រមទាំងលើកឡើងពីឧបសគ្គនានា និងវិធានការត្រូវប្រកាន់យកដើម្បីសម្រេចបាននូវគោលដៅទាំងនេះដែលរួមមាន៖ ១) សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម ២) ការលើកកម្ពស់ និងការពង្រឹងការស្រាវជ្រាវកសិកម្ម និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ៣) លទ្ធភាពចូលទៅកាន់ទីផ្សារចំពោះផលិតផលកសិកម្ម ៤) ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ននិងច្បាប់ ៥) កំណែទម្រង់ដីធ្លី របបកម្មសិទ្ធិដីធ្លី និងលទ្ធភាពទទួលបានដីធ្លីចំពោះពលរដ្ឋក្រីក្រ ៦) កំណែទម្រង់ជលផល និង ៧) កំណែទម្រង់ព្រៃឈើ ។

កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់គោលនយោបាយមួយ ដើម្បីជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។ គោលនយោបាយនេះក៏បានបញ្ជាក់លំអិតបន្ថែមទៀតនូវវិធានការ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលដើម្បីជម្រុញការអភិវឌ្ឍកសិកម្ម ដោយសង្កត់ធ្ងន់លើល្បឿន និងទ្រង់ទ្រាយថ្មី ។ គោលបំណងគឺបន្តពង្រឹងមូលដ្ឋានគ្រឹះ ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច ពន្លឿនការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គោលនយោបាយបានកំណត់ឲ្យអនុវត្តយុទ្ធសាស្ត្រដែលមានបីផ្នែក៖ ការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងការធ្វើពាណិជ្ជកម្មកសិកម្ម ។

បទបញ្ញត្តិដទៃទៀតសម្រាប់អភិវឌ្ឍកសិកម្ម សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ រួមមាន៖

- គោលនយោបាយជាតិស្តីពីធនធានទឹក
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម ឆ្នាំ២០០៩-២០១៣
- សារាចរលេខ ៣ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅព្រះរាជាណាចក្រកម្ពុជា
- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគោលនយោបាយជាតិចំពោះវិស័យជលផល
- គោលនយោបាយជាតិស្តីពីជលផល និងច្បាប់ជលផល (ឆ្នាំ២០០៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

- កម្មវិធីជាតិចំពោះសន្តិសុខស្បៀងគ្រួសារ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៧-២០១១
- ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ឆ្នាំ២០០៨-២០១២
- កម្មវិធីសកម្មភាពជាតិ ស្តីពីការបន្សាំចំពោះបំរែបំរួលអាកាសធាតុ (NAPA)
- ច្បាប់ស្តីពីវិនិយោគ ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីវិនិយោគ (ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៣)
- អនុក្រឹត្យស្តីពីនិក្ខេប និងអនុបយោគនៃសិទ្ធិចំពោះសម្បទានដីសេដ្ឋកិច្ច (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧)
- ព្រះរាជក្រឹត្យ នស/រកត/០៦០៩/០០៩ (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩) ដើម្បីផ្តល់កត្តាលើកទឹកចិត្ត ចំពោះការអភិវឌ្ឍកសិកម្មនៅកម្ពុជា ។

## ការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ និងកង្វះការយល់ដឹង

នៅកម្ពុជា មានវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយមួយចំនួន រួមមាន៖ SNEC, RUA, CDRI, CBNRM-LI, WorldFish Centre, NGO forum, EIC, CIDS ។ លទ្ធភាពក្នុងការទទួលបានឯកសារស្រាវជ្រាវដែលមានក្នុងក្របខ័ណ្ឌសាធារណៈ នៅមានកំហិតជាខ្លាំង ពិសេសចំពោះវិទ្យាស្ថានស្រាវជ្រាវសាធារណៈ និង "ធនាគារខួរក្បាល" ។ ការពិនិត្យមើលសាឡើងវិញនេះ ផ្តោតសំខាន់លើអនុវិស័យស្រោចស្រព អនុវិស័យដំណាំកសិកម្ម អនុវិស័យជលផល និងអនុវិស័យចិញ្ចឹមសត្វ ។ ប៉ុន្តែផ្នែកពាក់ព័ន្ធដទៃទៀត ក៏មានលើកយកមកពិភាក្សាដែរ ។

ការស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធនឹងទឹក បានគ្របដណ្តប់លើបញ្ហាអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ផលចំណូលសេដ្ឋកិច្ច និងការសិក្សាសាកល្បងមួយចំនួនអំពីកម្មវិធីស្រោចស្រព ។ ការសិក្សាទាំងនេះ បានរកឃើញថា ថ្នាក់ដឹកនាំមានសមត្ថភាពទាប និងស្ថាប័នអន់ខ្សោយ គឺជាឧបសគ្គចំបងនៅក្នុងគម្រោងស្រោចស្រពភាគច្រើន ។ គម្រោងស្រោចស្រពជាច្រើន គេរចនារៀបចំមិនយបានល្អទេ ដែលធ្វើឱ្យខ្ជះខ្ជាយទឹក ។ ប្រការនេះនាំឱ្យមានអតុល្យភាពក្នុងការបែងចែកទឹក និងទំនាស់ក្នុងចំណោមអ្នកប្រើទឹកនានា ។ ទំនាស់មួយចំនួនត្រូវបានដោះស្រាយនៅក្នុងសហគមន៍ ប៉ុន្តែទំនាស់ដទៃទៀត ត្រូវការអន្តរាគមន៍ពីអាជ្ញាធរខេត្ត និងអាជ្ញាធរជាតិ ។ ការចូលរួមពីសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ក្នុងការទូទាត់ថ្លៃសេវា ថែទាំ និងកម្មសិទ្ធិ និងការបែងចែកទឹក គេចាត់ទុកថា មានសារៈសំខាន់ជាខ្លាំងចំពោះការគ្រប់គ្រងការស្រោចស្រពទឹកប្រកបដោយជោគជ័យ ។ នៅកម្ពុជាពុំទាន់មានការស្រាវជ្រាវទឹកក្រោមដីទេ ។ ទឹកក្រោមដីអាចមានលទ្ធភាពក្លាយជាប្រភពស្រោចស្រពបានពេញៗមួយឆ្នាំ ហើយជួយកាត់បន្ថយផលប៉ះពាល់នៃភាពរាំងស្ងួត និងការប្រែប្រួលធាតុអាកាស មកលើកសិកម្ម និងសន្តិសុខស្បៀង ។

ការស្រាវជ្រាវមួយចំនួន ស្តីពីពាណិជ្ជកម្មកសិកម្មរវាងប្រទេសកម្ពុជា និងអាស៊ាន និងរវាងអាស៊ាន និងចិន ត្រូវបានធ្វើឡើង ។ ទំនិញកសិកម្មជាច្រើន ដូចជា បសុសត្វ (ជ្រូក គោ និងក្របី) និងដំណាំ (កៅស៊ូ ដំឡូងមី ពោត សណ្តែកសៀង និងស្រូវ) ត្រូវបានជួញដូរ ។ ពាណិជ្ជកម្មឆ្លងដែននេះ អាចជួយធ្វើឱ្យថ្លៃទីផ្សារមានស្ថិរភាព និងពង្រីកទីផ្សារផលិតផលកសិកម្មសម្រាប់ប្រជាជនកម្ពុជា ។ ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាទទួលបានផលប្រយោជន៍តិចតួចណាស់ ហើយមានកម្លាំងប្រកួតប្រជែងតិចជាងបណ្តាប្រទេសអាស៊ានដទៃទៀត ។ ទំនិញស្ទើរតែទាំងអស់ ត្រូវបាននាំចេញជាផលិតផលមិនទាន់កែច្នៃតាមរយៈការធ្វើពាណិជ្ជកម្មក្រៅផ្លូវការ ។ ប្រទេសថៃ និងប្រទេសវៀតណាម មានឧត្តមភាពជាងប្រទេសកម្ពុជា ដោយសារប្រទេសទាំងនោះធ្វើការកែច្នៃទំនិញជាច្រើនដែលនាំចូលមកពីប្រទេសកម្ពុជា ហើយលក់បន្តទៅកាន់ទីផ្សារពិភពលោក ។

មានការសិក្សាតិចតួចណាស់អំពីសន្តិសុខស្បៀង និងការកសាងផែនទីសន្តិសុខស្បៀងនៅប្រទេសកម្ពុជា ។ ការសិក្សាទាំងនេះបង្ហាញថា ស្រូវនៅកម្ពុជា គឺជាប្រភពអាហារចំបងដែលផ្តល់ថាមពលស្មើនឹង ២/៣ នៃបរិមាណអាហារបរិភោគគិតជាកាឡូរីសរុប ខណៈដែលការបរិភោគសាច់ត្រី និងសាច់សត្វមានចំនួនតិចតួច ដោយទាំងពីរមុខនេះផ្តល់បានត្រឹមតែ ៦% នៃបរិមាណថាមពលគិតជាកាឡូរីសរុបប៉ុណ្ណោះ ។ ការកសាងបង្កើតផែនទីសន្តិសុខស្បៀងបាន

បង្ហាញថាខេត្តចំនួន ៩ មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ ហើយខេត្តចំនួន ៥ ត្រូវបានសង្កេតឃើញថាមានអត្រាមរណភាពខ្ពស់ ទម្ងន់មិនសមាមាត្រនឹងអាយុ កំពស់មិនសមាមាត្រនឹងអាយុ និងការស្រកទម្ងន់ធ្ងន់ធ្ងរ ។ ទោះជាយ៉ាងណាក្តី ការសិក្សាទាំងនេះបានបញ្ចប់ក្នុងឆ្នាំ២០០៧ ហើយកន្លងមក នៅពុំទាន់មានរបកគំហើញការស្រាវជ្រាវថ្មីៗនៅឡើយ ។ ប្រការនេះធ្វើឱ្យគេជួបការលំបាកក្នុងការកំណត់ គោលដៅកម្មវិធីសុវត្ថិភាពសង្គមទាំងមូលក្នុងការកាត់បន្ថយភាពងាយរងគ្រោះ ។

គេឃើញមានការស្រាវជ្រាវសម្បូរបែបស្តីពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងអាហារូបត្ថម្ភ និងភាពក្រីក្រក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់ការវិភាគ cross-section[1] និង panel data (កម្រងទិន្នន័យ)[2] និងវិធីសាស្រ្តបែបគុណវិស័យ ។ ការសិក្សាទាំងនោះបង្ហាញថា ការកាត់បន្ថយភាពក្រីក្រ ហាក់ដូចជាគ្មានទំនាក់ទំនងជាមួយនឹងកំណើនសេដ្ឋកិច្ចឡើយ ហើយកំណើនសេដ្ឋកិច្ចក៏ហាក់ដូចមិនបានជួយដល់គ្រប់គ្នាដែរ ។ ភាពក្រីក្រ និងអសន្តិសុខស្បៀងនៅតែមានកម្រិតខ្ពស់នៅតំបន់ជនបទ ។ បញ្ហាកម្មសិទ្ធិដីធ្លី នៅតែជាកត្តាកំណត់សំខាន់ ចំពោះភាពក្រីក្រ និងអសន្តិសុខស្បៀងសម្រាប់គ្រួសារកម្ពុជានៅជនបទ ។ គ្រួសារធំៗដែលមានសមាជិកពឹងផ្អែកច្រើននាក់ ការអប់រំទាប និងសុខភាពមិនល្អ គឺជាកត្តាផ្ទៃក្នុងចំបងនៃភាពក្រីក្រក្នុងសហគមន៍ជនបទ ។ លទ្ធភាពទទួលបានសេវាសាធារណៈមិនល្អ ដូចជា ការអប់រំ សុខាភិបាល និងការបណ្តុះបណ្តាលវិជ្ជាជីវៈ កង្វះលទ្ធភាពទទួលបានឥណទាន និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ (ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព) គឺជាអថេរផ្ទៃក្រៅចំពោះភាពក្រីក្រ ។ វិស័យកសិកម្ម បានក្លាយជាកត្តាដ៏សំខាន់ក្នុងការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅតំបន់ជនបទ ខណៈពេលដែលធនធានទ្រព្យរួម និងឱកាសធ្វើការងារដើម្បីទទួលប្រាក់ឈ្នួល គឺជាប្រព័ន្ធសុវត្ថិភាពដ៏សំខាន់សម្រាប់ជនក្រីក្រ ។ ចំនួនគ្រួសារគ្មានដីធ្លី កំពុងកើនឡើងគួរឱ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារការកសាងគ្រួសារថ្មី និងទីផ្សារដីធ្លី ។ ការប្រឈម និងអន្តរកម្ម រវាងភាពគ្មានដី និងអសន្តិសុខស្បៀង ជាមួយនឹងការការពារសង្គម និងភាពងាយរងគ្រោះគេនៅតែមិនទាន់បានដឹងច្បាស់នៅឡើយ ។

ការស្រាវជ្រាវពីគោលនយោបាយជាច្រើន លើកឡើងពីបញ្ហានេសាទទឹកសាប ក្នុងការឆ្លើយតបចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីកំណែទម្រង់វិស័យជលផល ។ លទ្ធផលសម្រេចបាន និងនិរន្តរភាពនៃការគ្រប់គ្រងរួមគ្នាលើវិស័យជលផល ជួបឧបសគ្គដោយសារកង្វះការកំណត់ច្បាស់លាស់ស្តីពីកម្មសិទ្ធិ និងដែនកំណត់ធនធាន និងអវត្តមាននៃច្បាប់ ។ ប្រការនេះធ្វើឱ្យមានទំនាស់រវាងសហគមន៍នេសាទនានា ។ ទំនាស់ក៏អាចកើតមានផងដែរ រវាងការនេសាទ និងការធ្វើកសិកម្ម ដោយសារការដណ្តើមប្រើប្រាស់ធនធានទឹកក្នុងគោលដៅផ្សេងគ្នា ។ ទំនាស់របស់សហគមន៍នេសាទតាមតំបន់ជាច្រើនអាចដោះស្រាយ ដោយមានការគាំទ្រពីស្ថាប័នថ្នាក់ខ្ពស់ ។ ជនក្រីក្រនៅពុំទាន់ទទួលបានអត្ថប្រយោជន៍ពីការចូលទៅក្នុងដែននេសាទនៅឡើយ ។ ចំណូលសុទ្ធនៃការនេសាទលក្ខណៈគ្រួសារខ្នាតតូចជាមធ្យមគឺ ១២ដុល្លារអាមេរិក នៅរដូវបើកនេសាទ និង ៤,៦ដុល្លារអាមេរិកនៅរដូវបិទនេសាទ ។ ប៉ុន្តែប្រសិនបើកំលាំងពលកម្មគ្រួសារ ត្រូវដកចេញពីចំណូលសុទ្ធ នោះប្រាក់ចំណេញសុទ្ធទទួលបានគឺត្រឹមតែ ៤,៥ដុល្លារអាមេរិកប៉ុណ្ណោះក្នុងរដូវបើកនេសាទ និង ១,៦ដុល្លារអាមេរិកប៉ុណ្ណោះនៅរដូវបិទនេសាទ ។ បំរែបំរួលជលសាស្រ្ត ការគោករាក់ ការអភិវឌ្ឍន៍កសិកម្មនៅជុំវិញបឹងទន្លេសាប ហើយនិងសមត្ថភាពគ្រប់គ្រងសហគមន៍នេសាទនាបច្ចុប្បន្ន វាគំរាមកំហែងដល់និរន្តរភាព និងការប្រើប្រាស់បរិស្ថាននៃបឹងទន្លេសាបឲ្យសមស្រប ម្យ៉ាងទៀត កម្ពស់ទឹកទន្លេមេគង្គមានកម្រិតទាបជាង ៥ម៉ែត្រ ហើយកម្រិតកម្ពស់ទឹកទន្លេសាបមានកម្រិតទាបជាង ៣ម៉ែត្រ ធៀបនឹងកម្រិតកម្ពស់ទឹកមួយឆ្នាំមុន ដោយការសាងសង់ទំនប់នៅខ្សែទឹកខាងលើ ។ កម្រិតកម្ពស់ទឹកទាបនឹងធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានមកលើអេកូឡូស៊ី និងជម្រកត្រីទឹកសាបនៅកម្ពុជា ។ កម្រិតកម្ពស់ទឹកទាបមានឥទ្ធិពលយ៉ាងណាលើការចំនួនត្រីទឹកសាប ការពងកូនរបស់ត្រី និងសន្តិសុខស្បៀងនៅកម្ពុជា គេមិនទាន់ដឹងច្បាស់ទេ ។ ការស្រាវជ្រាវពេញលេញស្តីពីនេសាទសមុទ្រ ក៏ពុំទាន់មានដែរ ។

---

1 វិធីសាស្រ្តស្រាវជ្រាវមួយបែបដែលសង្កេតមើលក្រុម ឬអនុក្រុមដែលមានលក្ខណៈតំណាង ក្រោយពីបានកសាងសំណាកបែបស្ថិតិវិទ្យា ក្នុងពេលណាមួយជាកំណត់ ដើម្បីកំណត់ទំនាក់ទំនងរវាងអថេរពាក់ព័ន្ធនឹងកម្មវត្ថុនៃការស្រាវជ្រាវ ។

2 ការវិភាគបាតុភូតចម្រុះដែលបានសង្កេតឃើញច្រើនគ្រា ចំពោះកម្មវត្ថុនៃការស្រាវជ្រាវ ។

គោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីអនុវិស័យបសុសត្វគ្មានទិសដៅច្បាស់លាស់ ។ វិស័យនេះក៏គ្មានផែនការយុទ្ធសាស្ត្រដើម្បីណែនាំការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែរ ។ អនុវិស័យនេះ ដើរតួយ៉ាងសំខាន់លើសន្តិសុខស្បៀង និងកំលាំងអូសទាញសម្រាប់ផលិតកម្មកសិកម្ម ។ គោ និងក្របី ត្រូវបានប្រើប្រាស់ជាកំលាំងអូសទាញ និងសម្រាប់យកសាច់បរិភោគ ។ ជ្រូក និងមាន់ ត្រូវបានគេចិញ្ចឹមដើម្បីសន្សំប្រាក់ និងបរិភោគ ហើយមានការជួញដូរយ៉ាងសកម្មនៅក្នុងតំបន់ និងរវាងសហគមន៍ជនបទនានា ។ គោ និងក្របីភាគច្រើនត្រូវបានជួញដូរក្រៅផ្លូវការជាមួយប្រទេសជិតខាង ។ កន្លងទៅថ្មីៗនេះ គ្មានការស្រាវជ្រាវគោលនយោបាយលើវិស័យបសុសត្វទេ ដូច្នេះមានតម្រូវការបន្ទាន់នូវការស្រាវជ្រាវដើម្បីកែលំអការអភិវឌ្ឍអនុវិស័យនេះ និងការសិក្សាសេដ្ឋកិច្ចសង្គមកិច្ចនៃបសុសត្វដែលគប្បីចាត់ទុកជាអាទិភាព ។

ការស្រាវជ្រាវអំពីគោលនយោបាយ បានប្រព្រឹត្តលើការកែលំអអនុវិស័យស្រូវ និងជម្រុញការនាំចេញអង្ករដែលមានសក្តានុពលខ្ពស់ក្នុងកំណើនសេដ្ឋកិច្ច និងសន្តិសុខស្បៀងសម្រាប់កម្ពុជា ។ ស្រូវមានសក្តានុពលក្នុងការនាំចេញ ហើយការជម្រុញការកែច្នៃផលកសិកម្ម និងកសិពាណិជ្ជកម្ម នឹងពង្រឹងអនុវិស័យនេះសម្រាប់ការនាំចេញ ។ សមត្ថភាពកិនស្រូវបច្ចុប្បន្ន របស់កម្ពុជាមានកម្រិតទាប (តិចជាង ១០តោន/ម៉ោង) ហើយអាចកិនបានត្រឹមតែ ១/៣ នៃបរិមាណស្រូវដែលបានផលិតតែប៉ុណ្ណោះ ។ ហេតុនេះ ប្រទេសកម្ពុជាត្រូវបង្កើនសមត្ថភាពកិនស្រូវ ៣ដង ដើម្បីឆ្លើយតបនឹងតម្រូវការកិនស្រូវក្នុងស្រុក ។ ស្រូវក៏មានសក្តានុពលធំធេងដើម្បីបង្កើនផលិតកម្ម និងផលិតភាពដែរ ប្រសិនបើគេអាចកែលំអបច្ចេកទេស ជាំដុះ តាមរយៈការវិនិយោគលើធាតុចូល-ការកែលំអគ្រាប់ពូជជី និងការស្រោចស្រព ។ ទោះជាយ៉ាងណាក្តីកំណើន ក្នុងពេលអនាគតនៃផលិតភាពស្រូវ គ្មានភាពប្រាកដប្រជាឡើយដោយសារមានឧបសគ្គជាច្រើន ដូចជាធាតុចូលតិច ជាអាទិ៍ កង្វះឥណទាន កង្វះការស្រោចស្រព និងកង្វះពូជមានគុណភាពល្អ ភាពអន់ថយនៃសេវាផ្សព្វផ្សាយកសិកម្ម និងផ្លូវថ្នល់ជនបទ ។

ផលប៉ះពាល់នៃបំរែបំរួលអាកាសធាតុលើវិស័យកសិកម្ម គឺជាការស្រាវជ្រាវថ្មីមួយនៅកម្ពុជា ហេតុនេះទើបមានការសិក្សាតែតិចតួចលើបញ្ហានេះ ។ បំរែបំរួលអាកាសធាតុ បានបង្ហាញពីផលប៉ះពាល់អវិជ្ជមានមកលើជីវភាពរស់នៅ ។ ប្រាក់ចំណូលរបស់គ្រួសារបានធ្លាក់ចុះជាបណ្តើរៗក្នុងអំឡុងឆ្នាំ១៩៩៩ ដល់ ២០០៨ ។ កត្តាពាក់ព័ន្ធរួមមាន ការរានព្រៃធ្វើកសិកម្ម ការខូចខាតផលដំណាំដោយសាររដូវប្រាំងមានរយៈពេលវែង ហើយភ្លៀងធ្លាក់មិនទៀងទាត់ និងការហាមឃាត់មិនឱ្យចូលព្រៃ ។ ប្រជាជនជនបទ និងទីក្រុង មានចំណេះដឹងមួយចំនួនអំពី ផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាសមកលើសុខភាពមនុស្ស និងកសិកម្មៈ មនុស្សងាយនឹងកើតជម្ងឺ ធាតុអាកាសក្តៅទៅៗ ហើយទឹកជំនន់ និងព្យុះភ្លៀងកើតមានញឹកញាប់ជាងមុនធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ផលិតកម្មកសិកម្ម ។ CARDI កំពុងជ្រើសរើសពូជស្រូវដែលមានរយៈពេលខ្លី (អាចផ្តល់ផលក្នុងរយៈពេលខ្លី) ដើម្បីកាត់បន្ថយតម្រូវការទឹក ។

## សំណួរស្រាវជ្រាវនាពេលអនាគត

ប្រធានបទស្រាវជ្រាវសំខាន់ៗមួយចំនួនត្រូវបានកំណត់ដើម្បីរៀបចំសំណួរ និងចំណាប់អារម្មណ៍អំពី ការស្រាវជ្រាវនាពេលអនាគត ទោះបីជាក្របខ័ណ្ឌនេះមិនអាចមានលទ្ធភាពឆ្លើយតប រាល់ភាពខ្វះចន្លោះផ្នែកចំណេះដឹងក្តីៈ

### ការគ្រប់គ្រងធនធានទឹក

១. តើទឹកក្រោមដីមានសក្តានុពលអ្វីសម្រាប់ការស្រោចស្រព ទាំងក្នុងការរក្សាតុល្យភាពទឹកនៅកម្ពុជា និងជាកន្លែងស្តុកទឹកធម្មជាតិដ៏ច្រើនដែលអាចក្លាយជាប្រភពផ្គត់ផ្គង់ទឹកពេញៗមួយឆ្នាំ? តើអ្វីជាចំណុចខ្លាំង និងចំណុចខ្សោយនៃការប្រើប្រាស់ទឹកក្រោមដីចំពោះអភិវឌ្ឍន៍កសិកម្ម និងបរិស្ថាន? តើទឹកក្រោមដីផ្តល់តុល្យភាពសេដ្ឋកិច្ចអ្វីរវាងផលប្រយោជន៍ និងផលប៉ះពាល់លើលក្ខណៈដី និងជីជាតិដី ក្នុងរយៈពេលវែង?

២. តើធ្វើដូចម្តេចដើម្បីកែលំអប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រពដែលមានស្រាប់ ក្នុងការប្រើប្រាស់ទឹកលើផ្ទៃដី?

៣. តើធ្វើដូចម្តេច ដើម្បីពង្រឹងការចូលរួមរបស់អ្នកប្រើប្រាស់ទឹកលើផ្ទៃដី ឲ្យមានភាពជាម្ចាស់ និងការថែទាំប្រព័ន្ធស្រោចស្រពប្រកបដោយប្រសិទ្ធភាព? តើអ្វីជាផលកំរៃសេដ្ឋកិច្ចនៃការវិនិយោគលើការថែទាំប្រព័ន្ធស្រោចស្រព?

៤. តើមានទំនាស់អ្វីជុំវិញភាពខ្សត់ទឹក និងការបែងចែកធនធានទឹក ហើយតើគេអាចដោះស្រាយបញ្ហាទាំងនេះតាមបែបណាប្រកបដោយប្រសិទ្ធភាព? តើអាចបង្កើនចំណែក និងប្រសិទ្ធភាពវិនិយោគសាធារណៈបានប៉ុណ្ណា សម្រាប់ការស្តារ ការកែលំអ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព?

## ការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀង

១. តើការបែងចែកធនធានដើម្បីលើកកម្ពស់ការអភិវឌ្ឍកសិកម្ម និងកំណើន គេអាចបង្កើនយ៉ាងដូចម្តេចបាន? តើការស្រាវជ្រាវកសិកម្មដើម្បីជម្រុញកំណើនកសិកម្ម ត្រូវពង្រីកថែមយ៉ាងដូចម្តេច? តើទីភ្នាក់ងារស្រាវជ្រាវ និងអ្នកប្រើប្រាស់បច្ចេកវិទ្យាត្រូវមានទំនាក់ទំនងយ៉ាងដូចម្តេចដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព? តើវិធីអ្វីដែលល្អបំផុត ក្នុងការជម្រុញ និងលើកទឹកចិត្តកសិករឱ្យអនុវត្តវិធីផលិតថ្មីៗ ដើម្បីបង្កើនផលិតភាព និងសន្តិសុខស្បៀង?

២. តើការប្រើប្រាស់បច្ចេកវិទ្យាសមស្រប និងធាតុចូលសមស្របអ្វី ដែលជួយបង្កើនផលិតភាពចំពោះអ្នកមានដីតូច ដើម្បីផលិតស្បៀងអាហារបានគ្រប់គ្រាន់? តើមានឱកាសការងារអ្វីផ្សេងដើម្បីធ្វើពិពិធកម្មប្រាក់ចំណូលជនបទក្រៅពីប្រាក់ចំណូលកសិកម្មនិងជួយលើកកម្ពស់ជីវភាពរស់នៅ? តើគេអាចធ្វើពិពិធកម្មការងារកសិកម្មលើមូលដ្ឋានដំណាំស្រូវដោយមានសមត្ថភាពស្រោចស្រពតិចតួចយ៉ាងដូចម្តេច ដើម្បីលើកកម្ពស់ជីវភាពរស់នៅជនបទ និងកាត់បន្ថយភាពក្រីក្រ?

៣. តើធ្វើយ៉ាងណាអាចលើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងលក្ខណៈជា មធ្យោបាយនៃការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពទៅឲ្យសហគមន៍? តើកម្មវិធីបណ្តុះបណ្តាលអ្វីខ្លះដែលមានប្រសិទ្ធភាពក្នុងការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ ក្នុងមុខងារជួយផ្ទេរបច្ចេកវិទ្យានេះ? តើការចូលរួមរបស់វិស័យឯកជននៅក្នុងការផ្ទេរបច្ចេកវិទ្យាចំពោះផលិតករ អាចលើកកម្ពស់យ៉ាងដូចម្តេចបាន? តើការកសាងស្ថាប័ន និងការកសាងសមត្ថភាពរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ត្រូវពង្រឹងយ៉ាងដូចម្តេច ដើម្បីជួយកសិករបង្កើនផលិតភាពឱ្យកាន់តែមានប្រសិទ្ធភាព? តើអាចបែងចែកធនធានច្រើនថែមទៀតដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មយ៉ាងណា?

៤. តើគេអាចជម្រុញឱ្យមានការកសាងផែនការប្រើប្រាស់ដីធ្លី និងតំបន់ដំណាំកសិកម្ម ដើម្បីបង្កើនកំណើនកសិកម្មឱ្យបានល្អប្រសើរយ៉ាងដូចម្តេច? តើតំបន់ផលិតកម្មស្រូវអាចពង្រីក ដើម្បីបង្កើនកំណើនកសិកម្ម និងជម្រុញការនាំចេញយ៉ាងដូចម្តេច? តើត្រូវពង្រឹងច្បាប់យ៉ាងណា ដើម្បីបង្វែរដីទំនេរទៅជាដីប្រើប្រាស់ប្រកបដោយផលិតភាព?

៥. តើធ្វើដូចម្តេចដើម្បីលើកកម្ពស់សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច? តើហានិភ័យ និងបញ្ហាសន្តិសុខស្បៀងដែលគ្រួសារគ្មានដីធ្លីត្រូវប្រឈមមុខមានអ្វីខ្លះ? តើគោលនយោបាយអ្វីខ្លះប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យ និងអសន្តិសុខស្បៀងដល់ គ្រួសារដែលគ្មានដីធ្លី? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះ ចំពោះគ្រួសារនៅតាមខេត្តនានា ដែលប្រឈមមុខជាមួយអសន្តិសុខស្បៀងធ្ងន់ធ្ងរ?

៦. តើការផ្លាស់ប្តូរបច្ចេកវិទ្យាកសិកម្មអ្វីខ្លះដែលអាចកើតមានក្នុងប្រទេសកម្ពុជា ក្នុងឋានៈជាប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍ? តើវិស័យកសិកម្មមានមុខងារអ្វីខ្លះក្នុងកំណើនសេដ្ឋកិច្ច ឱកាសការងារសន្តិសុខស្បៀងនៅជនបទនិងទីក្រុង និងការកាត់បន្ថយភាពក្រីក្រ?

៧. តើហានិភ័យផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងដែលស្ថិត ក្រោមការគំរាមកំហែងនៃបំរែបំរួលអាកាសធាតុ អាចកាត់បន្ថយបានយ៉ាងដូចម្តេច? តើការប្រើប្រាស់ទឹកក្រោមដីប្រកបដោយប្រសិទ្ធភាព អាចរៀបចំ និងអាចជម្រុញយ៉ាងដូចម្តេច ដើម្បីកាត់បន្ថយការគំរាមកំហែងលើដីកសិកម្ម?

## ការអភិវឌ្ឍអនុវិស័យជលផល

១. តើអ្វីខ្លះជាផលប៉ះពាល់អវិជ្ជមាននៃកម្ពស់ទឹកទន្លេទាប មកលើអេកូឡូស៊ីជលផល ជម្រក និងផលិតភាពក្នុងវិស័យនេសាទទឹកសាបរបស់កម្ពុជា? តើការផ្លាស់ប្តូរកម្រិតកម្ពស់ទឹកទន្លេអាចគ្រប់គ្រង និរន្តរភាពអេកូឡូស៊ីត្រី ជម្រកត្រី និងផលិតភាពត្រីបានយ៉ាងដូចម្តេច?

២. តើធ្វើយ៉ាងណាអាចលើកកម្ពស់ និងពង្រឹងការអភិវឌ្ឍ និងការកសាងសមត្ថភាពសហគមន៍នេសាទ ដើម្បីឲ្យការគ្រប់គ្រងធនធានជលផលធម្មជាតិបានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព សម្រាប់ការបង្កើតប្រាក់ចំណូល សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ?

៣. តើមុខងាររបស់ស្ថាប័នពាក់ព័ន្ធ (ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមហាផ្ទៃ) អាចធ្វើសុខុដុមភាវូបនីយកម្ម/សម្របសម្រួលយ៉ាងដូចម្តេច ដើម្បីឱ្យការគ្រប់គ្រងវិស័យជលផល កាន់តែមានប្រសិទ្ធភាព?

៤. តើផលិតកម្មវារីវប្បកម្ម អាចកែលំអយ៉ាងដូចម្តេចបាន ដើម្បីកាត់បន្ថយការគំរាមកំហែងនេសាទទឹកសាបធម្មជាតិ? ដើម្បីបង្កើនការបរិភោគប្រូតេអ៊ីនសត្វ និងបង្កើនប្រាក់ចំណូល តើធ្វើដូចម្តេចដើម្បីលើកកម្ពស់វារីវប្បកម្ម នៅតំបន់ជនបទឆ្ងាយពីកន្លែងនេសាទទឹកសាប?

## ការអភិវឌ្ឍអនុវិស័យបសុសត្វ

១. តើធ្វើដូចម្តេច ដើម្បីលើកកម្ពស់អនុវិស័យបសុសត្វក្នុងការបង្កើនប្រាក់ចំណូលនៅជនបទ និងសន្តិសុខស្បៀង? តើអ្វីជាទំនាក់ទំនងចំបងរវាងផលិតកម្មបសុសត្វ និងផលិតកម្មកសិកម្ម ប្រាក់ចំណូលគ្រួសារនៅជនបទ និងសន្តិសុខស្បៀង? តើអ្វីជាផលចំនេញសេដ្ឋកិច្ចពីការចិញ្ចឹមបសុសត្វក្នុងទ្រង់ទ្រាយតូច? តើអ្វីខ្លះជាហានិភ័យ និងឧបសគ្គចំបងៗនៃការចិញ្ចឹមបសុសត្វ ដែលសហគមន៍នៅជនបទជួបប្រទះ? តើហានិភ័យនិងឧបសគ្គទាំងនេះ អាចកាត់បន្ថយយ៉ាងដូចម្តេច?

២. តើទីផ្សារបសុសត្វសំរាប់ផលិតករខ្នាតតូច អាចអភិវឌ្ឍយ៉ាងដូចម្តេច? តើកម្ពុជាអាចផ្គត់ផ្គង់ពាណិជ្ជកម្មផ្លូវការ (ដូចជា គោ ក្របី) ដើម្បីពង្រីកទីផ្សារបសុសត្វបានយ៉ាងដូចម្តេច? តើមានបទបញ្ញត្តិអ្វីខ្លះក្នុងការលើកម្ពស់ទីផ្សារបសុសត្វ?

៣. តើតំបន់មូលដ្ឋានអាចលើកកម្ពស់ផលិតកម្មជ្រូក ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក បានយ៉ាងដូចម្តេច? តើអ្វីខ្លះជារបៀបផលិតកម្មសមស្របអនុវត្ត ដើម្បីលើកកម្ពស់ការចិញ្ចឹមជ្រូក? តើអ្នកចិញ្ចឹមជ្រូកជួបប្រទះនឹងហានិភ័យ និងឧបសគ្គអ្វីខ្លះ? តើសព្វថ្ងៃមានបទបញ្ញត្តិ និងគោលនយោបាយអ្វីខ្លះ ដើម្បីកាត់បន្ថយការនាំចូលជ្រូក និងលើកកម្ពស់ផលិតករក្នុងស្រុក?

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសទើបបញ្ចប់ទំនាស់ ទើបចាកផុតពីសង្គ្រាម និងសង្គ្រាមស៊ីវិលអស់រយៈពេល ២ ទសវត្សរ៍ថ្មីៗ (១៩៧០ និង ១៩៨០) និងមានទំនាស់ផ្ទៃក្នុង និងអស្ថិរភាពនយោបាយអស់រយៈពេលមួយទសវត្សរ៍ (១៩៩០) ។ បញ្ហាអភិវឌ្ឍសំខាន់ៗជាច្រើនដែលកម្ពុជាកំពុងជួបប្រទះ ដូចជា សន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ អាចចាត់ទុកថាកើតពីទសវត្សរ៍ ៣ នេះ ។ ប្រទេសកម្ពុជាចាប់ផ្តើមប្រែក្លាយពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារបើកចំហពីឆ្នាំ១៩៨៩ មក (យោងតាមឯកសាររបស់លោក ហង្ស ២០០៩) ។ កម្មសិទ្ធិដីធ្លី ត្រូវបានទទួលស្គាល់ជាផ្លូវការក្នុងឆ្នាំ១៩៨៩ ។ ពាណិជ្ជកម្ម ឧស្សាហកម្ម និងការដឹកជញ្ជូន ត្រូវបានធ្វើសេរីភាវូបនីយកម្ម និងឯកជនភាវូបនីយកម្មនាពេលនោះផងដែរ ។ គោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី ត្រូវបានអនុម័តជាផ្លូវការក្នុងឆ្នាំ១៩៩៣ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជា បានកើតឡើងជាផ្លូវការ ។ ចាប់តាំងពីអាណត្តិទី ១ នៃរាជរដ្ឋាភិបាល យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិមួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តការអភិវឌ្ឍប្រទេសកម្ពុជា ។ អាទិភាពរួមនៃគោលនយោបាយអភិវឌ្ឍជាតិ គឺការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច លើកកម្ពស់ជនក្រីក្រកម្ពុជាឲ្យរួចផុតពីភាពក្រីក្រ និងធ្វើឱ្យប្រទេសកម្ពុជា ស្ថិតលើមាគ៌ាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។ វិស័យកសិកម្មមានសក្តានុពលដ៏ធំធេង ហើយកំណើនផលិតភាព អាចជម្រុញផលិតកម្មឲ្យមាននិរន្តរភាព - ភាពមានការងារធ្វើ និងប្រាក់ចំណូល - ដើម្បីកាត់បន្ថយភាពក្រីក្រ ។ គោលនយោបាយអភិវឌ្ឍននៃរាជរដ្ឋាភិបាល បានចាត់ទុកវិស័យកសិកម្មជាក្បាលម៉ាស៊ីនក្នុងកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។ ឯកសារខ្លីនេះ ពិនិត្យមើលសាឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដែលមានស្រាប់ ជាពិសេសគោលនយោបាយអភិវឌ្ឍន៍កសិកម្ម និងគោលនយោបាយសន្តិសុខស្បៀង ព្រមទាំងស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ស្តីពីកសិកម្មកម្ពុជា ។

គោលបំណងសំខាន់នៃឯកសារនេះ គឺដើម្បីពិនិត្យមើលសាឡើងវិញទាំង គោលនយោបាយជាតិ និងគោលនយោបាយរាជរដ្ឋាភិបាលតាមវិស័យ ដែលទាក់ទងដោយផ្ទាល់ដល់ការអភិវឌ្ឍវិស័យកសិកម្ម ។ ការពិនិត្យមើលសាឡើងវិញនេះ ក៏ផ្តោតលើការស្រាវជ្រាវពីគោលនយោបាយមានស្រាប់ផងដែរ (របាយការណ៍ ស្រាវជ្រាវ ទស្សនាវដ្តី និងអត្ថបទពាក់ព័ន្ធ អង្កេត និងទិន្នន័យស្រាវជ្រាវដែលមាន) ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយការអភិវឌ្ឍវិស័យកសិកម្ម សន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ មានអនុវិស័យកសិកម្ម ៣ ចំបង គឺដំណាំកសិកម្ម បសុសត្វ និងជលផល ដែលជាចំណុចផ្តោតនៃការពិនិត្យមើលសាឡើងវិញនេះ ថ្វីបើបញ្ហាពាក់ព័ន្ធផ្សេងទៀតក៏មានលើកយកមកបកស្រាយដែរ ។

ឯកសារនេះត្រូវបានរៀបចំដូចតទៅ៖ ផ្នែកទី ២ និយាយអំពីសាវតារខ្លីៗនៃវិស័យកសិកម្ម ។ ផ្នែកទី ៣ ពិនិត្យមើលឡើងវិញនូវអាទិភាពគោលនយោបាយរាជរដ្ឋាភិបាលនានា ចំពោះការអភិវឌ្ឍកសិកម្ម ។ ផ្នែកទី ៤ ពិនិត្យមើលការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ សម្រាប់កសិកម្មកម្ពុជា ។ ផ្នែកទី ៥ ពិពណ៌នាអំពីកង្វះចំណេះដឹងក្នុងវិស័យនេះ។ ផ្នែកទី ៦ ពិភាក្សាអំពីសំណួរស្រាវជ្រាវនាពេលអនាគត និង ផ្នែកទី ៧ ធ្វើសេចក្តីសន្និដ្ឋាន ។

## ២. ស្ថានភាពកសិកម្មនៅកម្ពុជា

ប្រទេសកម្ពុជាធ្លាប់សម្រេចបាននូវ កំណើនសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ក្នុងទសវត្សរ៍កន្លងទៅ មុនពេលដែលសេដ្ឋកិច្ចកម្ពុជាទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចសកលលោកក្នុងឆ្នាំ២០០៩ ។ កំណើន ផសស ជាមធ្យមគឺ ៩,៥%/ឆ្នាំ សម្រាប់រយៈពេលពីឆ្នាំ១៩៩៩-២០០៨ ។ កំណើនសេដ្ឋកិច្ចខ្ពស់បំផុតគឺ ១៣,៣% នៅឆ្នាំ២០០៥ (ក្រាហ្វិក ១) ។ កំណើននេះ អាចសម្រេចបានដោយសារសេដ្ឋកិច្ចបើកចំហ និងស្ថិរភាពបរិយាកាសម៉ាក្រូសេដ្ឋកិច្ច និងការបង្កើនការនាំចេញនិងវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងអត្រាអតិផរណាទាបប្រមាណជា ៥,០% លើកលែងពេលដែលអតិផរណាកើនឡើងប្រមាណជា ២២% ក្នុងឆ្នាំ២០០៨ ដោយសារ ការឡើងថ្លៃយ៉ាងឆាប់រហ័សនៃស្បៀង

អាហារនានា ។ ទោះជាយ៉ាងណាក្តី កំណើនមានមូលដ្ឋានតូចចង្អៀត ដោយមានវិស័យឈានមុខសំខាន់ៗតែ ៤ គឺ វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យសំណង់ និងវិស័យកសិកម្ម ។ មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច បានទទួលរងការប្រែប្រួលយ៉ាងខ្លាំង ក្នុងនេះ វិស័យកសិកម្មមានចំណាត់ថ្នាក់បន្ទាប់ពីវិស័យសេវាកម្ម និងវិស័យឧស្សាហកម្មក្នុងឆ្នាំ២០០៦ (ក្រាហ្វិក ២ ធនាគារពិភពលោក ឆ្នាំ២០០៩)[3] ។

ក្រាហ្វិក ១៖ កំណើន ផសស ឆ្នាំ១៩៩៥-២០០៨ (ថ្លៃថេរឆ្នាំ២០០០)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងគណនីជាតិ (ឆ្នាំ២០០៨) ធនាគារពិភពលោក (២០១០)[4]

ក្រាហ្វិក ២៖ អត្រាភាគរយនៃ ផសស (%) ឆ្នាំ១៩៩៥-២០០៨ (ថ្លៃថេរឆ្នាំ២០០០)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងគណនីជាតិ (ឆ្នាំ២០០៨)

3 World Bank (2009), Sustaining Rapid Growth in a Challenging Environment.

4 World Bank (2010), Emerging Stronger from the Crisis, pp. 39-41.

ចំណែកនៃ ផសស ក្នុងវិស័យកសិកម្ម បានកំពុងធ្លាក់ចុះជាបន្តបន្ទាប់ ប៉ុន្តែវិស័យនេះនៅតែជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ចកម្ពុជា ដោយមានចំណែកប្រមាណជា ២៧% នៃ ផសស នៅឆ្នាំ២០០៨ (ក្រាហ្វិក ២) ។ អត្រាកំណើនជាមធ្យម ប្រមាណជា ៤,៥% ក្នុងមួយឆ្នាំចាប់ពីឆ្នាំ១៩៩៨-២០០៨ (ក្រាហ្វិក ៣) រួមចំណែកប្រមាណជា ២% នៃកំណើន ផសស ក្នុងរយៈពេលនោះ (Guimbert 2010) ។ ការកាត់បន្ថយតម្លៃបន្ថែមក្នុង ផសស វិស័យកសិកម្ម គឺបណ្តាលមកពីការកើនឡើងនៃ តម្លៃបន្ថែមក្នុងវិស័យឧស្សាហកម្ម ។ តម្លៃបន្ថែមក្នុងវិស័យឧស្សាហកម្ម កើនឡើងពី ១៥,១% ក្នុងឆ្នាំ១៩៩៥ ដល់ ២៧,៥% ក្នុងឆ្នាំ២០០៨ ខណៈពេលដែលតម្លៃបន្ថែមនៃសេវាកម្មបានប្រែប្រួលខ្លះៗ ក្នុងអំឡុងពេលដូចគ្នា ។ វិស័យកសិកម្ម ស្រូបយកកម្លាំងពលកម្មប្រហែលជា ៥៦% នៃកម្លាំងពលកម្មសរុបក្នុងឆ្នាំ២០០៧ ហើយផលិតភាពពលកម្មបានកើនឡើង ២% ពីឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៧ (ក្រាហ្វិក ៤ក ធនាគារពិភពលោក ឆ្នាំ២០០៩) ។ ចំណែកកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ធ្លាក់ចុះគួរឱ្យកត់សម្គាល់ពី ៧០% ក្នុង ឆ្នាំ២០០១ ដល់ ៥៦% ក្នុងឆ្នាំ២០០៧ ។ ទោះជាយ៉ាងណាក្តី ក្នុងអំឡុងពេលដូចគ្នាដែរ ចំនួនប្រជាជនសរុបដែល ចូលរួមនៅក្នុងវិស័យនេះពុំបានប្រែប្រួលឡើយ ។ កំលាំងពលកម្មចូលរួម ក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម កើនឡើងគួរឱ្យកត់សម្គាល់ពី ១០,២-១៥,៤% និង ១៩,៥-២៨,៧% ក្នុងអំឡុងពេលដូចគ្នា (ក្រាហ្វិក ៤ក និង ខ) ។

ក្រាហ្វិក ៣៖ កំណើនតាមវិស័យនៃ ផសស ឆ្នាំ១៩៩៨-២០០៩ (ថ្លៃថេរ ឆ្នាំ២០០០)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងគណនីជាតិ (ឆ្នាំ២០០៨) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឆ្នាំ២០១០)

**កំណើនកសិកម្ម** ត្រូវបានជម្រុញឡើងដោយសារដី ពលកម្ម និងផលិតភាព ។ កំណើនមិនទៀងទាត់ ដោយសារស្ថានភាពអាកាសធាតុ កើតមានរហូតដល់ឆ្នាំ២០០៥[5] ប៉ុន្តែក្រោយមកវាក៏មានស្ថិរភាព (ក្រាហ្វិក ៣ និងតារាង ១) ។ ប្រការនេះបណ្តាលមកពីការពង្រីកផលិតកម្មដំណាំកសិកម្ម ដោយផលដំណាំកសិកម្មរួមចំណែក ៤៧,៤% នៃ ផសស កសិកម្មចាប់ពីឆ្នាំ១៩៩៨-២០០៨ ។ កន្លងមកស្រូវ គឺជាអនុវិស័យដំណាំធំជាងគេ ដោយរួមចំណែកប្រហែល ២៦% នៃ ផសស តាមវិស័យ (តារាង ១) ។ ផលិតកម្មកៅស៊ូ និងដំឡូងឈើបានរីកចម្រើនគួរឱ្យកត់សំគាល់ ដោយសារការពង្រីកផ្ទៃដីដាំដុះ និងការបង្កើនផលិតភាព ។ ដោយមានតម្រូវការទីផ្សារខ្ពស់ ហើយប្រទេសថៃ វៀតណាម និងចិន

5 នៅឆ្នាំ២០០១ ២០០៣ ២០០៤ មានការរាំងស្ងួត និងទឹកជំនន់ធ្ងន់ធ្ងរនៅរដូវវស្សា ប៉ុន្តែមានអន្តរាគមន៍តិចតួចប៉ុណ្ណោះ ដើម្បីបូមទឹកសង្គ្រោះដំណាំស្រូវ ។

គឺជាគោលដៅនាំចេញចំបង ដំណាំទាំងនេះក៏ក្លាយជាដំណាំដ៏សំខាន់ចំពោះសេដ្ឋកិច្ចកម្ពុជា ។ ទោះជាយ៉ាងណាក្តី មូលដ្ឋានកំណើនក្នុងវិស័យកសិកម្ម ផ្អែកលើតម្លៃបន្ថែមនៃ ផលិតកម្មដំណាំជាក់ស្តែង ជាមួយនឹងការសន្មតថ្លៃថេរ ។ ចំពោះប្រាក់ចំណូល កសិករកាន់តែជួបការលំបាកខ្លាំងឡើងៗ ដោយសារការធ្លាក់ថ្លៃដំណាំកសិកម្មក្នុងរដូវប្រមូលផល ឆ្នាំ២០០៨[6] (Theng 2009; CDRI 2008) ។

ក្រាហ្វិក ៤៖ ការងារតាមវិស័យ ឆ្នាំ១៩៩៨-២០០៧







ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ២០០៤ និង ២០០៩

តារាង ១៖ ផសស តាមអនុវិស័យកសិកម្ម និងកំណើនពីឆ្នាំ១៩៩៩-២០០៨ (ថ្លៃថេរ ឆ្នាំ២០០០)

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|---|---|---|
| *អត្រានៃតម្លៃបន្ថែម (ភាគរយ)* | | | | | | | | | | | |
| កសិកម្ម | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| - ដំណាំ | 43.5 | 44.8 | 43.5 | 42.4 | 46.8 | 46.1 | 50.9 | 50.8 | 52.3 | 52.8 | 47.4 |
| + ក្នុងនោះ៖ ស្រូវ | 25.9 | 25.0 | 24.3 | 23.0 | 25.5 | 22.6 | 28.0 | 27.7 | 29.2 | 27.9 | 25.9 |
| - បសុសត្វ និងបសុបក្សី | 17.0 | 15.5 | 16.6 | 16.8 | 16.1 | 16.9 | 15.4 | 15.8 | 15.6 | 15.3 | 16.1 |
| - នេសាទ | 28.4 | 30.0 | 30.6 | 31.6 | 29.1 | 28.8 | 26.3 | 25.9 | 24.9 | 25.1 | 28.1 |
| - ព្រៃឈើ | 11.1 | 9.7 | 9.3 | 9.1 | 8.0 | 8.1 | 7.4 | 7.5 | 7.2 | 6.9 | 8.4 |
| *កំណើនអនុវិស័យ (ភាគរយ)* | | | | | | | | | | | |
| កសិកម្ម | 2.2 | -0.4 | 3.6 | -2.5 | 10.5 | -0.9 | 15.7 | 5.5 | 5.0 | 5.7 | 4.4 |
| - ផលដំណាំ | 12.1 | 2.4 | 0.6 | -4.8 | 21.9 | -2.3 | 27.6 | 5.3 | 8.2 | 6.6 | 7.8 |
| + ក្នុងនោះ៖ ស្រូវ | 15.1 | -3.8 | 0.7 | -7.8 | 22.2 | -12.2 | 43.7 | 4.4 | 10.7 | 4.1 | 7.7 |
| - បសុសត្វ និងបសុបក្សី | -1.1 | -8.8 | 10.8 | -1.1 | 5.7 | 3.9 | 5.6 | 8.2 | 3.7 | 3.8 | 3.1 |
| - នេសាទ | -2.3 | 5.0 | 5.9 | 0.6 | 1.7 | -1.7 | 5.6 | 3.8 | 0.8 | 1.5 | 2.1 |
| - ព្រៃឈើ | -13.0 | -12.4 | -1.5 | -4.3 | -3.0 | 0.8 | 5.1 | 7.0 | 1.1 | 0.9 | -1.9 |

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០០៤ និងឆ្នាំ២០០៩ និងវិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៨

**ស្រូវ** គឺជាមូលដ្ឋានសំខាន់នៃកំណើនវិស័យកសិកម្មក្នុងប្រទេសកម្ពុជា ។ ផលិតកម្មដំណាំស្រូវ បានកើនឡើង ប្រមាណជា ៣៩៥.០០០តោនក្នុងមួយឆ្នាំៗ តាំងពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៩ ។ កំណើននេះមានទំនាក់ទំនងជាមួយ ការពង្រីកផ្ទៃដីដាំដុះយ៉ាងច្រើន (ជិតស្មើ ២៦%) និងបានបង្កើនទិន្នផលដំណាំ (៤០%) ។ ស្ថិតិរបស់ក្រសួងកសិកម្ម

6 កសិករត្រូវប្រឈមនឹងថ្លៃដើមផលិតកម្មខ្ពស់ ចំពោះពលកម្ម ជី និងប្រេងឥន្ធនៈ ក្នុងរដូវដាំដុះឆ្នាំ២០០៨ ប៉ុន្តែថ្លៃផលកសិកម្ម បានធ្លាក់ចុះ នៅរដូវប្រមូលផលនៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩ (see Theng 2009; CDRI 2008) ។

រុក្ខាប្រមាញ់ និងនេសាទ បង្ហាញថា ផ្ទៃដីដាំដំណាំត្រូវបានពង្រីក ប្រមាណជា ២,៩% ចំណែកផលិតកម្មបានពង្រីក ៧,៤% ក្នុងមួយឆ្នាំ (ក្រាហ្វិក ៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០) ។ ការពង្រីកផ្ទៃដីដាំដុះដំណាំស្រូវភាគច្រើន ប្រព្រឹត្តទៅតាមរយៈតាមការរានព្រៃ (ការកាប់ និង ដុតព្រៃដាំដំណាំនៅតំបន់ខ្ពង់រាប) និងការប្រគល់ដីដែលបានបោសសំអាតគ្រាប់មីន និងដីទំនេរ ដើម្បីយកទៅធ្វើផលិតកម្ម ។ ការកើនឡើងនូវទិន្នផលស្រូវនៅរដូវវស្សា (៤,៦%) មានកម្រិតខ្ពស់ជាងរដូវប្រាំង (៣,២%) ហើយអត្រាកំណើនជាមធ្យមស្មើនឹង ៤,៣% ក្នុងមួយឆ្នាំ (តារាង ២) តាំងពីឆ្នាំ១៩៩៩ ដល់ ២០០៨ ។ ទោះជាយ៉ាងណាក្តី អត្រាកំណើនប្រចាំឆ្នាំនៃផលិតកម្មនៅរដូវវស្សា (៧,២%) មានកម្រិតទាបជាងការដាំដុះក្នុងរដូវប្រាំង (១០,៥%) (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០ USDA ឆ្នាំ២០១០) ។

តារាង ២៖ ទិន្នផលស្រូវរបស់កម្ពុជា និងការប្រៀបធៀបក្នុងតំបន់ (តោនក្នុងមួយហិកតា)

| ឆ្នាំ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | មីយ៉ាន់ម៉ា | ហ្វីលីពីន | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|
| 1999 | 1.94 | 4.25 | 2.93 | 2.94 | 3.24 | 2.95 | 2.42 | 4.10 |
| 2000 | 2.12 | 4.40 | 3.06 | 3.06 | 3.38 | 3.07 | 2.61 | 4.24 |
| 2001 | 2.07 | 4.39 | 3.13 | 3.11 | 3.42 | 3.19 | 2.62 | 4.29 |
| 2002 | 1.92 | 4.47 | 3.27 | 3.24 | 3.42 | 3.28 | 2.61 | 4.59 |
| 2003 | 2.10 | 4.54 | 3.14 | 3.36 | 3.55 | 3.37 | 2.65 | 4.64 |
| 2004 | 1.98 | 4.54 | 3.28 | 3.33 | 3.79 | 3.51 | 2.86 | 4.86 |
| 2005 | 2.48 | 4.57 | 3.49 | 3.42 | 3.75 | 3.59 | 2.96 | 4.89 |
| 2006 | 2.49 | 4.62 | 3.35 | 3.39 | 3.80 | 3.68 | 2.92 | 4.89 |
| 2007 | 2.62 | 4.71 | 3.47 | 3.53 | 3.84 | 3.80 | 3.01 | 4.99 |
| 2008 | 2.75 | 4.89 | 3.55 | 3.59 | 3.72 | 3.77 | 2.96 | 5.22 |
| មធ្យមភាគ | 2.25 | 4.54 | 3.27 | 3.30 | 3.59 | 3.42 | 2.76 | 4.67 |
| អត្រាកំណើន | 4.74 | 1.55 | 2.80 | 2.24 | 1.78 | 3.42 | 1.89 | 2.83 |

ប្រភព៖ FAOSTAT 2010

កំណើនក្នុងផលិតកម្ម និងផ្ទៃដាំដុះ បានរួមចំណែកយ៉ាងច្រើនដល់អតិរេកផលស្រូវរបស់កម្ពុជា ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ប្រទេសកម្ពុជាមានប្រវត្តិផ្គត់ផ្គង់ស្រូវអង្ករបានគ្រប់គ្រាន់តាំងពីឆ្នាំ ១៩៩៥ ។ ប្រការនេះបានកើនឡើងជាបន្តបន្ទាប់ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៦) ។ នៅឆ្នាំ ២០០០ ប្រទេសកម្ពុជាមានផលស្រូវលើសពីការប្រើប្រាស់ក្នុងស្រុកប្រមាណជា ១៤៣.០០០តោន ហើយកើនឡើងដល់ ៣.៥០៧.០០០តោន ក្នុងឆ្នាំ២០០៩ (ក្រាហ្វិក ៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០) ។ កត្តានានាដែលទាក់ទិននឹងកំណើនផលិតកម្មស្រូវរួមមាន ការប្រើប្រាស់ពូជដែលត្រូវបានកែច្នៃ[7] (ផ្លាស់ប្តូរពីពូជស្រូវរយៈពេលវែងមក ពូជស្រូវរយៈពេលខ្លី និងមធ្យម) ការបង្កើនផ្ទៃដីមានការស្រោចស្រព និងការគ្រប់គ្រងទឹក[8] ការកែលំអដល់ ផ្នែកបច្ចេកទេសផលិត ពិសេសជី និងបច្ចេកទេសកែលំអដី ព្រមទាំងអាកាសធាតុអំណោយផល តាំងពីឆ្នាំ២០០៥ មក (USDA 2010) ។ ទោះជាយ៉ាងណាក្តី ថ្វីត្បិតតែមានស្រូវនៅសល់លើសពីតំម្រូវការក្នុងស្រុក ក៏ប្រទេសកម្ពុជា

---

7 CARDI បានរាយការការណ៍ថា អ្នកធ្វើស្រែ ៤០% បានប្រើប្រាស់ពូជស្រូវដែលបានកែច្នៃ និង ៧៥% បានផ្លាស់ប្តូរមកប្រើប្រាស់ពូជដែលមានរយៈពេលខ្លី និងមធ្យម ក្នុងឆ្នាំ២០០៨ (CARDI 2009) ។

8 ក្រសួងធនធានទឹក និងឧតុនិយម រាយការណ៍ថា ផ្ទៃដីស្រោចស្រពទូទាំងប្រទេសមានទំហំ ៨២៧.៣៧៣ហ.ត នៅចុងឆ្នាំ២០០៨ (គឺជាការកើនឡើងយ៉ាងច្រើន ពី ៤០៧.០០០ហ.ត ក្នុងឆ្នាំ១៩៩៨) ក្នុងនេះ ៥៨២.០៨៥ហ.ត គឺសម្រាប់ស្រូវរដូវវស្សា ។ តួលេខនេះតំណាងឲ្យប្រហែលជា ៣១.៦% នៃផ្ទៃដីដាំស្រូវ (RGC 2010a: pp. 48) ។

នៅតែបន្តជួបអសន្តិសុខស្បៀង និងអត្រាភាពក្រីក្រខ្ពស់ ជាពិសេសនៅតាមតំបន់ជនបទ[9] ។ តាំងពីឆ្នាំ២០០៥ ប្រទេសកម្ពុជាបានផលិតស្រូវលើសពីតម្រូវការក្នុងស្រុកច្រើនជាង ២.០០០.០០០តោនក្នុងមួយឆ្នាំ សម្រាប់កែច្នៃ និងនាំចេញ ។ ប្រសិនបើសមត្ថភាពកិនស្រូវ បានធ្វើការកែច្នៃប្រមាណ ៦០% នៃអតិរេកផលស្រូវ គឺត្រូវមានអង្ករប្រមាណជា ១,២ លានតោន សម្រាប់នាំចេញ ។ ប៉ុន្តែតួលេខផ្លូវការស្តីពីការនាំចេញអង្ករ មានចំនួនតិចជាង ២០.០០០តោនក្នុងមួយឆ្នាំ ហើយប្រការនេះបង្ហាញថា ការនាំចេញភាគច្រើន គឺការនាំចេញស្រូវមិនទាន់កែច្នៃ (ក្រាហ្វិក ៦) ។ ឃ្លាំង និងសមត្ថភាពកែច្នៃនៅប្រទេសកម្ពុជា ភាគច្រើននៅមិនទាន់អភិវឌ្ឍបានល្អទេ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០ខ) ។

ក្រាហ្វិក ៥៖ ផលិតកម្ម និងផ្ទៃដីដាំស្រូវឆ្នាំ១៩៩៩-២០០៨




ប្រភព៖ FAOSTAT & MAFF 2010

ក្រាហ្វិក ៦៖ ផលិតកម្មស្រូវ និងអតិរេកផលស្រូវ ២០០០-២០០៩




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០

ទោះបីជាផលិតកម្មស្រូវ បានលើសពីតំរូវការប្រើប្រាស់ក្នុងស្រុក ដោយសារកំណើនទិន្នផលចាប់ពីឆ្នាំ១៩៩៥ ក្តី ទិន្នផលស្រូវកម្ពុជាស្មើនឹង ២,៧៥តោនក្នុងមួយហិកតា ក្នុងឆ្នាំ២០០៨ គឺជាទិន្នផលកម្រិតទាបបំផុតក្នុងតំបន់ ដែលមួយចំណែកបណ្តាលមកពីការប្រើប្រាស់ធាតុចូលតិចបំផុត (តារាង ២ និង ៣) ។ ស្ថិតិដែលមានស្រាប់បង្ហាញថា កសិករកម្ពុជាប្រើប្រាស់ធាតុចូលជាជី និងគ្រឿងយន្តយ៉ាងតិចបំផុត ។ ពួកគេក៏មានលទ្ធភាពតិចតួចក្នុងការបានប្រើប្រាស់ ថ្នាលកៅស៊ូ ប្រព័ន្ធស្រោចស្រព និង ជំនួយបច្ចេកទេសពីសេវាផ្សព្វផ្សាយកសិកម្ម[10] នោះដែរ ។ ចំណុចនេះបង្ហាញថាវិស័យកសិកម្មនៅមានកម្រិតទាបជាងសក្តានុពលពិតប្រាកដរបស់ខ្លួន ធៀបនឹងប្រទេសឯទៀតក្នុងតំបន់ (តារាង ២ និង ៣) ។

**វិស័យជលផល** រួមចំណែក ២៥,១% ក្នុង ផសស កសិកម្ម ក្នុងឆ្នាំ២០០៨ (តារាង ១) និងប្រើកម្លាំងពលកម្មប្រមាណជា ៣៨៥.០០០នាក់ ឬស្មើនឹង ៤,៧% នៃចំនួនប្រជាជនដែលមានការងារធ្វើ (មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០០៩) ។ កំណើនអនុវិស័យជលផលស្មើនឹង ២,១% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ១៩៩៩ ដល់ ២០០៨ ដែលមានប្រភពពីនេសាទទឹកសាប (កើនឡើងពី ២៥០.០០០តោន នៅឆ្នាំ២០០៤ ដល់ ៣៩០.០០០តោន នៅឆ្នាំ២០០៩) និងនេសាទទឹកប្រៃ ។ ផលិតផលនេសាទទឹកប្រៃភាគច្រើន បាននាំចេញ ប៉ុន្តែប្រមាណជា ២០% នៃផលនេសាទត្រីទឹកប្រៃ បានប្រើប្រាស់នៅក្នុងស្រុក ។ របាយការណ៍ផលនេសាទត្រីទឹកប្រៃ កើនឡើងពី ៥៥.០០០តោន ក្នុងឆ្នាំ២០០៤ ដល់

---

9 ផលស្រូវនៅសល់ពីការប្រើប្រាស់ មិនមែនមានន័យថា គ្រប់គ្នាសុទ្ធតែមានស្បៀងបរិភោគគ្រប់គ្រាន់នោះទេ ។ កសិករក្នុងតំបន់មួយចំនួន ផលិតស្រូវលើសពីតំរូវការបរិភោគយ៉ាងច្រើន ចំណែកអ្នកដទៃទៀតរងគ្រោះធ្ងន់ធ្ងរពីកង្វះស្បៀងអាហារ ហើយប្រជាជនក្រីក្រពុំមានលទ្ធភាពក្នុងការបានទទួលស្បៀងអាហារនេះឡើយ ។ ប្រទេសកម្ពុជារងគ្រោះដោយសារកង្វះអាហារបឋម រ៉ាំរ៉ៃ និងកង្វះអាហាររូបត្ថម្ភចំពោះកុមារ កម្រិតខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៧-២០១១ ២០០៦) ។

10 ក្នុងប្រទេសទាំងអស់មានមន្ត្រីផ្សព្វផ្សាយកសិកម្មប្រហែល ៥០០នាក់ ។ ទោះជាយ៉ាងនេះក្តី កសិករត្រឹមតែ ០,៧% ប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មក្នុងទម្រង់ណាមួយ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើវិភាជន៍ចំពោះការផ្សព្វផ្សាយកសិកម្មសរុប តិចជាង ១% នៃថវិកាសរុបរបស់ក្រសួង (ធនាគារពិភពលោក ឆ្នាំ២០០៩) ។

៧៥.០០០តោន ក្នុងឆ្នាំ២០០៩ (ក្រាហ្វិក ៧ ក្រសួងកសិកកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០) ។ របាយការណ៍ផលិតកម្មវារីវប្បកម្ម ក៏បានកើនឡើងយ៉ាងខ្ពស់ផងដែរពី ឆ្នាំ២០០៤ ដល់ ២០០៩ ដែលអាចបណ្ដាលមកពីតម្រូវការនៃកំណើនប្រជាជន និងការលើកកម្ពស់គួរឱ្យកត់សំគាល់នូវបច្ចេកវិទ្យាវារីវប្បកម្ម ។

តារាង ៣៖ ធាតុចូលកសិកម្ម

| ការប្រើប្រាស់ធាតុចូល | កម្ពុជា | ឡាវ | ម៉ាឡេស៊ី | ថៃ | វៀតណាម | ចិន |
|---|---|---|---|---|---|---|
| ការប្រើជី (គ.ក្រ/ហិកតា ចំពោះដីដែលអាចដាំដុះ ឆ្នាំ២០០៤) | 5.0 | - | 821.3 | 123.3 | 374.3 | 327.9 |
| គ្រឿងយន្តកសិកម្ម (ត្រាក់ទ័រក្នុងមួយម៉ែត្រការ៉េ នៃដីដែលអាចដាំដុះបាន ឆ្នាំ២០០៥) | 11.0 | 9.8 | 241.0 | 529.6 | 256.6 | 124.3 |
| ដីដែលបានស្រោចស្រព (ភាគរយនៃដីដាំដំណាំ ឆ្នាំ២០០៣) | 7.0 | 16.5 | - | 28.2 | 33.7 | 35.6 |
| ផ្លូវថ្នល់ក្រាលកៅស៊ូ (ភាគរយនៃផ្លូវថ្នល់សរុប ឆ្នាំ២០០៤) | 6.3 | 13.4 | 79.8 | 98.5 | 47.6 | 70.7 |

ប្រភព៖ World Development Indicators 2009 & 2010

បសុសត្វ និងបសុបក្សី ក៏មានមុខងារសំខាន់ផងដែរ ក្នុងសេដ្ឋកិច្ចតំបន់ជនបទនៃប្រទេសកម្ពុជា ដោយមានចំណែក ១៥,៣% ក្នុង ផសស កសិកម្ម (តារាង ១) ។ ប៉ុន្តែថាមភាពនៃវិស័យនេះបានធ្លាក់ចុះ ដោយកំណើនបានថយចុះពី ១០,៨% ក្នុងឆ្នាំ២០០១ មកត្រឹម ៣,៨% ក្នុងឆ្នាំ២០០៨ ។ អត្រាកំណើនជាមធ្យម ស្មើនឹង ៣,១% តាំងពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ។ ទោះជាមានការធ្លាក់ចុះក្ដី សន្និធិបសុសត្វសំខាន់ៗបានកើនឡើងគួរឱ្យកត់សំគាល់ ឧទាហរណ៍ គោកើនឡើងពី ៣.០៣៩លានក្បាល ដល់ ៣.៥៧៩លានក្បាល ចំណែកបសុបក្សី កើនឡើងពី ១៣.៩៩លាន ដល់ ២០.១៩លានក្បាល (ក្រាហ្វិក ៨ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០) ។ សន្និធិគោ បានកើនឡើង ៣,៣% ក្នុងមួយឆ្នាំ បសុបក្សីកើនឡើង ៧,៨% ប៉ុន្តែសន្និធិជ្រូក មានកំណើនអវិជ្ជមានប្រមាណជា ២,៥% ដែលបញ្ជាក់ថា វិស័យនេះរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការនាំចូលជ្រូកមកពីប្រទេសជិតខាង ដែលធ្វើឱ្យបាក់ទឹកចិត្តដល់ផលិតកម្មក្នុងស្រុក ។

ក្រាហ្វិក ៧៖ ផលនេសាទ (ពាន់តោន)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ឆ្នាំ២០១០

ក្រាហ្វិក ៨៖ ផលិតកម្មបសុសត្វ និងបសុបក្សី(ពាន់ក្បាល)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ឆ្នាំ២០១០

**វិស័យព្រៃឈើ** ក៏បានរួមចំណែកសំខាន់ផងដែរ ចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជា មុនពេលផ្អាកសកម្មភាពកាប់ឈើនៅខែធ្នូ ឆ្នាំ២០០១ ។ វិស័យនេះរួមចំណែក ៧% ក្នុង ផសស កសិកម្ម ក្នុងឆ្នាំ២០០៨ ដោយធ្លាក់ចុះពី ១១,១% ក្នុងឆ្នាំ១៩៩៩ (តារាង ១) ។ រាជរដ្ឋាភិបាលបានប្រកាសពីការហាមឃាត់ការកាប់ឈើ និងការកែច្នៃឈើក្នុងឆ្នាំ១៩៩៩ ហើយបានពង្រឹងការហាមឃាត់នេះដោយចេញប្រកាសមួយនៅខែធ្នូ ឆ្នាំ២០០១ ដើម្បីហាមឃាត់រាល់សកម្មភាពកាប់ឈើទាំងអស់នៅកម្ពុជា ។ ការពង្រឹងវិធានការរបស់រដ្ឋាភិបាលលើផ្នែកនេះ គឺជាគោលនយោបាយជាតិចំពោះព្រៃឈើដែល

បានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០០២ និងច្បាប់ព្រៃឈើដែលបានអនុម័តកាលពីខែតុលា ឆ្នាំ២០០២ ។ តាំងពីមានបទបញ្ញត្តិទាំងនេះដើម្បីទប់ស្កាត់ការប្រើប្រាស់ព្រៃឈើដែលគ្មាននិរន្តរភាពមក វិស័យនេះបានធ្លាក់ចុះគួរឱ្យកត់សំគាល់ក្នុងអត្រាមធ្យមស្មើ ១,៩%ក្នុងមួយឆ្នាំក្នុង ចន្លោះឆ្នាំ១៩៩៩ និងឆ្នាំ២០០៨ (តារាង ១) ។ ទោះបីជាមានតម្លៃបន្ថែមតូចបំផុតក្នុងវិស័យកសិកម្មក្តី ព្រៃឈើនៅតែបន្តមុខងារដ៏សំខាន់ជួយទ្រទ្រង់ការចិញ្ចឹមជីវិតនៅជនបទដោយផ្តល់សម្ភារៈសំណង់ អុស ចំណីបសុសត្វ ថ្នាំបុរាណ និងប្រាក់ចំណូលបន្ថែមដល់គ្រួសារនានា ។ ស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឆ្នាំ២០១០) រាយការណ៍ថា ក្នុងឆ្នាំ២០០៩ មានសហគមន៍ព្រៃឈើចំនួន ៣៩៥ បានបង្កើតឡើងដែលមានផ្ទៃដីសរុបចំនួន ៣២៥.១៣០ហ.ត និងគ្រប់គ្រងដោយសហគមន៍ខ្លួនឯង ។ កម្លាំងពលកម្មប្រមាណជា ៦១.០០០នាក់ បានចូលរួមដោយផ្ទាល់ ក្នុងអនុវិស័យព្រៃឈើក្នុងឆ្នាំ២០០៧ (មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០០៩) ។

## ៣. គោលនយោបាយសម្រាប់លើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា

តាំងពីអាណត្តិទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩៣ មក មានគោលនយោបាយអភិវឌ្ឍន៍ជាតិ និងក្រោមជាតិ ឬគោលនយោបាយអភិវឌ្ឍន៍តាមវិស័យមួយចំនួនត្រូវបានបង្កើតឡើង ។ ចក្ខុវិស័យនៃគោលនយោបាយនានា គឺជម្រុញដល់និរន្តរភាពកំណើនសេដ្ឋកិច្ច និងចែករំលែកផលចំនេញនៃកំណើនសេដ្ឋកិច្ចដល់ពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ចំណុចយកចិត្តទុកដាក់សំខាន់មួយក្នុងគោលនយោបាយទាំងនេះ គឺវិស័យកសិកម្មដែលបន្តមានមុខងារសំខាន់ ក្នុងកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ។ ផ្នែកនេះពិនិត្យមើលឡើងវិញនូវគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀង ។ គោលនយោបាយដទៃទៀតដែលទាក់ទងដល់ផលចំនេញក្នុងការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀង ដូចជា ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ វិស័យសុខាភិបាល និងអប់រំ ពុំមែនជាចំណុចចំបងនៃការពិនិត្យមើលសាឡើងវិញនេះទេ ។

### ៣.១ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច (SEDP)

ក្រោយពីការបោះឆ្នោតថ្នាក់ជាតិដឹកនាំដោយ អ៊ុនតាក់ ក្នុងឆ្នាំ១៩៩៣[11] រដ្ឋាភិបាលថ្មីបានចូលកាន់អំណាចនៅខែកញ្ញា ក្នុងឆ្នាំដដែល ដើម្បីអភិវឌ្ឍន៍ប្រទេសដែលរងគ្រោះពីសង្គ្រាមស៊ីវិលអស់រយៈពេល ២០ឆ្នាំ នោះ កម្មវិធីជាតិដើម្បីស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (NPRD) ត្រូវបានអនុម័តភ្លាមៗ ក្នុងឆ្នាំ១៩៩៤ ។ NPRD ព្យាយាមសម្រេចបាននូវសង្គមមួយដែលមានយុត្តិធម៌ និងមានសន្តិភាព តាមការបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតស្តង់ដារជីវភាពរស់នៅរបស់ពលរដ្ឋកម្ពុជាទាំងអស់ តាមរយៈការប្រើប្រាស់ធនធានធម្មជាតិឲ្យសមស្រប និងបង្កលទ្ធភាពឲ្យប្រជាជនទាំងអស់ទទួលបានដោយសមធម៌នូវអត្ថប្រយោជន៍ពីកំណើន ។ គោលនយោបាយនេះផ្តល់អាទិភាពដល់ការអភិវឌ្ឍជនបទ ហើយគោលដៅរយៈពេលខ្លីគឺ ការលើកកម្ពស់ជីវភាពរស់នៅនៅតំបន់ជនបទ ។ ស្របតាមគោលនយោបាយអភិវឌ្ឍន៍តំបន់ជនបទ គោលនយោបាយវិស័យកសិកម្ម ក៏បានផ្តល់អាទិភាពដល់ពិពិធកម្មដំណាំកសិកម្ម និងបសុសត្វ និងការធ្វើអាជីវកម្មព្រៃឈើ និងធនធានជលផលប្រកបដោយប្រសិទ្ធភាពដែរ ។ យុទ្ធសាស្រ្តចំពោះមុខរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យកសិកម្មគឺ ផលិតស្រូវឱ្យគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងស្រុក លើកកម្ពស់វិស័យបសុសត្វ និងជម្រុញទិសដៅក្នុងទីផ្សារ ។

ទោះជា NPRD ត្រូវបានអនុវត្តក្តី ដោយសារអស្ថិរភាពនយោបាយ គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច មិនត្រូវបានអនុវត្តទៀងទាត់ឡើយ រហូតដល់មាន ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី ១ (SEDP-I) ដែលបានអនុវត្តតាំងពីឆ្នាំ១៩៩៦-២០០០ (Ho-Seop 2004) ។ SEDP បានរៀបចំឡើងដោយផ្អែកយ៉ាងច្រើនលើ NRPD ប៉ុន្តែមានទិសដៅឆ្ពោះចំលទ្ធផលជាក់លាក់ជាង ដើម្បីសម្រេចគោលដៅកំណើនសេដ្ឋកិច្ច ។ គោលដៅចំបង និងចំណុចគោល

11 United Nations Transitional Authority in Cambodia.

ដែលដាក់ចេញដោយ SEDP គឺ៖ ១) ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន ដើម្បីទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ (ក្នុងឆ្នាំ២០០៤ បង្កើន ផសស ឆ្នាំ១៩៩៤ ទ្វេដង តាមន័យពិត) ដោយផ្តោតលើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ ២) លើកកម្ពស់ជីវភាពរស់នៅនៅតំបន់ជនបទតាមរយៈការអភិវឌ្ឍវិស័យកសិកម្ម និងអភិវឌ្ឍន៍តំបន់ជនបទ ៣) អភិបាលកិច្ចល្អ ៤) ជម្រុញវិនិយោគលើធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សុខាភិបាល អប់រំ និង ៥) ជម្រុញកំណែទម្រង់ដីធ្លី និងការការពារបរិស្ថាន ។ ដោយទទួលស្គាល់ថា ការកាត់បន្ថយភាពក្រីក្រ គឺជាផ្នែកសំខាន់មួយនៃការផ្សះផ្សាសង្គម និងជាគន្លឹះរក្សាស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសការកាត់បន្ថយភាពក្រីក្រថាជាគោលដៅរយៈពេលវែងសំខាន់ជាងគេបំផុត ជាលើកដំបូងក្នុងឆ្នាំ១៩៩៦ និងការលុបបំបាត់ភាពក្រីក្រថាជា ចលករចំបងនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ១ (SEDP-I) (១៩៩៦-២០០០) ។ គោលដៅមូលដ្ឋានកំណត់ដោយរាជរដ្ឋាភិបាលសម្រាប់វិស័យកសិកម្មគឺ៖ ១) ធានាឱ្យមានសន្តិសុខស្បៀងតាមរយៈការពង្រីកផលិតកម្មស្រូវ និងការផ្គត់ផ្គង់ស្រូវតាមទីផ្សារ និងតាមរយៈដំណាំស្បៀងបន្ទាប់បន្សំ ២) រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការទទួលបាននូវរូបិយប័ណ្ណបរទេស តាមរយៈការនាំចេញ ៣) លើកម្ពស់ឱកាសរកប្រាក់ចំណូលរបស់គ្រួសារប្រកបរបរកសិកម្មតាមរយៈការធ្វើពិពិធកម្មផលិតកម្មដំណាំ ។

ដំណាំ និងបសុសត្វ គឺជាអាទិភាពចំបងដើម្បីសម្រេចនូវការផ្គត់ផ្គង់គ្រប់គ្រាន់បំពេញតម្រូវការប្រើប្រាស់ស្បៀងអាហារ ។ ដើម្បីសម្រេចគោលដៅនេះ ក្នុងវិស័យដំណាំ គោលនយោបាយរបស់រាជរដ្ឋាភិបាលផ្តោតលើការស្តារនីតិសម្បទាប្រព័ន្ធស្រោចស្រពនិងរំដោះទឹក ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការលើកកម្ពស់ការប្រើប្រាស់ជី និងការបង្កើនល្បឿនការបោសសំអាតគ្រាប់មីន ដើម្បីពង្រីកការដាំដុះលើផ្ទៃដីដែលត្រូវបានបោះបង់ចោល ។ ដោយប្រមើលឃើញថា ការនាំស្រូវចេញមិនអាចក្លាយជាប្រភពចំណូលជាតិបាន យោងតាមការលំបាកផ្សេងៗក្នុងការព្យាករណ៍ទិន្នផលស្រូវដោយសារភ្លៀងធ្លាក់មិនទៀងទាត់ និងកំណើនប្រជាជនឆាប់រហ័ស គោលនយោបាយរាជរដ្ឋាភិបាលបានលើកកម្ពស់ការនាំចេញក្នុងវិស័យកៅស៊ូតាមរយៈការធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូរបស់រដ្ឋ ដោយបង្កើតការវិនិយោគរួមគ្នារវាងក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុក ។ ចំពោះវិស័យបសុសត្វ គេពុំឃើញមានគោលនយោបាយច្បាស់លាស់ដើម្បីលើកកម្ពស់ផលិតកម្មទេ ទោះបីជាវិស័យមួយដ៏សំខាន់សម្រាប់សេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទក្តី ។ គោលនយោបាយមួយចំនួនទៀតបានដោះស្រាយបញ្ហានានាដូចជា ការគ្រប់គ្រងជម្ងឺ ការចាក់ថ្នាំបង្ការ ការបង្កាត់ពូជសត្វ អាហារូបត្ថម្ភសត្វ ក៏ដូចជា ការស្វែងរកទីផ្សារគោក្របី ព្រោះមានពាណិជ្ជកម្មក្រៅផ្លូវការរវាង ប្រទេសកម្ពុជានិងប្រទេសថៃ និង ប្រទេសកម្ពុជា និងប្រទេសវៀតណាម ។

ទាក់ទងនឹងវិស័យជលផល និងព្រៃឈើ ដូចមានបញ្ជាក់ច្បាស់នៅក្នុងឯកសារ NRDP រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តធ្វើអាជីវកម្មលើធនធានទាំងនេះ ទោះបីជាមានគោលនយោបាយណែនាំយ៉ាងតឹងរ៉ឹងក៏ដោយ ។ គោលនយោបាយវិស័យជលមានគោលដៅ ៖ ១) រក្សា ឬបង្កើនការទទួលទានប្រូតេអ៊ីនត្រីដល់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗ ២) បង្កើនប្រាក់ចំណូលដែលបានមកពីវិស័យនេះ និង ៣) ថែរក្សាបរិស្ថានជលផល និងធានាការពង្រីកផលិតកម្ម ទន្ទឹមនឹងការធានានិរន្តរភាពបរិមាណស្តុកត្រី ។ វារីវប្បកម្មដូចជា ការចិញ្ចឹមត្រីតាមស្រះជាដើម ត្រូវបានលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាលដើម្បីផ្តល់ត្រី និងរួមចំណែកចំពោះអាហារូបត្ថម្ភនៅតំបន់ឆ្ងាយដាច់ស្រយាលពីតំបន់នេសាទទឹកសាបសំខាន់ៗ ។ គោលនយោបាយវិស័យព្រៃឈើ ផ្តោតសំខាន់លើ ១) គ្រប់គ្រងប្រកបដោយនិរន្តរភាពនូវសម្បទាននានា និង ពង្រឹងអនុវត្តបទបញ្ញត្តិផ្សេងៗ ២) គ្រប់គ្រងការកាប់ឈើខុសច្បាប់ និង ៣) ណែនាំការធ្វើអាជីវកម្មដើម្បីផ្តល់ឈើដល់រោងចក្រកែច្នៃឈើក្នុងស្រុក ។

រាជរដ្ឋាភិបាលក្នុងអាណត្តិទី ២ បានអនុម័តយុទ្ធសាស្ត្រត្រីកោណបន្ទាប់ពីការបោះឆ្នោត ក្នុងខែកក្កដា ឆ្នាំ១៩៩៨ ។ គោលនយោបាយនេះផ្តល់អាទិភាពសសរស្តម្ភចំនួន ៣៖ ១) ពង្រឹងស្ថិរភាព សន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២) ធ្វើសមាហរណកម្មកម្ពុជាក្នុងតំបន់ និងសហគមន៍អន្តរជាតិ ៣) អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ។ សសរស្តម្ភទាំង ៣ ភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក និងមានមូលដ្ឋានផ្អែកលើកំណែទម្រង់រដ្ឋ

ពោលគឺអភិបាលកិច្ចល្អ ។ នៅជិតចុងបញ្ចប់នៃ SEDP-I មានការរៀបចំ SEDP-II ឆ្នាំ២០០១-០៥ (ឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី) ដែលរួមបញ្ចូលគោលដៅយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា តាមការដាក់បញ្ចូលយុទ្ធសាស្ត្រត្រីកោណ និងឯកសារបណ្ដោះអាសន្នស្ដីពីការកាត់បន្ថយភាពក្រីក្រ ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីកាលពីខែតុលា ឆ្នាំ២០០០ ។ SEDP-II ចែងគោលដៅចំបងទូទៅចំនួន ៤ ជាអាទិភាព៖ ១) កំណើនសេដ្ឋកិច្ចរយៈពេលវែង ប្រកបដោយនិរន្តរភាពដែលដឹកនាំដោយវិស័យឯកជន (៦-៧% ក្នុងមួយឆ្នាំ) ២) ការបែងចែកប្រាក់ចំណូលប្រកបដោយសមធម៌ និងលទ្ធភាពទទួលសេវាអភិវឌ្ឍន៍សង្គមនិងវប្បធម៌ មានជាអាទិ អប់រំ សុខាភិបាល ទឹកស្អាត អនាម័យ ថាមពល ឥណទាន ទីផ្សារ ព័ត៌មាន និងបច្ចេកវិទ្យាសមស្រប ៣) ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន និង ៤) កំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល ដើម្បីឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ។

សម្រាប់គោលនយោបាយតាមវិស័យ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការអភិវឌ្ឍន៍វិស័យកសិកម្ម គឺជាគន្លឹះចំបងក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សន្តិសុខស្បៀង ព្រមទាំងជម្រុញការអភិវឌ្ឍសហគមន៍ និងអភិរក្សធនធានធម្មជាតិដែលជាគន្លឹះឆ្ពោះទៅរកនិរន្តរភាព ។ រដ្ឋាភិបាលកំណត់នូវ កំណើនកសិកម្មស្មើនឹង ៣,៥% ក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០០១-២០០៥ ធ្វើជាគោលដៅរបស់ខ្លួន ។ គោលនយោបាយវិស័យកសិកម្មក្នុង SEDP-II មានលក្ខណៈប្រហាក់ប្រហែលគ្នានឹង SEDP-I ឆ្នាំ១៩៩៦-២០០០ ដោយកំណត់អាទិភាពដំណាំកសិកម្មជាចំបង ជាពិសេស ស្រូវ បសុសត្វ និងជលផល ព្រមទាំងកំណែទម្រង់វិស័យព្រៃឈើ ។ គោលនយោបាយកើតឡើងក្នុងអំឡុង SEDP-II នៅពេលដែលកំណែទម្រង់ជលផល និងព្រៃឈើ ត្រូវបានប្រកាន់យកយ៉ាងម៉ត់ចត់ដោយរាជរដ្ឋាភិបាល ។ ឡូត៍នេសាទសម្បទានព្រៃឈើជាច្រើន បានប្ដូរជាកម្មសិទ្ធិសហគមន៍ និងគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ខ្លួនឯង ។ កំណែទម្រង់ព្រៃឈើបានចាប់ផ្ដើមក្នុងឆ្នាំ១៩៩៩-២០០០ ហើយបានពង្រឹងក្នុងឆ្នាំ២០០២ តាមរយៈការព្យួរការកាប់ឈើ និងសកម្មភាពកែច្នៃឈើទាំងអស់ (សូមអានជំពូក ២ ខាងលើ) ខណៈដែលកំណែទម្រង់ជលផល ចាប់ផ្ដើមនៅចុងឆ្នាំ២០០០ និងបន្តរហូតដល់ឆ្នាំ២០០១ ដោយមានប្រមាណជា ៥៣% នៃផ្ទៃឡូត៍សរុប បានក្លាយទៅជាឡូត៍នេសាទលក្ខណៈគ្រួសារ ពោលគឺ សហគមន៍នេសាទ ។

### ៣.២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥

អំឡុងពេលដែលគោលនយោបាយអភិវឌ្ឍន៍ SEDP-II ស្របគ្នា ២ ត្រូវបានរៀបចំឡើង ពោលគឺ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ និង គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDGs) ឆ្នាំ២០០៣-២០១៥ ។ ឯកសារបណ្ដោះអាសន្នស្ដីពីការកាត់បន្ថយភាពក្រីក្រ (I-PRSP) បានរៀបចំពីដំបូងក្នុងឆ្នាំ១៩៩៩ ដែលឧបត្ថម្ភដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ក្នុងគោលបំណងដាក់លក្ខខ័ណ្ឌលើការលុបចោលបំណុលក្រោមកម្មវិធីលើកកម្ពស់ប្រទេសក្រីក្រដែលជំពាក់បំណុលធ្ងន់ធ្ងរ ។ បន្ទាប់មក ឯកសារនេះបានក្លាយជាឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSP) ក្នុងឆ្នាំ២០០២ ។ នៅចុងបញ្ចប់ កម្ពុជាបានអនុម័តឯកសារនេះ ហើយប្ដូរឈ្មោះជាយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ ក្នុងខែធ្នូ ឆ្នាំ២០០២ ។ ស្រដៀងគ្នានឹង SEDP-II ដែរ NPRS បានអនុម័តតាមយុទ្ធសាស្ត្រត្រីកោណក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ដល់អាទិភាពដល់៖ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែងដោយមានគោលដៅសម្រេចឱ្យបាន ៦-៧% ក្នុងមួយឆ្នាំ ការបែងចែកផលចំនេញពីកំណើនសេដ្ឋកិច្ច និងលទ្ធភាពទទួលបានសេវាសង្គម និងវប្បធម៌ប្រកបដោយនិរន្តរភាព ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព និងកំណែទម្រង់បរិស្ថានអភិបាលកិច្ច ។

ម្យ៉ាងទៀត NPRS ក៏មានសេចក្ដីណែនាំស្រដៀងគ្នាស្ដីពីគោលនយោបាយតាមវិស័យដែរ ដើម្បីលើកកម្ពស់ជីវភាពរស់នៅតំបន់ជនបទ ដោយមានគោលនយោបាយមួយចំនួន រួមមាន៖ ការលើកកម្ពស់លទ្ធភាពទទួលបានដីធ្លី ការអភិវឌ្ឍនិងពិពិធកម្មកសិកម្ម ចលនាភូមិមួយផលិតផលមួយ ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍប្រព័ន្ធ

ស្រោចស្រព និងបង្ហូរទឹក និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ គោលនយោបាយអភិវឌ្ឍន៍កសិកម្ម ត្រូវបានរាជរដ្ឋាភិបាលរៀបចំឡើងដើម្បីៈ (១) ធានាឱ្យមានក្របខ័ណ្ឌគតិយុត្តិសមស្រប និង ផ្នែកស្ថាប័នបរិស្ថាន (២) ពង្រឹងសមត្ថភាព និងលើកកម្ពស់ប្រព័ន្ធព័ត៌មានរបស់រដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងជាពិសេសកសិករខ្នាតតូច (៣) បង្កើនប្រពលវប្បកម្មពិពិធកម្ម និងសន្តិសុខ ផលិតកម្មកសិកម្ម (៤) ជម្រុញការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព និង (៥) ជម្រុញការកែច្នៃផលិតផលកសិកម្ម និងវិនិយោគក្នុងផ្នែកកសិឧស្សាហកម្ម និងព្រមទាំងពង្រឹងប្រព័ន្ធទីផ្សារកសិកម្ម និងច្រកចូលទៅកាន់ទីផ្សារ ។

បរិបទនៃការប្រៀបធៀបគោលនយោបាយ SEDP និង NPRS ពុំមានភាពខុសប្លែកគ្នាគួរឲ្យកត់សំគាល់ទេ ហើយឯកសារទាំងពីរផ្តោតលើចក្ខុវិស័យ និងយុទ្ធសាស្ត្រដូចគ្នា ដោយដាក់វិស័យជាច្រើនឲ្យចូលរួមដោះស្រាយការកាត់បន្ថយភាពក្រីក្រ និងមានបញ្ជីសកម្មភាពអាទិភាពស្ទើរតែដូចគ្នាទាំងអស់ ចំណែកភាពខុសគ្នាមានតែលើបែបផែន និងរចនាសម្ព័ន្ធឯកសារប៉ុណ្ណោះ ។ នេះជាការខាតបង់ធនធាន និងពេលវេលាចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តគោលនយោបាយជាតិស្របគ្នាចំពោះបេសកកម្មដដែល គឺដូចគ្នានឹងម្ចាស់ជំនួយសំខាន់ៗដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ដែលមិនបានសហការគ្នារៀបចំនូវ យុទ្ធសាស្ត្រប្រចាំប្រទេសតែមួយ (Shimomura & Ohno ឆ្នាំ២០០៥) ។

## ៣.៣ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ២០០៣-២០១៥

ស្របជាមួយ SEDP-II គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG) ឆ្នាំ២០០៣-២០១៥ ក៏បានបង្កើតឡើងដោយ ផ្តល់អាទិភាពដល់ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ។ បន្ថែមលើគោលដៅអភិវឌ្ឍន៍សហសវត្សរ៍សាកលទាំង ៨ កម្ពុជាមានគោលដៅទី ៩ គឺការដោះមីន ។ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាទាំង ៩ គោលដៅអភិវឌ្ឍន៍ទី២ ឆ្លុះបញ្ចាំងដោយផ្ទាល់ពីការអភិវឌ្ឍកសិកម្ម និងគោលដៅគោលនយោបាយស្តីពីជីវភាពរស់នៅដែលត្រូវសម្រេចឲ្យបាននៅឆ្នាំ២០១៥ ។ គោលដៅមួយក្នុងចំណោមគោលដៅទាំង ២ គឺគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាលេខ១ ពោលគឺការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន មានគោលដៅរួមធ្វើការកាត់បន្ថយឱ្យបានពាក់កណ្តាលនូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ មកត្រឹម ១៩,៥% និងប្រជាជនដែលប្រើប្រាស់ស្បៀងទាបជាងបន្ទាត់នៃភាពក្រីក្រស្បៀង (ភាពអត់ឃ្លាន និងអាហារូបត្ថម្ភ) មកត្រឹម ១០% នៅឆ្នាំ២០១៥ ។ គោលនយោបាយមានស្រាប់ដែលបានរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រចាំសហវត្សរ៍កម្ពុជាទី១ មានអធិប្បាយនៅក្នុងឯកសារ SEDP-II និង NPRS ។ ឯកសារទាំងពីរមានចក្ខុវិស័យលើកកម្ពស់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលវែង ដើម្បីសម្រេចការអភិវឌ្ឍមានមូលដ្ឋានធំទូលាយតាមរយៈកំណើនសំរាប់ជនក្រីក្រ ការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់កសិកម្ម និងសហគ្រាសធុនតូច និងធុនមធ្យមនៅជនបទ និងអភិបាលកិច្ចល្អ ។ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាលេខ១ ក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ ៣ ត្រូវបានផ្តល់អាទិភាពៈ បរិយាការម៉ាក្រូសេដ្ឋកិច្ច បរិយាកាសមីក្រូសេដ្ឋកិច្ច និងការការពារសង្គម និងការកាត់បន្ថយហានិភ័យ ។ ចំណុចដៅកំណត់ក្នុងគោលដៅប្រចាំសហសវត្សរ៍កម្ពុជាលេខ៧ គឺធានានិរន្តរភាពបរិស្ថានដើម្បីរក្សានិងការពារធនធានព្រៃឈើ និងធនធានជលផល តាមរយៈការផ្តល់អាទិភាពដល់គោលនយោបាយដើម្បីអភិវឌ្ឍន៍សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ ។ SEDP-II និង NPRS បានអនុម័តគោលនយោបាយយ៉ាងច្បាស់លាស់សម្រាប់ធ្វើកំណែទម្រង់វិស័យទាំងនេះ ។

## ៣.៤ យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព គឺជាកម្មវិធីនយោបាយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៣ ឆ្នាំ២០០៣-២០០៨ ។ យុទ្ធសាស្ត្រនេះផ្តោតលើសមិទ្ធផលនៃយុទ្ធសាស្ត្រត្រីកោណ

របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី២ ។ ធាតុផ្សំសំខាន់ៗបានជ្រើសយកពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ២០០៣ SEDP-II ឆ្នាំ២០០១-២០០៥ និង NPRS ២០០៣-២០០៥ តាមរយៈការពិគ្រោះយោបល់ដ៏ទូលំទូលាយ ជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ។ យុទ្ធសាស្ត្រចតុកោណនេះ បានបង្ហាញក្នុងទម្រង់ន័យធៀបដោយមាន អភិបាលកិច្ចល្អជាស្នូល ព័ទ្ធជុំវិញដោយសសរស្តម្ភចំនួន ៤ ដែលជាបរិយាកាសត្រូវកើតមាន និងចតុកោណកំណើន យុទ្ធសាស្ត្រចំនួន ៤ ។ ចតុកោណកំណើនយុទ្ធសាស្ត្រទាំង ៤ គឺ៖ ១) ការលើកកម្ពស់វិស័យកសិកម្ម ២) ការស្តារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបន្ថែម ៣) ការអភិវឌ្ឍវិស័យឯកជន និងភាពមានការងារធ្វើ និង ៤) ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ។ ការលើកកម្ពស់ចតុកោណកំណើនវិស័យកសិកម្មពាក់ព័ន្ធ នឹងការអភិវឌ្ឍយុទ្ធសាស្ត្រអាទិភាពចំនួនបួន ដែលត្រូវបានអនុម័តពីទស្សនទានរបស់ SEDP-II គឺមាន៖ ១) ការលើកកម្ពស់ផលិតកម្ម និងពិពិធកម្មកសិកម្ម ២) កំណែទម្រង់ដីធ្លី និងការបោសសំអាតមីន ៣) កំណែទម្រង់ ជលផល និង ៤) កំណែទម្រង់ព្រៃឈើ ។

លើសពីនេះ មានគោលនយោបាយមួយចំនួនទៀតដែលបានរួមចំណែកដោយផ្ទាល់ក្នុងលើកកម្ពស់ការអភិវឌ្ឍ វិស័យកសិកម្ម និងពិពិធកម្មវិស័យកសិកម្ម ត្រូវបានផ្តល់អាទិភាពក្នុងកំណើនយុទ្ធសាស្ត្រចតុកោណ គឺមាន៖ ១) ការស្តារនីតិសម្បទា ២) ការសាងសង់ ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធស្រោចស្រព អាងស្តុកទឹក ប្រឡាយ បំពង់បង្ហូរ ប្រព័ន្ធបង្ហូរទឹក ស្ថានីយ៍បូមទឹកជំនន់ និងស្ថានីយ៍បូមទឹកប្រកបដោយប្រសិទ្ធភាព ដើម្បី បង្កើនផ្ទៃដីស្រោចស្រព និងជម្រុញផលិតកម្មកសិកម្ម ២) លើកកម្ពស់ការគ្រប់គ្រងប្រព័ន្ធស្រោចស្រពប្រកបដោយ ប្រសិទ្ធភាព តាមរយៈការពង្រឹងសមត្ថភាពស្ថាប័នចំពោះមន្ត្រី និងភ្នាក់ងារពាក់ព័ន្ធ ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ បានអនុម័តជាមូលដ្ឋានតាម ទស្សនទានយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី១ ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ មានយុទ្ធសាស្ត្ររយៈពេលវែងច្បាស់លាស់ចំនួន ៤ ដែលជា គោលដៅអាទិភាពដើម្បីជាទា៖ ១) សន្តិភាពប្រកបដោយនិរន្តរភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ សង្គមតាមរយៈការកាត់វិធានការជាក់លាក់ដើម្បីលើកកម្ពស់នីតិរដ្ឋការគោរពសិទ្ធិមនុស្សនិងភាពថ្លៃថ្នូរនិងប្រជាធិបតេយ្យ សេរីពហុបក្សដើម្បីបង្កើតស្ថិរភាពនយោបាយសម្រាប់អភិវឌ្ឍន៍រយៈពេលវែងប្រកបដោយនិរន្តរភាព២) កំណើនសេដ្ឋកិច្ច មានរយៈពេលវែងប្រកបដោយនិរន្តរភាពប្រមាណជា ៧% ក្នុងមួយឆ្នាំ ដោយមានមូលដ្ឋានសេដ្ឋកិច្ចកាន់តែធំទូលាយ និងមានលក្ខណៈប្រកួតប្រជែង ក្នុងបរិបទមានអតិផរណាទាបត្រឹមលេខមួយខ្ទង់ ស្ថិរភាពអត្រាប្តូរប្រាក់ និងការកើនឡើង ជាបណ្តើរៗនៃប្រាក់បំរុងអន្តរជាតិ ៣) ការបែងចែកឱកាស និងប្រាក់ចំណេញពីកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ៤) និរន្តរភាពបរិស្ថាន ជាពិសេសតាមរយៈការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ គោលនយោបាយអភិវឌ្ឍន៍កសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ជនបទសម្រាប់ជួយលើកកម្ពស់ជីវភាពរស់នៅក្នុង តំបន់ជនបទ និងកាត់បន្ថយភាពក្រីក្រ នៅតែជាអាទិភាពចំបង ។ បន្ថែមលើនេះ ការជំរុញគំនិតផ្តួចផ្តើមស្តីពី "ភូមិមួយ ផលិតផលមួយ" បានទទួលអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ តាមការលើកទឹកចិត្តដល់សហគ្រិន ភាព ពិពិធកម្មកសិកម្ម និងស្វ័យទំនុកចិត្តនៅតំបន់ជនបទ ។

### ៣.៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ)

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ឆ្នាំ២០០៦-២០១០ បានរៀបចំឡើងក្នុងឆ្នាំ២០០៥ ហើយ ការអនុវត្តបានចាប់ផ្តើមក្នុងឆ្នាំ២០០៦ ។ ផយអជ គឺជាវិធីសាស្ត្របង្កើតផែនការថ្មី និងពេញលេញ ដោយផ្តោតលើ គោលដៅ និងសកម្មភាពយុទ្ធសាស្ត្រ និងសង្កត់ធ្ងន់លើលទ្ធផលសម្រេចបាន ជាជាងគ្រាន់តែផ្តោតលើធាតុចូល សកម្មភាព និងដំណើរការនានា ដូចក្នុងដំណើរការពីមុន ។ គោលដៅ និងយុទ្ធសាស្ត្រអាទិភាពនៃ ផយអជ គឺភាពឆាប់រហ័សនៃ ការកាត់បន្ថយភាពក្រីក្រ និងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រចាំសហសវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចផ្សេងៗដែលមានអត្ថប្រយោជន៍ចំពោះពលរដ្ឋកម្ពុជា ។ ផយអជ បានរៀបចំឡើងទៅតាមវិស័យ ពុំមែនតាម

ក្រសួងឬស្ថាប័នឡើយ ហើយគោលដៅលំអិត និងគោលដៅបន្ទាប់ទៀតសម្រាប់វិស័យនីមួយៗនឹងត្រូវរៀបចំឡើងដោយក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះការអនុវត្តន៍គោលនយោបាយ និងការតាមដានវិស័យនីមួយៗ ។

អាស្រ័យហេតុនេះ ផយអជ គឺជាឧបករណ៍ដែលមានលក្ខណៈអនុវត្តជាក់ស្តែង ផ្តោតលើលទ្ធផល និងផ្តល់ផែនទីចង្អុលផ្លូវ ព្រមទាំងគោលការណ៍ណែនាំផ្សេងៗ ដើម្បីនាំកម្ពុជាពីស្ថានភាពក្នុងឆ្នាំ២០០៦ ឲ្យឈានដល់គោលដៅអាទិភាពកម្រិតខ្ពស់និងជាក់លាក់របស់ជាតិក្នុងឆ្នាំ២០១០ ។ ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មដ៏សំខាន់ (ដែលយកតាមទស្សនទាននៃយុទ្ធសាស្ត្រចតុកោណ) បានកំណត់នូវក្របខ័ណ្ឌសម្រាប់ ការកែលំអ និងពិពិធកម្មវិស័យកសិកម្ម (រួមមាន អាហារូបត្ថម្ភ និងការអភិវឌ្ឍជនបទ) កំណែទម្រង់ដីធ្លី ការបោសសំអាតមីន ព្រមទាំងកំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ ។ ជាកិច្ចឆ្លើយតប ផយអជ បានគូសបញ្ជាក់ពី តម្រូវការកសាងផែនការយុទ្ធសាស្ត្រពិស្តារដោយក្រសួងស្ថាប័នពាក់ព័ន្ធនានា ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម យុទ្ធសាស្ត្រសម្រាប់កសិកម្មនិងទឹក សន្តិសុខស្បៀងក្នុងគ្រួសារនិងអាហារូបត្ថម្ភ ព្រមទាំងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រនូវធនធានទឹក ត្រូវបានបង្កើតឡើងដើម្បីជម្រុញកំណើនកសិកម្ម សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រជាដើម (សូមអានផ្នែក ៣.៧) ។ ផយអជ ឆ្នាំ២០០៩-២០១៣ ត្រូវបានធ្វើបច្ចុប្បន្នភាពផ្អែកលើ ផយអជ ២០០៦-២០១០ ដោយគ្មានការកែប្រែធំដុំឡើយ ហើយគោលដៅយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនានានៃផែនការលើកមុន ត្រូវបានអនុម័តក្នុងកិច្ចប្រឹងប្រែងដើម្បីឈានដល់គោលដៅអភិវឌ្ឍន៍ប្រចាំសហសវត្សរ៍កម្ពុជា និងអនុវត្តចក្ខុវិស័យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។

## ៣.៦ ឯកសារគោលនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តឯកសារគោលនយោបាយ ស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ។ គោលនយោបាយនេះ គឺជាការកែសម្រួលពីវិធានការគោលនយោបាយយុទ្ធសាស្ត្រចំបងដើម្បីជម្រុញការអភិវឌ្ឍកសិកម្ម ដោយសង្កត់ធ្ងន់លើល្បឿន និងទ្រង់ទ្រាយថ្មីក្នុងការពង្រឹងបន្ថែមនូវមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច ពន្លឿនការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ ដើម្បីអនុវត្តចក្ខុវិស័យក្នុងការអភិវឌ្ឍកសិកម្ម រាជរដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រ ៣ផ្នែក គឺការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម (ពីកសិកម្មចិញ្ចឹមក្រពះទៅជាកសិកម្មពាណិជ្ជកម្ម) តាមរយៈការអនុវត្តវិធានការដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក៖ ១) ការកសាង និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព ថាមពលអគ្គិសនី បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) ២) ការលើកកម្ពស់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងកាតផ្គត់ផ្គង់ធាតុចូលកសិកម្ម ៣) កំណែទម្រង់ការគ្រប់គ្រងដីធ្លី ៤) ហិរញ្ញវត្ថុ ៥) ទីផ្សារ ៦) អង្គការកសិករ និង ៧) ការកសាងស្ថាប័ន និងការសម្របសម្រួល ។

ដើម្បីសម្រេចបានចក្ខុវិស័យនៃការប្រែក្លាយប្រទេសកម្ពុជា ជា "ជង្រុកស្រូវ" និងជាប្រទេសនាំមុខក្នុងការនាំអង្ករចេញទៅកាន់ទីផ្សារពិភពលោក រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដៅដើម្បី៖ ១) សម្រេចបានផលស្រូវលើសពីតម្រូវការក្នុងស្រុកច្រើនជាង ៤លានតោន និងនាំអង្ករចេញយ៉ាងតិច ១លានតោន ២) ធានាការទទួលស្គាល់អង្ករជាអន្តរជាតិ ។ ដើម្បីសម្រេចគោលដៅទាំងនេះ រាជរដ្ឋាភិបាលនឹងគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ វិធានការគោលនយោបាយសំខាន់ៗ ដោយវិធានការនីមួយៗអាចទទួលបានជោគជ័យឆាប់រហ័ស និងមានផលចំណេញក្នុងរយៈពេលមធ្យម និងវែង គឺ៖ i) ផលិតកម្មស្រូវ ii) ការប្រមូលផលស្រូវ និងការកែច្នៃ iii) ការងារផ្គត់ផ្គង់ និង iv) ទីផ្សារ ។

តារាង ៤៖ ចំណាយចរន្តរបស់រដ្ឋាភិបាលចំពោះវិស័យមួយចំនួន (គិតជាពាន់លានរៀល)

| ចំណាយតាមវិស័យ | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009ខ | 2010ខ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណាយសរុប (ចរន្ត) | 1,109 | 1,216 | 1,416 | 1,575 | 1,758 | 1,746 | 1,968 | 2,355 | 2,974 | 3,636 | 4,361 | 5,029 |
| ការពារជាតិ និងសន្តិសុខ | 47.5 | 455.0 | 417.3 | 406.8 | 411.0 | 422.8 | 451.2 | 520.2 | 615.9 | 789.9 | 895.9 | 1150.5 |
| សុខាភិបាល | 76.3 | 121.0 | 129.7 | 164.4 | 173.0 | 192.1 | 224.6 | 260.8 | 343.3 | 372.9 | 503.8 | 600.1 |
| អប់រំ | 166.8 | 183.2 | 209.2 | 289.7 | 300.5 | 325.9 | 350.8 | 445.6 | 491.4 | 506.1 | 742.5 | 824.9 |
| កសិកម្ម | 24.0 | 26.0 | 30.5 | 39.7 | 39.0 | 38.6 | 47.1 | 55.9 | 57.7 | 63.2 | 77.0 | 87.5 |
| អភិវឌ្ឍន៍ជនបទ | 12.0 | 7.5 | 12.4 | 18.4 | 16.9 | 16.6 | 22.1 | 30.0 | 34.8 | 48.0 | 63.8 | 83.2 |
| *អត្រាភាគរយនៃថវិកាកសិកម្ម* | | | | | | | | | | | | |
| ភាគរយនៃថវិកាកសិកម្ម ក្នុងចំណាយសរុប | 2.16 | 2.30 | 2.15 | 2.52 | 2.22 | 2.21 | 2.39 | 2.37 | 1.94 | 1.74 | 1.77 | 1.74 |
| ចំណែកនៅក្នុង អត្រាភាគរយនៃ ផសស កសិកម្ម | 0.47 | 0.51 | 0.58 | 0.78 | 0.69 | 0.69 | 0.73 | 0.82 | 0.80 | 0.83 | - | - |

ប្រភព៖ សូចនាករសំខាន់ៗសំរាប់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០០៩ ADB (www.adb.org/statistics/cambodia)
ខ៖ ច្បាប់ជាតិស្តីពីថវិកាចំណាយឆ្នាំ២០០៩ និង ២០១០

យោងតាមវិធានការគោលនយោបាយទាំងនេះ ដែលសំដៅដោះស្រាយឧបសគ្គផ្សេងៗតាំងពីការផលិតរហូតដល់ការសម្របសម្រួលដែលគ្មានលក្ខណៈជាប្រព័ន្ធ នៅតាមក្រសួងឬស្ថាប័នរាជរដ្ឋាភិបាលនានាក្នុងការនាំចេញស្រូវ និងការធ្វើពាណិជ្ជកម្មស្រូវ គោលនយោបាយផលិតផលស្រូវនេះឆ្លុះបញ្ចាំងពីការគិតគូរដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល និងការយល់ដឹងច្បាស់លាស់ពីខ្សែសង្វាក់ក្នុងផលិតកម្មស្រូវ ។ គោលនយោបាយនេះក៏គូសបញ្ជាក់ផងដែរពីមុខងារ និងការសម្របសម្រួលអន្តរក្រសួងរវាងបណ្តាក្រសួង ស្ថាប័ន ដែលមានតួនាទីសំខាន់ក្នុងការពន្លឿនដំណើរការនាំចេញ និងលើកទឹកចិត្តវិនិយោគឯកជនក្នុងវិស័យស្រូវ ដើម្បីសម្រេចគោលដៅសហសវត្សរ៍របស់កម្ពុជាក្នុងការនាំចេញស្រូវយ៉ាងតិច ១លានតោនក្នុងឆ្នាំ២០១៥ ។ ទោះបីជារាជរដ្ឋាភិបាលមានគោលនយោបាយល្អនៅថ្នាក់ជាតិក្តី ប៉ុន្តែវិធីដាក់អនុវត្តគោលនយោបាយជាក់ស្តែង គឺជាបញ្ហាមួយសម្រាប់ការពិភាក្សា ឧទាហរណ៍ រាជរដ្ឋាភិបាលមានចក្ខុវិស័យល្អក្នុងការលើកកម្ពស់វិស័យកសិកម្មដើម្បីពង្រឹងមូលដ្ឋានគ្រឹះ និងពិពិធកម្មនៃកំណើនសេដ្ឋកិច្ច តាំងពីការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ មកម្លេះ ប៉ុន្តែការបែងចែកថវិការបស់រាជរដ្ឋាភិបាលដល់វិស័យនេះ នៅមានកម្រិតទាបជាង ២% នៃថវិកាសរុប ឬទាបជាង ១% នៃ ផសស កសិកម្ម ក្នុងមួយឆ្នាំ (តារាង ៤) ។ ដូច្នេះគេគួរពិភាក្សាអំពីវិធីបង្កើនវិភាជន៍ថវិកាជាតិក្នុងវិស័យកសិកម្មដែលរួមចំណែកបានដល់ ២៧,៥% នៃ ផសស នៅឆ្នាំ២០០៨ នេះ។

## ៣.៧ គោលនយោបាយជាតិស្តីពីធនធានទឹក

រាជរដ្ឋាភិបាល បានបង្កើតគោលនយោបាយជាតិ ស្តីពីធនធានទឹកជាតិសម្រាប់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៤ ។ ដើម្បីធានាឱ្យមានការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព ភាពត្រឹមត្រូវ និងសមធម៌ គោលនយោបាយនេះមានគោលដៅ និងគោលបំណងធំទូលាយ ដើម្បី៖ ១) ផ្តល់លទ្ធភាពឲ្យគ្រប់គ្នាទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព ក្នុងចំនួនគ្រប់គ្រាន់ និងក្នុងតម្លៃសមរម្យអាចប្រើបាន ២) ផ្តល់ទឹកគ្រប់គ្រាន់សម្រាប់សកម្មភាពកសិកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច ៣) ដោះស្រាយ និងកាត់បន្ថយរាល់ការគំរាមកំហែងដែលអាចធ្វើឲ្យបាត់បង់ជីវិត និងបង្កគ្រោះថ្នាក់ដល់ការចិញ្ចឹមជីវិត និងដែលបណ្តាលមកពីទឹក និង ៤) គ្រប់គ្រងបរិស្ថានធនធានទឹកដើម្បីបញ្ចៀសការបំពុលទឹក ។ គោលនយោបាយនេះ ក៏លើកឡើងផងដែរអំពីសារៈសំខាន់នៃទឹកក្នុងការលើកកម្ពស់វិស័យកសិកម្ម ។ ដើម្បីធានាការផ្តល់ទឹកឱ្យបានគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ផលិតកម្ម និងផលិតភាពកសិកម្ម រាជរដ្ឋាភិបាលបានកំណត់

គោលនយោបាយអាទិភាពដូចតទៅ៖ ១) ផ្តល់ទឹកគ្រប់គ្រាន់ដល់កសិករក្នុងកម្រិតធនធានទឹក និងបច្ចេកវិទ្យាដែលអាចប្រើប្រាស់បាន ២) ជម្រុញការស្តារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ស្រោចស្រព រំដោះទឹក និងគ្រប់គ្រងទឹកជំនន់ ដើម្បីផ្តល់ទឹកគ្រប់គ្រាន់ដល់កសិកម្ម និងកាត់បន្ថយផលអវិជ្ជមានពីការមានទឹកច្រើនពេក ៣) ជម្រុញការអភិវឌ្ឍ និងការផ្សព្វផ្សាយបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្រប ក្នុងតំបន់កសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង ៤) ពង្រឹងនិងពង្រីកការចូលរួមក្នុងសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីគ្រប់គ្រង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព និង ៥) កាត់បន្ថយផលប៉ះពាល់សារធាតុគីមីកសិកម្មមកលើធនធានទឹកតាមរយៈការលើកទឹកចិត្តប្រជាពលរដ្ឋឲ្យធ្វើពិពិធកម្មផលិតកម្មកសិកម្ម ។

## ៣.៨ គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ

### *៣.៨.១ យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម បានរួមគ្នាបង្កើតយុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក (SAW) ឆ្នាំ២០០៦-២០១០ ដែលបានបញ្ចប់ក្នុងឆ្នាំ២០០៧ ។ នេះជាយុទ្ធសាស្ត្រលំអិតតាមវិស័យ ដែល ផយអជ ឆ្នាំ២០០៦-២០១០ បានតម្រូវឲ្យបង្កើត ។ គោលដៅយុទ្ធសាស្ត្រនេះគឺ "រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍធនធានទឹក" ។ ដើម្បីសម្រេចបានគោលដៅនេះ ត្រូវផ្តោតជាសំខាន់លើការ ១) បង្កើនសន្តិសុខស្បៀង និងប្រាក់ចំណូលក្នុងសហគមន៍ និងគ្រួសារនៅតំបន់ជនបទ ២) កាត់បន្ថយភាពងាយរងគ្រោះក្នុងសហគមន៍ និងគ្រួសារនៅតំបន់ជនបទ ៣) បង្កើនផលិតផលកសិកម្មលើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក ដើម្បីកែច្នៃ និងនាំចេញ និង ៤) គ្រប់គ្រង និងអភិវឌ្ឍប្រកបដោយនិរន្តរភាពលើដី និងធនធានទឹករបស់ប្រទេសជាតិ ។

SAW រួមមានកម្មវិធីធំៗចំនួន ៥៖ ១) ការកសាងសមត្ថភាពស្ថាប័ន និងកម្មវិធីគាំទ្រការគ្រប់គ្រងវិស័យកសិកម្ម និងធនធានទឹក ២) កម្មវិធីគាំទ្រសន្តិសុខស្បៀង ៣) កម្មវិធីគាំទ្រកសិកម្ម និង កសិពាណិជ្ជកម្ម (ខ្សែសង្វាក់តម្លៃ ៤) កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រព និងដីធ្លី និង ៥) កម្មវិធីស្រាវជ្រាវកសិកម្មនិងធនធានទឹក និង កម្មវិធីអប់រំនិងផ្សព្វផ្សាយកសិកម្ម។កម្មវិធីទាំងនេះ SAWកំពុងព្យាយាមសម្រេចតាមចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ពោលគឺ"ធានាឱ្យមានស្បៀងអាហារនិងទឹកគ្រប់គ្រាន់និងមានសុវត្ថិភាពសម្រាប់ប្រជាជន កាត់បន្ថភាពក្រីក្រនិងរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច ទន្ទឹមគ្នានឹងការធានានិរន្តរភាពនៃធនធានធម្មជាតិ" ។ SAW ២០០៩-២០១៣ បានធ្វើបច្ចុប្បន្នភាព ហើយលទ្ធផលគ្រោងទុកនឹងត្រូវពិនិត្យមើលឡើងវិញក្នុងឆ្នាំ២០១៣ ស្របតាម ផយអជ ឆ្នាំ២០០៩-២០១៣ ។ កម្មវិធីនិងក្របខ័ណ្ឌទាំងអស់ ព្រមទាំងទស្សនទាននៃ ផយអជ បានយកលំនាំតាមឯកសារ SAW ឆ្នាំ២០០៦-២០១០ ។

### *៣.៨.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០*

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០០៦-២០១០ បានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែតុលា ឆ្នាំ២០០៥ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ ផយអជ ឆ្នាំ២០០៦-២០១០ ដោយយកលំនាំតាមទស្សនទានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ។ យុទ្ធសាស្ត្រនេះត្រូវបានប្រើប្រាស់ជាធាតុចូលចំបងសម្រាប់ SAW ឆ្នាំ២០០៨-២០១០ ។ គោលបំណងសំខាន់នៃវិស័យកសិកម្មគឺ "ធានាឱ្យមានសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល បង្កើតការងារ និងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជនទាំងអស់ តាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធកម្ម ព្រមទាំងពាណិជ្ជភាវូបនីយម្មវិស័យកសិកម្ម ដោយមានការការពារបរិស្ថាន និងមានសុវត្ថិភាពស្បៀងត្រឹមត្រូវ" ។ ដើម្បីសម្រេចគោលដៅ យុទ្ធសាស្ត្រនេះបានកំណត់កម្មវិធីអាទិភាពចំនួន ៧៖ ១) សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម ២) ការលើកកម្ពស់ និងពង្រឹងការស្រាវជ្រាវកសិកម្ម និងប្រព័ន្ធផ្សព្វផ្សាយ ៣) ច្រកចូលទៅកាន់ទីផ្សារចំពោះផលិតផលកសិកម្ម ៤) ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ន និងច្បាប់ ៥) កំណែទម្រង់ដីធ្លី

ដែលរួមមាន ការកាន់កាប់ដីធ្លី ការអភិវឌ្ឍទីផ្សារដីធ្លី លទ្ធភាពទទួលបានដីធ្លី និងលទ្ធភាពមានដីប្រើប្រាស់ ៦) កំណែទម្រង់ជលផល ដើម្បីមានលទ្ធភាពនេសាទប្រកបដោយនិរន្តរភាព និង ៧) កំណែទម្រង់ព្រៃឈើ តាមរយៈការលើកកម្ពស់ការអភិរក្ស និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងធានាការគ្រប់គ្រងបានកាត់តែល្អលើតំបន់ការពារ ។ កម្មវិធីពីទី១ ដល់ ទី៤ ចំពោះផែនការយុទ្ធសាស្ត្រនេះ ត្រូវបានដាក់បញ្ចូលក្នុង SAW ២០០៦-២០១០ ចំណែកឯកម្មវិធីកំណែទម្រង់ ៣ ចុងក្រោយ ត្រូវបានអនុវត្តដោយផ្ទាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

*៣.៨.៣ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ស្តីពីធនធានទឹក និងឧតុនិយម ឆ្នាំ២០០៩-២០១៣*

ដូចក្រសួងសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែរ ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់ ផយអជ ។ ផែនការនេះមានគោលដៅ បង្ហាញពីគោលបំណង និងសកម្មភាពរបស់ក្រសួងធនធានទឹក និងឧតុនិយម ដែលត្រូវសម្រេចឲ្យបានក្នុងឆ្នាំ២០១៣ ។ គោលដៅសំខាន់បំផុតរបស់ក្រសួងធនធានទឹក និងឧតុនិយម ដែលរួមចំណែកក្នុងការអភិវឌ្ឍកសិកម្ម គឺ ការបង្កើនសមត្ថភាពប្រព័ន្ធស្រោចស្រព ១% ស្មើនឹង ២៥.០០០ហ.តក្នុងមួយឆ្នាំ ព្រមទាំងពង្រីកផ្ទៃដីស្រោចស្រពឲ្យដល់ ១,២៤លានហ.ត នៅត្រឹមឆ្នាំ២០១៣ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ ត្រូវបានប្រើប្រាស់ដើម្បីធ្វើបច្ចុប្បន្នភាព SAW ២០០៩-២០១៣ ព្រមទាំងផ្តល់ធាតុចូលសម្រាប់ការធ្វើបច្ចុប្បន្នភាព ផយអជ ឆ្នាំ២០០៩-២០១៣ ។

*៣.៨.៤ គោលនយោបាយកសិកម្មពាក់ព័ន្ធដទៃទៀត និងគោលនយោបាយសន្តិសុខស្បៀង*

*សារាចរលេខ ០៣ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា (រជក ២០០៣)*

រាជរដ្ឋាភិបាលបានអនុម័ត និងផ្សព្វផ្សាយសារាចរស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៣ ។ គោលបំណងនៃសារាចរនេះ គឺដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភកម្ពុជាប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយភាពក្រីក្រ ។ ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលបានផ្តល់អនុសាសន៍ដល់ក្រសួងពាក់ព័ន្ធ នាយកដ្ឋានពាក់ព័ន្ធ និងភាគីពាក់ព័ន្ធនានាឲ្យ៖ ១) ធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់តំបន់រាំងស្ងួត និងផ្តល់យន្តការដោះស្រាយសមស្រប និងប្រកបដោយនិរន្តរភាព លើការផ្តល់ និងការបែងចែកស្រូវពូជ ពង្រឹងប្រព័ន្ធស្រោចស្រព ព្រមទាំងផ្តល់ម៉ាស៊ីនបូមទឹក ថ្នាំកសិកម្ម និងសម្ភារៈកសិកម្មដទៃទៀតដល់កសិករ ២) រៀបចំយន្តការដើម្បីលើកទឹកចិត្តដល់ សួនបន្លែគ្រួសារ ពិពិធកម្មដំណាំ និង ការចិញ្ចឹមសត្វដើម្បីបម្រើការងារកសិកម្ម និងបានប្រាក់ចំណូលបន្ថែម ៣) ផ្តោតលើការស្តារ និងការសាងសង់ប្រព័ន្ធស្រោចស្រពខ្នាតធំ និងខ្នាតតូចសម្រាប់សហគមន៍ និងគ្រួសារ តាមរយៈការស្នើសុំការគាំទ្រពីអង្គការនៅថ្នាក់ជាតិ និងអន្តរជាតិ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្មនិងជនបទ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួល ការអនុវត្តគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

*សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគោលនយោបាយជាតិក្នុងវិស័យជលផល*

រដ្ឋាភិបាលបានផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ស្តីពី គោលនយោបាយជាតិចំពោះវិស័យជលផល ក្នុងខែមិថុនា ឆ្នាំ២០០៥ នៅដំណាក់កាលចុងក្រោយនៃ SEDP-II ហើយ ផយអជ បានចែងពីគោលនយោបាយក្នុងវិស័យជលផលនេះ រួមបញ្ចូលទាំងកំណែទម្រង់ជលផលផងដែរ ។ ក្រសួងកសិកម្ម បានបន្តរៀបចំគោលនយោបាយជាតិស្តីពីវិស័យជលផល និងច្បាប់ជលផល ក្នុងឆ្នាំ២០០៦ ហើយបានអនុម័តក្របខ័ណ្ឌគោលនយោបាយនេះដែលមានចក្ខុវិស័យ "ការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកដល់ការធានាសន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងវិបុលភាពរបស់ប្រទេសជាតិ" ។

ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានផ្តល់អនុសាសន៍គោលនយោបាយធំៗ ៧៖ ១) ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល ២) ការគ្រប់គ្រងសហគមន៍នេសាទ និងនេសាទគ្រួសារ ៣) ការគ្រប់គ្រង និងអភិវឌ្ឍន៍

វារីវប្បកម្ម ៤) ការគ្រប់គ្រង និងអភិវឌ្ឍការកែច្នៃត្រី ៥) ការអភិរក្សធនធានជលផល ៦) ការអភិវឌ្ឍស្ថាប័នជលផល និង ហេដ្ឋារចនាសម្ព័ន្ធ និង ៧) ថវិកា និងហេដ្ឋារចនាសម្ព័ន្ធជលផល ។

*កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងលក្ខណៈគ្រួសារ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៧-២០១១*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងលក្ខណៈគ្រួសារ និង ការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៧-២០១១ ។ កម្មវិធីនេះ បង្កើតបានជាផ្នែកមួយនៃការអនុវត្ត ផយអជ ជាពិសេស មានគោលដៅ "កាត់បន្ថយភាពក្រីក្រ លុបបំបាត់ភាពខុសគ្នា និងកាត់បន្ថយគម្លាតរវាងតំបន់ ក៏ដូចជារវាងអ្នកមាន និងអ្នកក្រ" ។ ការអនុវត្តកម្មវិធីនេះនឹងរួមចំណែកយ៉ាងច្រើន ព្រមទាំងរួមចំណែកដោយផ្ទាល់ ដល់ការអនុវត្តគោលដៅ អភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាទី១ ពោលគឺ ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន និង គោលដៅក្នុងឆ្នាំ២០១៥ ។ កម្មវិធីនេះមានគោលបំណង លើកកម្ពស់សន្តិសុខស្បៀងសម្រាប់ប្រជាជនកម្ពុជាក្រីក្របំផុតប្រមាណជា ២លាននាក់ ។ ដើម្បីសម្រេចគោលបំណង កម្មវិធីនេះផ្តោតការយកចិត្តទុកដាក់លើ៖ ១) បង្កើន និងកែលំអការទទួលទានអាហារដល់ ជនមានអសន្តិសុខស្បៀង ២) លើកកម្ពស់សុខភាពមូលដ្ឋានដល់ជនមានអសន្តិសុខស្បៀង និងប្រជាជនងាយរងគ្រោះ ៣) ពង្រឹងសំណាញ់សុវត្ថិភាព សន្តិសុខស្បៀង និងពង្រឹងអង្គការសហគមន៍នានា ៤) ពង្រឹងស្ត្រីមានអសន្តិសុខស្បៀង និង ៥) លើកកម្ពស់គោលនយោបាយស្តីពីសន្តិសុខស្បៀង ។ កម្មវិធីនេះ ត្រូវបានសម្របសម្រួលនៅថ្នាក់ជាតិ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងសមាជិកសហគមន៍នានា) ។ កម្មវិធីនេះ ដើរតួជាក្របខ័ណ្ឌមួយដ៏ មានប្រយោជន៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលកំពុងអនុវត្តគម្រោងក្នុងប្រទេសកម្ពុជាដូចជា LWF, CARE, CONCERN, GTZ, IDE, GRET ។ល។

*ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាឆ្នាំ២០០៨-២០១២*

ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (SFFSN) ២០០៨-២០១២ គឺជាឯកសារមួយ ផ្តោតការយកចិត្តទុកដាក់លើបញ្ហាពាក់ព័ន្ធដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ។ ក្របខ័ណ្ឌនេះ បានបង្កើតឡើងដោយ CARD ដោយមានការពិគ្រោះយោបល់ពី TWG-FSN ក្នុងឆ្នាំ២០០៧ ។ ឯកសារយោង ជាយុទ្ធសាស្ត្រនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌអាទិភាពថ្នាក់ជាតិ ក្នុងយុទ្ធសាស្ត្រចតុកោណ ផយអជ ២០០៦-២០១០ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ស្តីពីការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ។ គោលដៅរបស់ SFFSN គឺ "ក្នុងឆ្នាំ២០១២ ពលរដ្ឋក្រីក្រកម្ពុជាដែលមានអសន្តិសុខស្បៀង នឹងមានលទ្ធភាពផ្នែក រូបវន្ត និងសេដ្ឋកិច្ចកាន់តែប្រសើរឡើង ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាព និង មានជីវជាតិល្អ ដើម្បីឆ្លើយតបនឹងតម្រូវការទទួលទានរបស់ពួកគេ និងស្របទៅតាមឯកសារណែនាំស្តីពីស្បៀងអាហារ សម្រាប់ការទ្រទ្រង់ជីវិតរស់នៅ និងមានសុខភាពល្អ" ។ ក្នុងចំណោមគោលបំណងយុទ្ធសាស្ត្រមូលដ្ឋានធំទូលាយទាំង៥ និងសកម្មភាពអាទិភាពសំដៅសម្រេចគោលដៅនេះ ផែនការយុទ្ធសាស្ត្រទាក់ទងនឹងការអភិវឌ្ឍន៍កសិកម្ម គឺដើម្បីឲ្យ "គ្រួសារអសន្តិសុខស្បៀងបង្កើនស្បៀងហូប អំពីផលិតកម្មកសិកម្ម និងបសុសត្វផ្ទាល់របស់ខ្លួន និងពីធនធានព្រៃឈើ និងជលផលដែលជាទ្រព្យរួម" ។ អាទិភាពសកម្មភាពនេះផ្តោតលើ ៤ផ្នែក៖ ១) ការលើកកម្ពស់ផលិតភាព និង ពិពិធកម្មកសិកម្ម ២) ការបង្កើនការគ្រប់គ្រងធនធានទឹក និងការស្រោចស្រព ៣) ការលើកកម្ពស់កំណែទម្រង់ជលផល និង ៤) ការលើកកម្ពស់កំណែទម្រង់ព្រៃឈើ ។ ទោះជាយ៉ាងណាក្តី ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះមិនបានបញ្ជាក់ច្បាស់ពី វិធីរៀបចំយុទ្ធសាស្ត្រតាមវិស័យនានាដែលអាចអនុវត្ត និងសម្របសម្រួលបាននោះទេ ។ សកម្មភាពអាទិភាពដូចបញ្ជាក់ នៅខាងលើ បានដាក់បញ្ចូលក្នុង SAW ២០០៦-២០១០ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម ២០០៦-២០១០ និង កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងលក្ខណៈគ្រួសារ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៧-២០១១ នៃក្របខ័ណ្ឌ អភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ លើសពីនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្របានរៀបចំឡើងក្រោយ

ការដាក់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រខាងលើ និងផ្តោតជាពិសេសលើការលើកកម្ពស់ការអភិវឌ្ឍន៍កសិកម្ម ការលើកកម្ពស់សន្តិសុខស្បៀងនិងការកាត់បន្ថយភាពក្រីក្រតាមរយៈការទទួលយកទស្សនាទានដូចគ្នានៃឯកសារយុទ្ធសាស្ត្រចតុកោណ ផយអជ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅសហសវត្សរ៍កម្ពុជា ។ យុទ្ធសាស្ត្រនេះ ហាក់ដូចជាខ្វះខ្វាយធនធាន និងពេលវេលាលើស្ថាប័នរបស់រដ្ឋាភិបាលនានា ដែលត្រូវធ្វើការងារលើក្របខ័ណ្ឌគោលនយោបាយត្រួតជាន់គ្នា ។

*គោលនយោបាយយែនឌ័រ និងយុទ្ធសាស្ត្រ ក្នុងវិស័យកសិកម្ម*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលនយោបាយយែនឌ័រលើវិស័យកសិកម្មក្នុងឆ្នាំ២០០៦ ស្របតាម ផយអជ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ។ សេចក្តីថ្លែងការណ៍គោលនយោបាយគឺ "ការលើកកម្ពស់សមភាពយែនឌ័រក្នុងវិស័យកសិកម្ម តាមរយៈកិច្ចសហប្រតិបត្តិការសកម្មទាំងស្ត្រី និងបុរស ដើម្បីទទួលបានឱកាសរួមចំណែក និងទទួលអត្ថប្រយោជន៍ស្មើគ្នាពីសកម្មភាពអនុវិស័យនានាក្នុងវិស័យកសិកម្ម" ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

គោលនយោបាយយែនឌ័រលើកឡើងពីការបញ្ជ្រាបយែនឌ័រជាមូលដ្ឋាន និងវិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងវិស័យកសិកម្ម និងការសម្របសម្រួល ។ ដើម្បីឆ្លើយតបនឹងសេចក្តីថ្លែងការណ៍គោលនយោបាយខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រមួយចំនួនដែលត្រូវសម្រេចក្នុងឆ្នាំ២០១០៖ ១) បង្កើនការយល់ដឹងអំពីយែនឌ័រដល់បុគ្គលិកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ជាន់ថ្នាក់ក្នុងវិស័យកសិកម្ម ២) ដាក់បញ្ចូលការវិភាគយែនឌ័រ និងគោលដៅនិងទិន្នន័យដែលបែងចែកតាមភេទ ទៅក្នុងផែនការក្នុងវិស័យកសិកម្ម ៣) បង្កើនឱកាសគ្រប់គ្រង និងចំនួនស្ត្រីដែលមានជំនាញ និងគុណភាពគ្រប់គ្រាន់ សម្រាប់មុខងារដឹកនាំ ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ៤) បង្កើនសមត្ថភាពស្ត្រីជនបទក្នុងការទទួលបាន និងគ្រប់គ្រងធនធាន និងសេវាកសិកម្មនានា ។

*គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីជម្រុញការវិនិយោគសម្រាប់ការអភិវឌ្ឍកសិកម្ម*

ច្បាប់ស្តីពីវិនិយោគ (ថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤) វិសោធនកម្មច្បាប់ស្តីពីវិនិយោគ (ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៣) អនុក្រឹត្យស្តីពីនិក្ខេប និងអនុបយោគសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧) និងព្រះរាជក្រឹត្យ នរស/រកត/០៦០៩/០០៩ (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩) បានផ្តល់កត្តាលើកទឹកចិត្តដល់ការអភិវឌ្ឍកសិកម្មក្នុងប្រទេសកម្ពុជា ដែលរួមមាន៖ ១) អត្រាពន្ធគយស្មើសូន្យចំពោះការនាំចូលសម្ភារៈកសិកម្ម (គ្រាប់ពូជ ជី ថ្នាំកសិកម្ម និងបរិក្ខារកសិកម្ម) ២) ការលើកលែងពន្ធលើប្រាក់ចំណេញ ចំពោះគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មសម្រាប់រយៈពេល ៩ឆ្នាំ (រយៈពេលជម្រុញ ៣ឆ្នាំ រយៈពេលអនុគ្រោះ ៣ឆ្នាំ និងរយៈពេលអាទិភាព ៣ឆ្នាំ) ។ រដ្ឋាភិបាលកំពុងកសាងផែនការផ្តល់កត្តាលើកទឹកចិត្តដល់ការវិនិយោគលើមធ្យោបាយកែច្នៃ ការនាំចេញអង្ករ និងការស្រោចស្រព ។ អនុក្រឹត្យស្តីពីការធ្វើកសិកម្មតាមរយៈកិច្ចសន្យាកំពុងព្រាងឡើង ហើយនឹងក្លាយជាឧបករណ៍មួយសម្រាប់ទាក់ទាញវិនិយោគិនបន្ថែមឲ្យធ្វើការជាមួយកសិករធុនតូច និងរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅក្នុងតំបន់ជនបទ (ឯកសាររបស់លោកសុក ឆ្នាំ២០១០) ។

*កម្មវិធី ការបន្សាំថ្នាក់ជាតិ ស្តីពីសកម្មភាពបំរែបំរួលអាកាសធាតុ*

បំរែបំរួលអាកាសធាតុបានក្លាយជាបញ្ហាប្រឈមដ៏ពិតប្រាកដមួយ សំរាប់ប្រទេសទូទាំងពិភពលោក ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់បញ្ហានេះយ៉ាងពិតប្រាកដ និងប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងកិច្ចប្រឹងប្រែងជាសាកល ដើម្បីដោះស្រាយបំរែបំរួលអាកាសធាតុ ។ កម្មវិធីសកម្មភាពបន្សាំថ្នាក់ជាតិ (NAPA) បានបង្កើតឡើងដោយក្រសួងបរិស្ថាន

ក្នុងឆ្នាំ២០០៦ ស្របតាមអាទិភាពនានាកំណត់ដោយរាជរដ្ឋាភិបាល ។ គោលដៅរបស់ NAPA គឺផ្តល់ក្របខ័ណ្ឌមួយដើម្បីណែនាំការសម្របសម្រួល និងកម្មវិធីអនុវត្តគំនិតផ្តួចផ្តើមផ្សេងៗស្តីពីការបន្សាំដែលទាក់ទងនឹងបរិស្ថាន និងកម្មវិធីអភិវឌ្ឍន៍នានានៅកម្ពុជា ។ កម្មវិធីនេះមានគោលបំណង៖ ១) ស្វែងយល់លក្ខណៈធំៗនៃគ្រោះថ្នាក់អាកាសធាតុនៅកម្ពុជា (ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ទឹកជោរខ្លាំង ទឹកសមុទ្រហូរចូល និងជម្ងឺគ្រុនចាញ់) ២) ស្វែងយល់ពីយន្តការដោះស្រាយគ្រោះថ្នាក់អាកាសធាតុ និងបំរែបំរួលអាកាសធាតុនៅកំរិតគ្រោះថ្នាក់ ៣) ស្វែងយល់សារៈសំខាន់នៃកម្មវិធី និងការរៀបចំស្ថាប័នដើម្បីដោះស្រាយគ្រោះថ្នាក់អាកាសធាតុ និងបំរែបំរួលអាកាសធាតុ ៤) កំណត់ និងផ្តល់អាទិភាពចំពោះសកម្មភាពបន្សាំទប់ទល់គ្រោះថ្នាក់អាកាសធាតុ និងបំរែបំរួលអាកាសធាតុ ។ NAPA កម្ពុជាគាំទ្រគោលបំណងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងឯកសារ ផយអជ ២០០៦-២០១០ ដោយបញ្ជាក់អំពីតម្រូវការលើកកម្ពស់ផលិតភាពកសិកម្ម តាមរយៈការពង្រីកការស្រោចស្រព និងការគ្រប់គ្រងធនធានទឹក ដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះគ្រោះធម្មជាតិនានា ។ គោលនយោបាយតាមវិស័យជាក់លាក់ និងសកម្មភាពក្នុងការអភិវឌ្ឍកសិកម្ម សន្តិសុខស្បៀង និងការពង្រីក និងគ្រប់គ្រងការស្រោចស្រពត្រូវបានផ្តល់អាទិភាពក្នុងឯកសារ SAW ២០០៦-២០១០ និង SAW ២០០៩-២០១៣ ។ ទោះជាយ៉ាងណាក្តីមានការសិក្សាតិចតួច ដែលផ្តោតលើឥទ្ធិពលផ្នែកសេដ្ឋកិច្ចសង្គមកិច្ចនៃបំរែបំរួលអាកាសធាតុលើវិស័យកសិកម្ម និងវិធានការគោលនយោបាយដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីបំរែបំរួលអាកាសធាតុ ។

## ៤. ការស្រាវជ្រាវគោលនយោបាយមានស្រាប់ស្តីពីកសិកម្មកម្ពុជា

នៅកម្ពុជាមាន វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយសាធារណៈ និងឯករាជ្យ ជាច្រើនដែលផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម ។ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) ចំបងៗ ដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលដោះស្រាយបញ្ហាប្រឈមចំពោះការអភិវឌ្ឍន៍កសិកម្ម មានដូចខាងក្រោម៖

- CARDI : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាសំម្រាប់ការស្រាវជ្រាវដំណាំ (វិទ្យាស្ថានពាក់ កណ្តាលស្វយ័ត)
- CRRI : វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សម្រាប់ស្រាវជ្រាវកៅស៊ូ
- NAHPIC : មជ្ឈមណ្ឌលជាតិសុខភាពសត្វ និងតាមដានការផលិត សម្រាប់ការស្រាវជ្រាវបសុសត្វ និងស្ថិតនៅក្រោមនាយកដ្ឋានផលិតកម្ម និងសុខភាពសត្វ (DAHP) ។
- FWSRI : វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និងសត្វព្រៃ សម្រាប់ការស្រាវជ្រាវព្រៃឈើ និងស្ថិតនៅក្រោមរដ្ឋបាលព្រៃឈើ (FA) ។
- IFReDI : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប សម្រាប់ការស្រាវជ្រាវជលផល និងស្ថិតនៅក្រោមរដ្ឋបាលជលផល (FiA) ។

វិទ្យាស្ថានស្រាវជ្រាវទាំងនេះ ផ្តោតសំខាន់លើបច្ចេកទេសដើម្បីលើកកម្ពស់ផលិតភាព ជាជាងស្រាវជ្រាវអំពីគោលនយោបាយ[12] (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៥ខ) ។ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) គឺជា

12 ផែនការចំបងក្នុងការស្រាវជ្រាវកសិកម្មជាតិ ត្រូវបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០០៥ ។ ផែនការនេះត្រូវចំណាយពេល ១២ខែក្នុងការបញ្ចប់ តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាដោយប្រើប្រាស់វិធីសាស្ត្រ SWOT ។ ផែនការនេះ ដើរតួជាក្របខ័ណ្ឌ និងការណែនាំក្នុងប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) សម្រាប់ឆ្នាំ ២០០៦-២០១៥ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់អាទិភាពដល់វិទ្យាស្ថានចំនួន ៦ ដើម្បីធ្វើការស្រាវជ្រាវដោះស្រាយចំណុចខ្សោយនៃវិស័យនានា តាមរយៈវិធីសាស្ត្រ SWOT ដែលរួមមាន ដំណាំ បសុសត្វ ជលផល ព្រៃឈើ កៅស៊ូ និង កសិឧស្សាហកម្ម ។ NARS រួមមាន CARDI, CRRI, NAHPIC, FWSRI, IFReDI និង DAI (នាយកដ្ឋានកសិឧស្សាហកម្មសម្រាប់លើកកម្ពស់វិស័យកសិឧស្សាហកម្ម) ។

វិទ្យាស្ថានស្រាវជ្រាវធនាគារខួរក្បាលរបស់រដ្ឋាភិបាលតែមួយគត់ ដែលផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពជាច្រើននៃការស្រាវជ្រាវគោលនយោបាយ និងការបង្កើតគោលនយោបាយសម្រាប់រាជរដ្ឋាភិបាល ។ គណៈកម្មាធិការទន្លេមេគង្គ (MRC) និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ក៏បានធ្វើការស្រាវជ្រាវអំពីការគ្រប់គ្រងធនធានទឹក អភិវឌ្ឍន៍កសិកម្ម និងការចិញ្ចឹមជីវិតនៅតំបន់ជនបទដែរ ។ ទោះជាយ៉ាងណាក្តី លទ្ធភាពទទួលបានលទ្ធផលការស្រាវស្រាវសាធារណៈក្នុងក្របខ័ណ្ឌសាធារណៈ ពិតជាលំបាកយ៉ាងខ្លាំង ចំពោះវិទ្យាស្ថានស្រាវជ្រាវសាធារណៈភាគច្រើន ។

មានវិទ្យាស្ថានស្រាវជ្រាវឯករាជ្យតិចទេដែលកំពុងផ្តោតការស្រាវជ្រាវលើគោលនយោបាយនៅកម្ពុជា ។វិទ្យាស្ថានគោលនយោបាយសំខាន់ៗរួមមាន៖ CDRI-អំពីអភិបាលកិច្ច ការគ្រប់គ្រងធនធានធម្មជាតិ ទិដ្ឋភាព សេដ្ឋកិច្ច ភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍តំបន់ជនបទ និង អភិវឌ្ឍន៍សង្គម ។ មជ្ឈមណ្ឌល WorldFish-ស្រាវជ្រាវពីជលផលសំខាន់គឺនេសាទទឹកសាប វិទ្យាស្ថានរៀនសូត្រ (CBNRM-LI)-ស្តីពីការគ្រប់គ្រងធនធានធម្មជាតិនៃវិស័យព្រៃឈើ វេទិកាអង្គការមិនមែនរដ្ឋាភិបាល-ស្តីពីបញ្ហាទំនាស់ដីធ្លី វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) និងវិទ្យាស្ថានសិក្សាអភិវឌ្ឍន៍កម្ពុជា (SIDS)-ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងមិនមែនពីការស្រាវជ្រាវគោលនយោបាយកសិកម្មទេ ។

ក្រៅពីវិទ្យាស្ថានស្រាវជ្រាវសាធារណៈ និងឯករាជ្យ ដៃគូអភិវឌ្ឍន៍ដទៃទៀតក៏ចូលរួមក្នុងការស្រាវជ្រាវគោលនយោបាយផងដែរ ដោយសហការជាមួយវិទ្យាស្ថានស្រាវជ្រាវក្នុងស្រុក ឬតាមរយៈការជួលអ្នកប្រឹក្សា ។ ស្ថាប័នទាំងនេះមានធនាគារអភិវឌ្ឍន៍អាស៊ី-ស្តីពីការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀងជុំវិញបឹងទន្លេសាប AusAID/ACIAR/CAVAC-ស្តីពីការកែលំអដំណាំ និងខ្សែសង្វាក់ថ្លៃកសិកម្ម ធនាគារពិភពលោក-ស្តីពីការចិញ្ចឹមជីវិត និងភាពក្រីក្រនៅតំបន់ជនបទ (មិនផ្តោតលើការអភិវឌ្ឍន៍កសិកម្មទាំងស្រុងដូចមានបញ្ជាក់ក្នុង កម្មវិធីអាទិភាពរបស់ធនាគារពិភពលោក) FAO-ស្តីពីកសិកម្ម និងសន្តិសុខស្បៀង បសុសត្វ និង USAID-ស្តីពីការលើកកម្ពស់សហគ្រាសធុន មីក្រូ តូច និងមធ្យម ក្នុងវិស័យកសិកម្ម ។ លទ្ធផលស្រាវជ្រាវមួយចំនួន អាចទទួលបានតាមរយៈអ៊ីនធឺណិត ប៉ុន្តែលទ្ធភាពក្នុងការទទួលបានលទ្ធផលស្រាវជ្រាវមួយចំនួនគឺមានកំណត់ ជាពិសេសកម្មវិធីស្រាវជ្រាវថ្មីៗ ។

ដោយសារពេលវេលាមានកំណត់ និងការលំបាកក្នុងការទទួលបានព័ត៌មានស្តីពីការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ក្នុងក្របខ័ណ្ឌសាធារណៈ ផ្នែកនេះគ្រាន់តែពិនិត្យមើលសាឡើងវិញនូវការស្រាវជ្រាវគោលនយោបាយសំខាន់ៗដែលមានស្រាប់ ហើយនិងទំនាក់ទំនងជាក់លាក់ និងដោយផ្ទាល់ទៅនឹងការអភិវឌ្ឍកសិកម្ម ។ ការពិនិត្យមើលការស្រាវជ្រាវគោលនយោបាយសំខាន់ៗដែលមានស្រាប់សាឡើងវិញ អនុញ្ញាតឱ្យយើងកំណត់ពីចន្លោះចំណេះដឹងសម្រាប់ការស្រាវជ្រាវនាអនាគត ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម និងសន្តិសុខស្បៀង ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ (គប្បីកត់សំគាល់ថា ផ្នែកនេះគ្រាន់តែជាសេចក្តីព្រាងលើកដំបូង ហើយនឹងមានការកែលំអបន្ថែមទៀត ដោយផ្អែកលើមតិយោបល់ពីកិច្ចពិភាក្សាតុមូលកាលពីខែវិច្ឆិកា ឆ្នាំ២០១០ ព្រមទាំងលទ្ធភាពទទួលបានឯកសារស្រាវជ្រាវបន្ថែមទៀត) ។ ការស្រាវជ្រាវគោលនយោបាយបច្ចុប្បន្នស្តីពីកសិកម្មកម្ពុជាត្រូវបានចាត់ថ្នាក់ទៅតាមប្រធានបទពាក់ព័ន្ធដូចខាងក្រោម៖

## ៤.១ ការស្រាវជ្រាវស្តីពីការគ្រប់គ្រងការស្រោចស្រព និងការគ្រប់គ្រងទឹកក្នុងវិស័យកសិកម្ម

តាមរយៈការស្រាវជ្រាវដែលមានស្រាប់ស្តីពី ការស្រោចស្រពទឹកមានទំនាក់ទំនងនឹងការអភិវឌ្ឍកសិកម្ម CDRI បានពិនិត្យមើលឯកសារដែលមានស្រាប់ គួបផ្សំនឹងការស្រាវជ្រាវស្តីពីអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋសាស្ត្រនៃការគ្រប់គ្រងធនធានទឹក រួមទាំងការសិក្សាសាកល្បងមួយចំនួនទៀត ។ ការសិក្សាទាំងនេះរួមមាន៖ ការផ្តោតការស្រាវជ្រាវលើពីការគ្រប់គ្រងធនធានទឹកនៅកម្ពុជា[13] ភស្តុតាងជាក់ស្តែងស្តីពីបញ្ហាប្រឈមនៃការគ្រប់គ្រង

13 CDRI ឆ្នាំ២០០៨ ការរៀបចំការស្រាវជ្រាវស្តីពីការគ្រប់គ្រងធនធានទឹក និងអភិបាលកិច្ចនៅកម្ពុជា៖ ការពិនិត្យមើលឡើងវិញនូវ

ការស្រោចស្រពក្នុងអាងទន្លេសាប[14] អភិបាលកិច្ចមូលដ្ឋាននៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា[15] បញ្ហា ទំនាស់ និង ដំណោះស្រាយអំពីការប្រើប្រាស់ទឹកស្រោចស្រពស្រូវវស្សា និងស្រូវប្រាំង នៅភាគខាងត្បូងប្រទេសកម្ពុជា[16] និងការចូលរួមរបស់កសិករ ក្នុងសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពនៅកម្ពុជា[17] ។ សរុបមក ការសិក្សាទាំងនេះបានរកឃើញបញ្ហាអភិបាលកិច្ចចំបង គឺការដឹកនាំទន់ខ្សោយ ស្ថាប័នខ្សោយ និងកង្វះការអនុវត្តច្បាប់ ក្នុងស្ទើរគ្រប់ព្រព័ន្ធស្រោចស្រព ។ ដើម្បីទទួលបានការគ្រប់គ្រងកម្មវិធីស្រោចស្រពទឹកប្រកបដោយប្រសិទ្ធភាព ការសម្របសម្រួល រវាងកសិករដូចគ្នា រវាងកសិករ និង FWUCs និង រវាង FWUCs ដូចគ្នា គឺត្រូវតែពង្រឹង ហើយពួកអ្នកប្រើប្រាស់ត្រូវតែសហការជាមួយទីភ្នាក់ងារពាក់ព័ន្ធទាំងអស់ ។ ប្រព័ន្ធស្រោចស្រពមានស្រាប់ភាគច្រើនរចនារៀបចំមិនសមស្របទេ ជាហេតុធ្វើឱ្យខ្សត់ទឹក ។ អតុល្យភាពនៃការបែងចែកទឹករវាងសហគមន៍អ្នកប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម បានបង្កទំនាស់ជារឿយៗ ។ ជួនកាលទំនាស់កើតឡើងដោយសារការប្រកួតប្រជែងរវាងការប្រើប្រាស់ទឹកក្នុងបែបផែនខុសគ្នា ដូចជា រវាងអ្នកនេសាទ និងកសិករធ្វើស្រែ ។ ការដោះស្រាយទំនាស់ត្រូវតែសម្របសម្រួលឱ្យបានល្អរវាងសហគមន៍អ្នកប្រើប្រាស់ទឹក ជួនកាលត្រូវការអន្តរាគមន៍ពីអាជ្ញាធរខេត្ត និងអាជ្ញាធរជាតិ ។ បទពិសោធន៍ល្អរៀនសូត្របានពីការប្រើប្រាស់ទឹក និងការគ្រប់គ្រងការស្រោចស្រពប្រកបដោយជោគជ័យ គឺការចូលរួមរបស់សមាជិក FWUC ក្នុងការទូទាត់ថ្លៃស្រោចស្រព ការថែទាំ និងភាពជាម្ចាស់លើ ប្រព័ន្ធស្រោចស្រព និងការបែងចែកទឹក ។

គណៈកម្មការទន្លេមេគង្គ (MRC) និងវិទ្យាស្ថានសាធារណៈនានា ក៏បានចូលរួមក្នុងការស្រាវជ្រាវស្ដីពីការគ្រប់គ្រងទឹក និងសារៈសំខាន់របស់ទឹក ក្នុងការអភិវឌ្ឍកសិកម្មដែរ ។ ការសិក្សា MRC មួយ ស្ដីពីការលើកកម្ពស់ការស្រោចស្រពវាលស្រែនៅអាងទន្លេមេគង្គខាងក្រោម[18] បានព្យាយាមប៉ាន់ស្មានពីប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក ហើយរកឃើញថាប្រសិទ្ធភាពនៃផ្ទៃស្រោចស្រព មានត្រឹមតែ ៧២,៤% ប៉ុណ្ណោះនៅរដូវប្រាំង និង ៨៦,៣% នៅរដូវភ្លៀង ។ តួលេខទាំងនេះមិនបានដល់ប្រសិទ្ធភាពកម្រិតខ្ពស់ទេ ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធ ។ ក្រុមការងារបច្ចេកទេសស្ដីពីកសិកម្ម និងទឹក (TWGAW) បានធ្វើការពិនិត្យឡើងវិញនូវបទពិសោធន៍ស្ដីពីរបៀបធ្វើអន្តរាគមន៍ និងមេរៀនសិក្សាបានពីកម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ការស្រោចស្រពដែលមានការចូលរួម (PIMD) នៅកម្ពុជា[19] ។ លទ្ធផលការសិក្សានេះបានចូលរួមចំណែកដល់ការរៀបចំ កម្មវិធីស្រោចស្រពនៅពាក់កណ្ដាលអាណត្តិនៃ SAW ប្រកបដោយប្រសិទ្ធភាព ។ នាបច្ចុប្បន្ន CDRI ដោយមានការឧបត្ថម្ភគាំទ្រពី AusAID កំពុងធ្វើការប៉ាន់ស្មានពី ការសិក្សាផ្អែកលើការអនុវត្តជាក់ស្ដែង ស្ដីពីអត្ថប្រយោជន៍ការស្រោចស្រពទឹកក្នុងផលិតកម្មកសិកម្ម ពោលគឺការវិភាគពីចំណាយ និងអត្ថប្រយោជន៍ នៃការស្រោចស្រពទឹកនៅកម្ពុជា ជាពិសេសចំពោះដំណាំស្រូវ ។

---

ឯកសារស្រាវជ្រាវ CDRI WP 37 ។

14 CDRI ឆ្នាំ២០១០ក ភស្តុតាងជាក់ស្ដែងនៃការគ្រប់គ្រងការស្រោចស្រពក្នុងអាងទន្លេសាប៖ បញ្ហាចោទ និងបញ្ហាប្រឈម CDRI WP 48 ។

15 CDRI ឆ្នាំ២០១០ខ អភិបាលកិច្ចល្អនៅមូលដ្ឋានលើធនធានទ្រព្យរួម៖ ករណីនៃទឹកស្រោចស្រពនៅកម្ពុជា CDRI WP 47 ។

16 Vuthana T. ឆ្នាំ២០០៨ ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពនៅខេត្តតាកែវ៖ បញ្ហា ទំនាស់ និងដំណោះស្រាយ ADR 2007/08, CDRI, ភ្នំពេញ ។

17 Bandeth R. ឆ្នាំ២០១០ ការចូលរួមរបស់កសិករ និងជោគជ័យនៃប្រព័ន្ធស្រោចស្រពគ្រងគ្រងដោយកសិករ៖ ករណីសិក្សាលើសហគមន៍កសិករប្រើប្រាស់ទឹកនៅអូរត្រែង ខេត្តកំពង់ស្ពឺ ADR 2009/2010, CDRI, ភ្នំពេញ ។

18 MRC ឆ្នាំ២០០៨ ការលើកកម្ពស់ប្រសិទ្ធភាពស្រោចស្រពដីស្រែ ក្នុងអាងទន្លេមេគង្គខាងក្រោម៖ ការសង្កេតដល់កន្លែង និងការវិភាគទិន្នន័យ ដើម្បីលើកកម្ពស់ការស្រោចស្រពដីស្រែប្រកបដោយប្រសិទ្ធភាព នៅប្រព័ន្ធស្រោចស្រពកំពីងពួយ ក្នុងខេត្តបាត់ដំបង និង MRC ឆ្នាំ២០០៩ ស្ដីពី មុខងាររបស់ MRC ក្នុងការគ្រប់គ្រងកសិកម្ម និងការទឹកកសិកម្ម (ឯកសារយុទ្ធសាស្ត្រ) ។

19 TWGAW ឆ្នាំ២០០៦ ការពិនិត្យឡើងវិញនូវបទពិសោធន៍នានា៖ បែបបទអន្តរាគមន៍ លទ្ធផល និងមេរៀនបានសិក្សារបាយការណ៍ TWGAW ស្ដីពីការគ្រប់គ្រង និងអភិវឌ្ឍន៍ការស្រោចស្រពដោយមានការចូលរួម (PIMD) នៅកម្ពុជា។

ការសិក្សាទាំងអស់នេះបង្ហាញថា មានការស្រាវជ្រាវមួយចំនួនកំពុងប្រព្រឹត្តទៅលើបញ្ហាគ្រប់គ្រងការស្រោចស្រពទឹកលើផ្ទៃដី ។ ទោះជាយ៉ាងណាក្តី កម្ពុជានៅខ្វះព័ត៌មានទាក់ទងនឹងទឹកក្រោមដី ក្នុងការស្រាវជ្រាវពីការស្រោចស្រព និងផលប៉ះពាល់រយៈពេលវែង ទៅលើដីកសិកម្ម និងផលិតភាពកសិកម្មនៅកម្ពុជា ។ ទឹកក្រោមដី អាចប្រើប្រាស់ជាយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយ ផលប៉ះពាល់បំរែបំរួលអាកាសធាតុនាពេលអនាគតមកលើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងក្នុងរយៈពេលវែង ។ ដើម្បីទប់ទល់ការរាំងស្ងួត ផ្ទៃដីផលិតកម្មស្រូវមួយចំនួនបានចាប់ផ្តើមប្រើប្រាស់ទឹកក្រោមដីរាក់ៗសម្រាប់ការស្រោចស្រពទាំងនៅរដូវប្រាំង និងរដូវវស្សា ។ ការប្រើប្រាស់ទឹកក្រោមដីរាក់ៗក្នុងរយៈពេលវែង អាចមានផលប៉ះពាល់អវិជ្ជមានដល់ដីកសិកម្ម ដោយសារវាមានផ្ទុកសារធាតុកាលស្យូមកាបូណាតខ្ពស់ ($CaCO_3$) ។ បច្ចុប្បន្ន មិនទាន់មានការស្រាវជ្រាវពីអត្ថប្រយោជន៍ និងគុណវិបត្តិនៃការប្រើប្រាស់ទឹកក្រោមដីនៅកម្ពុជាទេ ។

## ៤.២ ការស្រាវជ្រាវពីពាណិជ្ជកម្មកសិកម្ម

មានការសិក្សាមួយចំនួនស្តីពីពាណិជ្ជកម្ម រវាងកម្ពុជានិងបណ្តាប្រទេសអាស៊ាន និងរវាងអាស៊ាននិងប្រទេសចិន ។ ពាណិជ្ជកម្មបសុសត្វ ដែលបានស្រាវជ្រាវដោយ CDRI ក្នុងឆ្នាំ២០០៧[20] រកឃើញថា ពាណិជ្ជកម្មឆ្លងដែនអាចជួយឱ្យថ្លៃទីផ្សារមានស្ថិរភាព និងរកទីផ្សារបានធំទូលាយថែមទៀតសម្រាប់បសុសត្វ ។ គេបានកត់សំគាល់ថា ពាណិជ្ជកម្មគោក្របីពីប្រទេសកម្ពុជាទៅថៃ និងវៀតណាម ភាគច្រើនគឺជាពាណិជ្ជកម្មក្រៅផ្លូវការ ។ ក្នុងឆ្នាំ២០០៨[21] USAID និង FAO បានសិក្សាពីពាណិជ្ជកម្មគ្មានបទបញ្ញត្តិគ្រប់គ្រងនៃការនាំចូលជ្រូកពីប្រទេសថៃ និងវៀតណាម មកកម្ពុជា ដោយបានបង្ហាញពីផលប៉ះពាល់មកលើ វិស័យចិញ្ចឹមជ្រូកនៅកម្ពុជា និងការគ្រប់គ្រងជំងឺឆ្លងដែន ។

កម្មវិធីប្រមូលផលដើមដៃ៖ ឥទ្ធិពលលើវិស័យកសិកម្មកម្ពុជា[22] គឺជាការសិក្សារបស់ CDRI មួយ ដើម្បីពិនិត្យពីអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងចិន ។ ការសិក្សារកឃើញថា កិច្ចព្រមព្រៀងនេះផ្តល់ឧត្តមភាព និងអត្ថប្រយោជន៍សេដ្ឋកិច្ចដល់ប្រទេសជាសមាជិកទាំងអស់ តាមរយៈការបង្កើនពាណិជ្ជកម្មលើផលិតផលកសិកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច និងសហប្រតិបត្តិការវិនិយោគ ។ ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍តិចតួចពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដោយសារផលិតផលកសិកម្មរបស់កម្ពុជា ដូចជាដំឡូងឈើ កៅស៊ូ ពោត និងសណ្តែកសៀង ភាគច្រើនធ្វើពាណិជ្ជកម្មជាមួយប្រទេសថៃ ឬវៀតណាម ពុំមែនធ្វើពាណិជ្ជកម្មដោយផ្ទាល់ជាមួយប្រទេសចិនទេ ។ ឯកសារស្រាវជ្រាវ ២[23][24] ទៀត ក៏បានបញ្ជាក់លើអំណះអំណាងនេះដែរ ។

ស្រូវ និងកៅស៊ូ ជាអនុវិស័យដំណាំដ៏សំខាន់នៅកម្ពុជា ហើយមានសក្តានុពលសម្រាប់ការនាំចេញទៅកាន់ទីផ្សារពិភពលោក ។ ប្រទេសកម្ពុជាក៏ជាសមាជិកមួយនៃអង្គការពាណិជ្ជកម្មពិភពលោក ប៉ុន្តែមានការស្រាវជ្រាវតិចតួចដែលបង្ហាញពីពាណិជ្ជកម្មដំណាំទាំងនេះ នៅក្នុងតំបន់ និងក្នុងទីផ្សារពិភពលោក ។ យើងបានពិនិត្យឃើញការស្រាវជ្រាវមួយចំនួន ពីការលើកកម្ពស់ការនាំចេញស្រូវរបស់កម្ពុជា ក្រោយកម្ពុជាចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក[25] ប៉ុន្តែយើងមិនរកបានឯកសារនោះទេ ដើម្បីស្វែងយល់បន្ថែមអំពីពាណិជ្ជកម្មស្រូវរបស់កម្ពុជា (សូមអានផ្នែក ៤.៤

---

20 Ballard B. & Vathana T. ឆ្នាំ២០០៧ ផលិតកម្មបសុសត្វ និងសេវាពេទ្យសត្វនៅកម្ពុជា ADR 2006/07, CDRI, ភ្នំពេញ ។

21 USAID និង FAO ឆ្នាំ២០០៨ ទីផ្សារជ្រូកនៅកម្ពុជា៖ ការកាត់បន្ថយការប្រែប្រួលខុសលំនាំនៃទីផ្សារ ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធានាសុវត្ថិភាពពាណិជ្ជកម្ម ។

22 Vutha H. និង Keosothea N. ឆ្នាំ២០០៦ កម្មវិធីប្រមូលផលដើមដៃ៖ ផលប៉ះពាល់ចំពោះកសិកម្មកម្ពុជា ។

23 Vutha H. និង Vathana T. ឆ្នាំ២០០៩ ពាណិជ្ជកម្មកសិកម្ម ក្នុងមហាអនុតំបន់មេគ្គង៖ ករណីដំឡូងឈើ និងកៅស៊ូ នៅប្រទេសកម្ពុជា CDRI WP 43 ។

24 Fitzgerald R. និង John S. ឆ្នាំ២០០៩ ការលើកកម្ពស់ប្រព័ន្ធទីផ្សារ សម្រាប់ដំណាំពោត និងសណ្តែកសៀងនៅកម្ពុជា ។

25 Bonnivoit C., Viseth K., Sophal Y. ឆ្នាំ២០០៧ ការលើកកម្ពស់ការនាំចេញស្រូវរបស់កម្ពុជាក្រោយការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

ចំពោះព័ត៌មានលំអិតស្តីពីផលិតកម្មស្រូវ) និងភាពប្រកួតប្រជែងនៃពាណិជ្ជកម្មកៅស៊ូរបស់កម្ពុជានៅក្នុង GMS[26] ។ ដំណាំកៅស៊ូកម្ពុជា មានសក្តានុពលច្រើនសម្រាប់ការនាំចេញ និងពាណិជ្ជកម្មក្នុងទីផ្សារ GMS ។ ប៉ុន្តែវាមានសមត្ថភាពប្រកួតប្រជែងទាបជាងប្រទេសដទៃទៀតក្នុងតំបន់ដោយសារបច្ចេកវិទ្យាអន់ថយនិងផលិតភាពទាបថ្លៃឈ្នួលពលកម្មខ្ពស់ ថ្លៃដឹកជញ្ជូនខ្ពស់ និងថ្លៃកែច្នៃខ្ពស់ ដែលបញ្ហាទាំងអស់នេះបណ្តាលមកពីថ្លៃពន្ធនាំចូលអគ្គិសនីខ្ពស់ ។ លទ្ធផលវិស័យកៅស៊ូ អាចកើនឡើងយ៉ាងច្រើន ប្រសិនបើបច្ចេកទេសផលិតកម្ម លទ្ធភាពចូលទីផ្សារ ថ្លៃអគ្គិសនី និងការផ្តល់ហិរញ្ញប្បទានរយៈពេលវែងដល់ផលិតករ អាចល្អលំអឡើងទៀត ។

## ៤.៣ ការអភិវឌ្ឍកសិកម្ម ភាពក្រីក្រ និងសន្តិសុខស្បៀង

### *ការចិញ្ចឹមជីវិតនៅតំបន់ជនបទ និងសន្តិសុខស្បៀង*

ស្រូវអង្ករដែលជាអាហារចំបងរបស់ប្រជាជនកម្ពុជា ផ្តល់ប្រមាណ ២/៣ នៃថាមពលសរុបគិតជាកាឡូរីដល់គ្រួសារនានា[27 28] ហើយ ពោតដែលជាដំណាំស្បៀងបន្ទាប់បន្សំ ផ្តល់បាន ៧% ។ ការបរិភោគសាច់ និងត្រី នៅមានកម្រិតតិចតួច ។ ការកសាងផែនទីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាបានកំណត់ខេត្តចំនួន ៩ ដែលមានអសន្តិសុខស្បៀងធ្ងន់ធ្ងរ[29]៖ រតនគិរី មណ្ឌលគិរី ព្រះវិហារ កំពង់ស្ពឺ ឧត្តរមានជ័យ ស្វាយរៀង សៀមរាប ព្រៃវែង និងពោធិសាត់ ។ អត្រាមរណៈ អត្រាកង្វះទម្ងន់ធៀបនឹងអាយុ កង្វះកំពស់ធៀបនឹងអាយុ និងការស្រកទម្ងន់ធ្ងន់ធ្ងរកម្រិតខ្ពស់ គេបានរកឃើញក្នុង ៥ខេត្ត គឺសៀមរាប ព្រៃវែង រតនគិរី មណ្ឌលគិរី និងព្រះវិហារ ។ ខេត្តដែលមានអសន្តិសុខស្បៀងកម្រិតបង្គួរ រួមមាន កំពង់ធំ តាកែវ ស្ទឹងត្រែង ក្រចេះ កំពង់ចាម និងកណ្តាល ។ គួរកត់សំគាល់ថា ការស្រាវជ្រាវនេះបានធ្វើឡើងតាំងពីឆ្នាំ២០០៧ ដូច្នេះស្ថានភាពអាចផ្លាស់ប្តូរច្រើនចាប់តាំងពីពេលនោះមក ប៉ុន្តែកម្ពុជាគ្មានតួលេខថ្មីៗ ឬតួលេខធ្វើបច្ចុប្បន្នភាព ស្តីពីសូចនាករទាំងនេះទេ ។

មានការសិក្សាស្រាវជ្រាវសម្បូរបែបស្តីពី ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងសន្តិសុខស្បៀង និងភាពក្រីក្រនៅកម្ពុជា ជាអាទិ ការប្រើប្រាស់ការវិភាគ cross-section[30 31] និង panel data(កម្រងទិន្នន័យ)[32 33 34] និងវិធីសាស្ត្រ

---

26 Saing Chan Hang ឆ្នាំ២០០៩ ភាពប្រកួតប្រជែងក្នុងការនាំចេញនៃវិស័យកៅស៊ូកម្ពុជា ធៀបជាមួយអ្នកហ៊ុនផ្គត់ផ្គង់ដទៃទៀតក្នុងមហាអនុតំបន់មេគង្គ៖ ការវិភាគបែបពិព័ណ៌នាសាមញ្ញ ARTNeT ឯកសារពិភាក្សាស្តីពីគំនិតផ្តួចផ្តើម GMS លេខ១ ។

27 Murshid K. ឆ្នាំ១៩៩៨ សន្តិសុខស្បៀងក្នុងសេដ្ឋកិច្ចអន្តរកាលនៅអាស៊ី៖ បទពិសោធន៍ប្រទេសកម្ពុជា CDRI WP 6 ។

28 FAO ឆ្នាំ២០១០ ការចាត់ថ្នាក់ដំណាំសន្តិសុខស្បៀង ជំពូក២ អំពីកម្រៃផលប៉ះពាល់នៅកម្រិតគ្រួសារនៃការឡើងថ្លៃស្បៀងអាហារ មានចុះនៅលើគេហទំព័រ www.fao.org/docrep/012/i1664e/i1664e.pdf (បានបើកមើលនៅថ្ងៃ ខែ ឆ្នាំ) ។

29 FAO ឆ្នាំ២០០៧ ការកសាងផែនទីស្ថានភាពសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ (FSN) និងកិច្ចប្រឹងប្រែងបច្ចុប្បន្នរបស់ភ្នាក់ងារមូលដ្ឋាននៅកម្ពុជា ។

30 Engvall A., Sjöberg Ö. & Sjöholm F. ឆ្នាំ២០០៧ ភាពក្រីក្រនៅតំបន់ជនបទកម្ពុជា៖ ផលប៉ះពាល់ផ្សេងពីគ្នានៃចំណងទាក់ទងធាតុចូល និងលទ្ធភាពមានដីធ្លីប្រើប្រាស់ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចឧស្សាហកម្ម ឯកសារពិភាក្សា IFN លេខ ៧០៦ ។

31 Koy Ra & Em Sorany. ឆ្នាំ២០០៩ ការកសាងសមត្ថភាពសហគមន៍សម្រាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប CDR ច្បាប់លេខ ១៣ (១) CDRI ភ្នំពេញ ។

32 Sophal C. & & Acharya S. ឆ្នាំ២០០២ ការដោះស្រាយបញ្ហាប្រឈមក្នុងការចិញ្ចឹមជីវិតនៅតំបន់ជនបទ៖ ទស្សនវិស័យទទួលបានពីភូមិ ៩ នៅប្រទេសកម្ពុជា CDRI WP 25 ។

33 FitzGerald I. Sovannarith S. ឆ្នាំ២០០៧ ការចាកផុតពីភាពក្រីក្រ? និន្នាការក្នុងសុខុមាលភាពសហគមន៍ និងបម្លាស់ទីគ្រួសារនៅភូមិ ៩ ក្នុងប្រទេសកម្ពុជា ។

34 Sovannarith S.; Kimsun T. & Vuthy T. (ជិតចេញផ្សាយ) ការសិក្សាពីឌីណាមិកភាពក្រីក្រ របាយការណ៍របស់ CDRI សម្រាប់ធនាគារពិភពលោកស្តីពី ការសិក្សាភាពក្រីក្រនៅកម្ពុជាដោយវិធីអង្កេតកម្មវត្ថុស្រាវជ្រាវច្រើនលើក នៅទីតាំងជាក់លាក់ ក្នុងរយៈពេលវែង ។

តាមបែបគុណវិស័យ[35] [36] ។ ជាទូទៅលទ្ធផលការស្រាវជ្រាវបង្ហាញថា ការកាត់បន្ថយភាពក្រីក្រក្នុងទសវត្សរ៍កន្លងទៅ ទំនងជាពុំមានទំនាក់ទំនងជាមួយកំណើនសេដ្ឋកិច្ចទេ[37] ហើយកំណើនសេដ្ឋកិច្ចក៏ពុំមានលក្ខណៈរាប់បញ្ចូលដែរ ។ ភាពក្រីក្រ និងអសន្តិសុខស្បៀង នៅមានកម្រិតខ្ពស់នៅតំបន់ជនបទ ។ បញ្ហាកម្មសិទ្ធិដីធ្លីនៅតែជាកត្តាចំបងនៃភាពក្រីក្រ និងអសន្តិសុខស្បៀងសម្រាប់គ្រួសារកម្ពុជានៅតំបន់ជនបទ ។ គ្រួសារធំៗដែលមានសមាជិកច្រើននាក់រស់នៅពឹងផ្អែកលើមេគ្រួសារដែលមានកម្រិតអប់រំទាប និងសុខភាពមិនល្អ គឺជាកត្តាកំណត់ផ្ទៃក្នុងចំបងនៃភាពក្រីក្រតាមសហគមន៍ជនបទនានា ។ លទ្ធភាពតិចតួចក្នុងការទទួលបានសេវាសាធារណៈ សេវាអប់រំ សេវាសុខាភិបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ កង្វះលទ្ធភាពទទួលបានឥណទាន និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ (ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព) គឺជាកត្តាកំណត់ផ្ទៃក្រៅនៃភាពក្រីក្រនៅតំបន់ជនបទ ។ វិស័យកសិកម្មត្រូវបានចាត់ទុកថាជា កត្តាសំខាន់ចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅតំបន់ជនបទ ខណៈដែលធនធានទ្រព្យរួម និងឱកាសទទួលបានប្រាក់ឈ្នួលពលកម្ម ដើរតួនាទីជាសំណាញ់សុវត្ថិភាពដ៏សំខាន់សម្រាប់ប្រជាជនក្រីក្រ ។ ដូចបានបញ្ជាក់ខាងដើម ស្រូវអង្ករជាស្បៀងអាហារចំបងសម្រាប់ប្រជាជនកម្ពុជា ប៉ុន្តែផលិតកម្មស្រូវជួបប្រទះឧបសគ្គជាច្រើន (សូមអានជំពូក ៤.៤) ហើយទោះបីជាឧបសគ្គទាំងនេះគេបានកំណត់ឃើញជាច្រើនទសវត្សរ៍មកហើយក្តី ក៏កម្ពុជានៅមិនទាន់ដោះស្រាយវាបាននៅឡើយ ។ ចំនួនគ្រួសារគ្មានដីធ្លី បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំគួរឱ្យកត់សំគាល់ដោយសារការកសាងគ្រួសារថ្មី និងទីផ្សារដីធ្លី ។ គេក៏មិនទាន់ដឹងច្បាស់ដែរអំពីបញ្ហាប្រឈម ក៏ដូចជា អន្តរកម្មរវាងភាពគ្មានដីធ្លីនិងអសន្តិសុខស្បៀង ហើយនិង ការការពារសង្គមនិងភាពងាយរងគ្រោះ ។

### *ការស្រាវជ្រាវអនុវិស័យជលផល*

មានការសិក្សាស្រាវជ្រាវមួយចំនួនស្តីពីការនេសាទទឹកនៅកម្ពុជា ជាពិសេសបឹងទន្លេសាប ។ ការសិក្សាពីគោលនយោបាយ ២ បានពិនិត្យពីកំណែទម្រង់គោលនយោបាយជលផល និងការគ្រប់គ្រងរួមគ្នានៃសហគមន៍នេសាទ[38] [39] ។ ឧបករណ៍គ្រប់គ្រងរួមគ្នាមានលក្ខណៈថ្មីក្នុងវិស័យជលផលនៅកម្ពុជា ហើយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនេះ មានបំណងសម្រេចឲ្យបាននូវការប្រើប្រាស់ និងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងសមធម៌ ។ ទោះជាយ៉ាងណា លទ្ធផលបញ្ជាក់ថា ការអនុវត្ត និងនិរន្តរភាពនៃការគ្រប់គ្រងរួមគ្នា ត្រូវជួបឧបសគ្គនៃកង្វះការកំណត់ច្បាស់លាស់នូវសិទ្ធិលើទ្រព្យសម្បត្តិ និងព្រំដែននៃធនធាន និងអវត្តមាននៃច្បាប់ជួយគាំទ្រ ។ ការសិក្សារបស់ CDRI មួយទៀតក៏បានបញ្ជាក់ពីវត្តមានបញ្ហានេះ ដែលអាចនាំទៅដល់ទំនាស់ក្នុងចំណោមសហគមន៍នានា ។ ទំនាស់ក៏កើតឡើងពីការប្រកួតប្រជែងប្រើប្រាស់ធនធាន រវាងការនេសាទ និងការធ្វើកសិកម្មផងដែរ ហើយទំនាស់ជាច្រើននៅមិនទាន់ដោះស្រាយបាននៅឡើយ ។ ប្រជាពលរដ្ឋក្រីក្រនៅមិនទាន់បានទទួលអត្ថប្រយោជន៍ពីលទ្ធភាពបានចូល

---

35 Sedara K., Sophal C. & Acharya S. ឆ្នាំ២០០២ ដីធ្លី ការចិញ្ចឹមជីវិតនៅតំបន់ជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនាទានបានពីការចុះពិនិត្យមើលកន្លែងជាក់ស្តែង CDRI WP 24 ។

36 Brett M. B., Christian S., David W.;,FitzGerald I., Murshid K.A.S, Hansen K., Runsinarith P. & Sovannara L. ឆ្នាំ២០០៧ យើងកំពុងរស់នៅដោយក្តីបារម្ភរាល់ពេល៖ ការវាយតម្លៃអំពីភាពក្រីក្រដោយមានការចូលរួមនៅតំបន់ទន្លេសាប CDRI ភ្នំពេញ ។

37 កំណើនសេដ្ឋកិច្ចពិតស្មើនឹង ៨,៥% ពីឆ្នាំ១៩៩៤-២០០៨ ប៉ុន្តែភាពក្រីក្របានថយចុះតែ ១-១,៥% ក្នុងមួយឆ្នាំ ។ ទិដ្ឋភាពនេះបង្ហាញថា សេដ្ឋកិច្ចមានកំណើនខ្ពស់របស់កម្ពុជា មិនប្រាកដជាផ្តល់ប្រយោជន៍ដល់ពលរដ្ឋក្រីក្រទេ ហើយកំណើនសេដ្ឋកិច្ចអាចពុំមែនជាលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់កាត់បន្ថយភាពក្រីក្រដែរ (ការសិក្សាឌីណាមិកភាពភាពក្រីក្រដោយ CDRI ជិតចេញផ្សាយ) ។

38 Somony T. ឆ្នាំ២០០២ កំណែទម្រង់គោលនយោបាយជលផល និងទស្សនវិស័យបច្ចុប្បន្នអំពីសហគមន៍នេសាទ និងការគ្រប់គ្រងជលផលរួមគ្នា៖ ករណីសិក្សា តំបន់ឡូត៍នេសាទមួយចំនួននៅខេត្តសៀមរាប និង បាត់ដំបង ។

39 Viner K., Ahmed M., Bjørndal T., Lorenzen K. ឆ្នាំ២០០៦ ការអភិវឌ្ឍការគ្រប់គ្រងជលផលរួមគ្នានៅកម្ពុជា៖ ករណីសិក្សា និងផលប៉ះពាល់នៃការគ្រង់គ្រងជលផលរួមគ្នា WorldFish Centre, ឯកសារពិភាក្សាលេខ ២ ។

ទៅក្នុងដែននេសាទ[40] នៅឡើយ ។ ទំនាស់សហគមន៍នេសាទមួយចំនួនអាចដោះស្រាយតាមតំបន់ ដោយមានការគាំទ្រពីស្ថាប័នថ្នាក់ខ្ពស់ ។ ការវាយតម្លៃសេដ្ឋកិច្ច-សង្គមកិច្ចនៃការនេសាទទឹកសាបខ្នាតតូចនៅអាងទន្លេមេគង្គខាងក្រោម បង្ហាញថា គ្រួសារនេសាទតូចមួយរកចំណូលបានជាមធ្យម ១២ដុល្លារអាមេរិកក្នុងការចេញនេសាទមួយជើងនៅរដូវបើកនេសាទ និង ៤,៦ដុល្លារអាមេរិកនៅរដូវបិទនេសាទ[41] ។ ប៉ុន្តែនៅពេលពលកម្មគ្រួសារត្រូវបានកាត់ចេញពីប្រាក់ចំណូលសុទ្ធ ប្រាក់ចំណេញពិតមានត្រឹមតែ ៤.៥ដុល្លារអាមេរិកនៅរដូវបើកនេសាទ និង ១,៦ដុល្លារអាមេរិកនៅរដូវបិទនេសាទ ។ រាជរដ្ឋាភិបាលកម្ពុជាដោយមានការគាំទ្រពី Sida បានធ្វើការសិក្សាមួយស្តីពីការវាយតម្លៃពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍបឹងទន្លេសាប[42] ។ ការសិក្សានេះ ព្យាយាមវាយតម្លៃឥទ្ធិពលនៃ បំរែបំរួលជលសាស្រ្តនិងជលផលនៅទន្លេសាប ការដុះដីល្បប់ ហានិភ័យផ្សេងៗ ការអភិវឌ្ឍកសិកម្មជុំវិញបឹងទន្លេសាប និង ការគ្រប់គ្រងសហគមន៍នេសាទនៅតំបន់ទន្លេសាប ។

ការសិក្សាជាច្រើនបានលើកឡើងពីបញ្ហានេសាទទឹកសាប តែមិនទាន់មានការសិក្សាពីការនេសាទទឹកប្រៃនៅឡើយទេ លើកលែងតែគម្រោងមួយឧបត្ថម្ភដោយ FAO ដែលកំពុងធ្វើការវាយតម្លៃលើការសិក្សាមូលដ្ឋានគោលមួយអំពីសហគមន៍នេសាទនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា ។ កម្ពស់ទឹកទន្លេមេគង្គបច្ចុប្បន្នមានកម្រិត ៣-៤ម៉ែត្រ ទាបជាងកម្ពស់ទឹកដែលធ្លាប់មាន ដោយសារការសង់ទំនប់នៅខ្សែទឹកខាងលើ ហើយរឿងនេះនឹងមានផលប៉ះពាល់អវិជ្ជមានដល់ការនេសាទទឹកសាបនៅកម្ពុជា ។ យើងមិនទាន់ដឹងច្បាស់ពី ឥទ្ធិពលនៃកម្ពស់ទឹកទន្លេមេគង្គទាបទៅលើចំនួនជលផលទឹកសាប ការបន្តពូជត្រី ជម្រកត្រី និងសន្តិសុខស្បៀងនៅប្រទេសកម្ពុជានៅឡើយទេ ។

*ការស្រាវជ្រាវអនុវិស័យបសុសត្វ*

គោលនយោបាយរាជរដ្ឋាភិបាលស្តីពីវិស័យបសុសត្វ គ្មានទិសដៅច្បាស់លាស់ទេ[43] ។ វិស័យនេះក៏គ្មានយុទ្ធសាស្រ្តផែនការរយៈពេលវែង សម្រាប់ជួយណែនាំការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែរ[44] ។ វិស័យបសុសត្វមានមុខងារសំខាន់សម្រាប់សន្តិសុខស្បៀង និងកម្លាំងអូសទាញក្នុងផលិតកម្មកសិកម្ម ។ គោ និងក្របី ត្រូវបានប្រើប្រាស់ជាកម្លាំងអូសទាញក្នុងផលិតកម្ម និងជាសាច់សម្រាប់បរិភោគ ។ ជ្រូក និងមាន់ គេចិញ្ចឹមដើម្បីសន្សំប្រាក់ និងបរិភោគ[45] ។ ជ្រូក និងមាន់ត្រូវបានជួញដូរយ៉ាងសកម្ម ក្នុងភូមិ និងរវាងភូមិនានានៅតំបន់ជនបទ ។ ពាណិជ្ជកម្មគោក្របី បានប្រព្រឹត្តក្រៅផ្លូវការជាមួយប្រទេសជិតខាង ។ ថ្មីៗនេះ មិនមានការសិក្សាស្រាវជ្រាវគោលនយោបាយក្នុងវិស័យបសុសត្វទេ លើកលែងតែការស្រាវជ្រាវកំពុងអនុវត្តដោយ CelAgrid ស្តីពីចំណីសត្វ ( ពិសេសចំណីជ្រូក ) ។ ដូច្នេះ គួរមានការស្រាវជ្រាវបន្ទាន់ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យនេះ ហើយការសិក្សាផ្នែកសេដ្ឋកិច្ច-សង្គមកិច្ចនៃបសុសត្វគប្បីចាត់ទុកជាអាទិភាព ។

---

40 Sovannarith S., Blake D. R. Kosal M. & Sour K. ( ជិតចេញផ្សាយ ) ទំនាស់ និងសកម្មភាពរួមគ្នានៅក្នុង ជលផលទន្លេសាប៖ ការកែតម្រូវផ្នែកស្ថាប័នដើម្បីគាំទ្រការចិញ្ចឹមជីវិតក្នុងសហគមន៍ CDRI WP ។

41 Navy H. & Bhattarai M. ឆ្នាំ២០០៩ សេដ្ឋកិច្ច និងការចិញ្ចឹមជីវិតដោយការនេសាទទឹកសាបខ្នាតតូចក្នុងអាងទន្លេមេគង្គខាងក្រោម៖ អង្កេតសហគមន៍ ៣ នៅកម្ពុជា ឯកសារគោលនយោបាយទឹកលេខ១១ អត្ថបទបន្ថែមលេខ១(២០០៩) ៣១-៥ ។

42 Chadwick M. Juntopas M. & Sithirith M. ឆ្នាំ២០០៨ ទន្លេសាបប្រកបដោយនិរន្តរភាព៖ ការវាយតម្លៃអំពីបញ្ហាប្រឈមចំពោះការអភិវឌ្ឍទន្លេសាប បណ្តាញស្រាវជ្រាវទន្លេមេគង្គប្រកបដោយនិរន្តរភាព ផ្តល់មូលនិធិដោយ Sida ។

43 Sophal Ear ឆ្នាំ២០០៥ សេដ្ឋកិច្ចនយោបាយនៃគោលនយោបាយបសុសត្វផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្រីក្រនៅកម្ពុជា PPLPI WP No. 26 គំនិតផ្តួចផ្តើមស្តីពីគោលនយោបាយបសុសត្វផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្រីក្ររបស់ FAO ។

44 FAO កំពុងជួយនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ ដើម្បីរៀបចំផែនការយុទ្ធសាស្រ្តរយៈពេលវែង ដែលត្រូវបញ្ចប់ក្នុងឆ្នាំ២០១០ ។

45 FAO ឆ្នាំ២០០៤ ការពិនិត្យឡើងវិញអំពីវិស័យបសុសត្វ ក្នុងរបាយការណ៍វិស័យបសុសត្វរបស់ប្រទេសតំបន់មេគង្គ៖ កម្ពុជា ឡាវ ថៃ វៀតណាម ។

*កម្មវិធីគាំទ្រការអភិវឌ្ឍកសិកម្ម*

អនុផ្នែកនេះ ពិនិត្យឡើងវិញនូវដៃគូអភិវឌ្ឍន៍នានាដែលកំពុងគាំទ្រការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ។ ស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា យកវិស័យកសិកម្មធ្វើជាកម្លាំងជម្រុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ (ធនាគារពិភពលោក CIDA និង GTZ) បានធ្វើការសិក្សារចនាសម្ព័ន្ធក្សេត្រសាស្ត្រនៅឆ្នាំ២០០៥[46] ដើម្បីវាយតម្លៃវិស័យកសិកម្ម និងកំណត់វិធីសាស្ត្រយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកសិកម្ម និងគ្រប់គ្រងដីធ្លី ។ ការសិក្សាដ៏ធំទូលាយនេះគ្របដណ្តប់លើប្រព័ន្ធផលិតកម្មកសិកម្ម ការប្រើប្រាស់ដី និងការគ្រប់គ្រងដីក្នុងប្រទេសកម្ពុជា[47] ។ ការសិក្សានេះក៏ផ្តោតលើខ្សែសង្វាក់តម្លៃ គំរូសហគ្រាស និងការវិភាគពីចំណាយនិងផលចំណេញផងដែរ ប៉ុន្តែមិនបានផ្តោតលំអិតលើវិស័យបសុសត្វទេ ។

ក្នុងការគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មកម្ពុជា AusAID បានធ្វើការសិក្សាវិភាគស្ថានភាពក្នុងឆ្នាំ២០០៦[48] ក្នុងគោលបំណងកំណត់តម្លៃសក្តានុពល និងលទ្ធភាពអនុវត្តសកម្មភាពផ្សេងៗនៃកម្មវិធីដែលត្រូវអនុវត្តក្នុងឆ្នាំ២០០៧-២០១២[49] [50] ។ កម្មវិធីគាំទ្រការអភិវឌ្ឍកសិកម្មសំខាន់របស់ AusAID រួមមាន ការអភិវឌ្ឍខ្សែសង្វាក់តម្លៃ និងគោលនយោបាយ ការកសាងសមត្ថភាព និងការគ្រប់គ្រង ។ សកម្មភាពសម្រាប់គាំទ្រដល់ខ្សែសង្វាក់តម្លៃ រួមមាន ការផ្ទេរបច្ចេកវិទ្យា ទំនាក់ទំនងទីផ្សារនិងខ្សែសង្វាក់តម្លៃ ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ។ គោលដៅនៃកម្មវិធី AusAID គឺភាគខាងត្បូងប្រទេសកម្ពុជា និងផ្តោតជាពិសេសលើប្រព័ន្ធកសិកម្មស្រូវ ។

ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងឧបត្ថម្ភគាំទ្រកម្មវិធីអភិវឌ្ឍន៍កសិកម្មនៅតំបន់ទន្លេសាប ដែលរួមមាន គោលនយោបាយអភិវឌ្ឍន៍កសិកម្មនៅជនបទ (ARD) និងការគ្រប់គ្រងវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រោចស្រព និងគម្រោងសាកល្បងអភិវឌ្ឍន៍នៅតំបន់ជនបទ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានវាយតម្លៃលើការឧបត្ថម្ភគាំទ្ររបស់ខ្លួនចំពោះ ARD នៅកម្ពុជាតាំងពីឆ្នាំ១៩៩៥-២០០៨ ។ ប្រាក់កម្ចី និងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការគាំទ្របច្ចេកទេសនៃគម្រោង/កម្មវិធី មានទឹកប្រាក់សរុប ២៤០.៧លានដុល្លារអាមេរិក ។ ការសិក្សាវាយតម្លៃ បានផ្តល់ការណែនាំដែលមានចរិតស្ថាបនា ដល់ការកំណត់អាទិភាព ការរចនារៀបចំនិងអនុវត្តការគាំទ្របច្ចេកទេស និងប្រតិបត្តិការផ្តល់ឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងវិស័យនេះ[51] [52] ។ កម្មវិធីឧបត្ថម្ភគាំទ្រនាពេលអនាគតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តោតលើផ្លូវថ្នល់ជនបទ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ការផ្គត់ផ្គង់ទឹក មីក្រូឥណទាននៅតំបន់ជនបទ កម្មសិទ្ធិដីធ្លី និងការពង្រឹងសមត្ថភាពស្ថាប័ន ។ ធនាគារអភិវឌ្ឍន៍អាស៊ីគ្រោងពង្រីកសកម្មភាពរបស់ខ្លួនលើផ្នែកដទៃទៀតនៅកម្ពុជា ដោយផ្អែកលើការសិក្សាពីជោគជ័យនៃកម្មវិធីរបស់ខ្លួននាពេលកន្លងទៅ ក្នុងអាងទន្លេសាប ។

---

46 ការសិក្សាក្សេត្រសាស្ត្រនេះគឺជាធាតុចូលសំខាន់មួយសម្រាប់រៀបចំយុទ្ធសាស្ត្រ ក្នុងវិស័យកសិកម្ម និងទឹក (SAW) ។

47 ACI ឆ្នាំ២០០៥ ការសិក្សាអំពីរចនាសម្ព័ន្ធក្សេត្រសាស្ត្ររបស់កម្ពុជា របាយណ៍រៀបចំដោយ Agrifood Consulting International សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រដោយធនាគារពិភពលោក CIDA និង GTZ ។

48 ការសិក្សាវិភាគស្ថានភាពនេះ គឺជាធាតុចូលមួយដ៏សំខាន់សម្រាប់ការរៀបចំយុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW) ។

49 ACI ឆ្នាំ២០០៦ក ការសិក្សាវិភាគស្ថានភាពដំណាក់កាលទី ១ នៃការរចនារៀបចំកម្មវិធីកសិកម្ម (កម្ពុជា ២០០៧-២០១២) ឯកសារទស្សនាទាននៃកម្មវិធី រៀបរៀងដោយ Agrifood Consulting International និង CamConsult សម្រាប់ AusAID ។

50 ACI 2006b, របាយការណ៍វិភាគស្ថានភាពវិស័យកសិកម្មកម្ពុជា រៀបរៀងដោយ Agrifood Consulting International និង CamConsult សម្រាប់ AusAID ។

51 ADB ឆ្នាំ២០០៩ វិស័យអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា៖ ការសិក្សាវាយតម្លៃ របស់នាយកដ្ឋានវាយតម្លៃឯករាជ្យនៃ ABD ។

52 ADB ឆ្នាំ២០១០ វិស័យអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា ការវាយតម្លៃឯករាជ្យនៃជំនួយរបស់ ADB ចំពោះវិស័យ ARD នៅកម្ពុជា ។

USAID បានផ្តល់មូលនិធិដើម្បីអនុវត្តគម្រោងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSME) ចំពោះខ្សែសង្វាក់តម្លៃក្នុងអនុវិស័យ ជ្រូក ត្រី និងគ្រឿងយន្តកសិកម្ម នៅភាគខាងត្បូងនៃប្រទេសកម្ពុជា[53] [54] ។ សរុបមក ការវាយតម្លៃបានរកឃើញថា គម្រោងនេះមានផលប៉ះពាល់ចំបងលើការកែលំអផលិតភាព និងលទ្ធផលអាជីវកម្មនៃសហគ្រាសទាំងនេះ ដែលជះឥទ្ធិពលយ៉ាងល្អនៅកម្រិតខ្សែសង្វាក់តម្លៃ ។ ទោះយ៉ាងណាក៏ដោយ គោលដៅទាំងអស់មិនអាចសម្រេចបានក្នុងរយៈពេលខ្លីត្រឹម ៣ឆ្នាំឡើយ ហើយគេក៏មិនទាន់ទាញយកអត្ថប្រយោជន៍បានពេញលេញពីគម្រោងជំនួយទាំងនេះដែរ ។ លទ្ធផលការវាយតម្លៃនេះ អាចបង្កើតថែមទៀត ដើម្បីបង្កើនតម្លៃបន្ថែមលើសហគ្រាសទាំងនេះ និងខ្សែសង្វាក់តម្លៃនាពេលអនាគត ។

## ៤.៤ ការស្រាវជ្រាវអនុវិស័យស្រូវ

មានការសិក្សាអំពីគោលនយោបាយមួយចំនួន ដែលផ្តោតលើការលើកកម្ពស់វិស័យស្រូវ និងការជម្រុញការនាំចេញស្រូវ ដោយសារវិស័យនេះមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។ ស្រូវមានសក្តានុពលនាំចេញថ្មីល្អប្រសើរសម្រាប់ប្រទេសកម្ពុជា[55] ។ ការលើកកម្ពស់ការកែច្នៃកសិកម្ម និងកសិពាណិជ្ជកម្ម នឹងពង្រឹងវិស័យនេះសម្រាប់នាំចេញទៅកាន់ទីផ្សារពិភពលោក[56] ។ សមត្ថភាពបច្ចុប្បន្ននៃការកិនស្រូវនៅកម្ពុជាមានកម្រិតទាប (តិចជាង ១០តោនក្នុងមួយម៉ោង) ហើយអាចកិនបានត្រឹមតែ ១/៣ នៃផលស្រូវនៅកម្ពុជា ។ កម្ពុជាចាំបាច់ត្រូវបង្កើនសមត្ថភាពកិនស្រូវរបស់ខ្លួន ៣ដង ដើម្បីឆ្លើយតបនឹងតម្រូវការកិនស្រូវក្នុងស្រុក[57] ។ ដំណាំស្រូវមានសក្តានុពលយ៉ាងធំធេងសម្រាប់ការបង្កើនផលិតភាព តាមរយៈការកែលំអបច្ចេកទេសដាំដុះ និងវិនិយោគលើធាតុចូល ពោលគឺ ការកែលំអគ្រាប់ពូជ ជី និងការស្រោចស្រព[58] ។ ទោះជាយ៉ាងណា សក្តានុពលកំណើនទៅអនាគតក្នុងវិស័យស្រូវមានលក្ខណៈមិនប្រាកដប្រជា ដោយសារឧបសគ្គយ៉ាងច្រើន ដូចជា ធាតុចូលតិច កង្វះឥណទាន កង្វះការស្រោចស្រព កង្វះការកែលំអពូជ សេវាផ្សព្វផ្សាយកសិកម្មមិនបានល្អ និងផ្លូវជនបទមិនល្អ[59] ។ ACIAR/CAVAC កំពុងធ្វើការស្តីពីការកែលំអវិធីបង្កើនស្រូវ ដើម្បីបង្កើនផលិតភាព តាមរយៈការណែនាំឱ្យប្រើគ្រឿងយន្ត និងការប្រើប្រាស់ធាតុចូលសមស្រប[60] ។ ខ្សែសង្វាក់តម្លៃស្រូវ

---

53 USAID/កម្ពុជាឆ្នាំ២០០៧ ការវាយតម្លៃកម្មវិធីពង្រឹងសហគ្រាសមីក្រូ តូច និងមធ្យម នៅកម្ពុជា៖ ការវាយតម្លៃពាក់កណ្តាលអាណត្តិ ។

54 USAID ឆ្នាំ២០០៨ របាយការណ៍តាមដាន និងវាយតម្លៃចុងក្រោយនៃគម្រោងពង្រឹងសហគ្រាសមីក្រូ តូច និងមធ្យមនៅកម្ពុជា។

55 Sophal Ear ឆ្នាំ២០០៩ ការសាបព្រោះនិងតភ្ជាប់កំណើន៖ សេដ្ឋកិច្ចនយោបាយនៃស្រូវ និងឿលិតលកម្មសំលៀកបំពាក់នៅកម្ពុជា មជ្ឈមណ្ឌល Stanford សម្រាប់អភិវឌ្ឍន៍អន្តរជាតិ WP384 ។

56 Muniroth S. and Purcell T. ឆ្នាំ២០០៩ សក្តានុពលសម្រាប់វិនិយោគកសិពាណិជ្ជកម្ម ក្នុងផលិតកម្មស្រូវកម្ពុជា បទបង្ហាញឯកសារ PowerPoint របស់ អង្គការអភិវឌ្ឍន៍កសិកម្មអន្តរជាតិ (ADI) ។

57 Kimsun T. and Puy P. ឆ្នាំ២០១០ ការលើកកម្ពស់ការនាំចេញមាសសរបស់កម្ពុជា CDR លេខ ១៤ ច្បាប់លេខ ២, CDRI ភ្នំពេញ ។

58 Yu B. និង Fan S. ឆ្នាំ២០០៩ ដំណោះស្រាយក្នុងផលិតកម្មស្រូវនៅកម្ពុជា ឯកសារពិភាក្សារបស់ IFPRI លេខ ០០៩៣៩ ។

59 USDA ឆ្នាំ២០១០ កម្ពុជា៖ អត្រាកំណើនអនាគតនៃផលិតកម្មស្រូវ មានលក្ខណៈមិនប្រាកដប្រជា http://www. pecad.fas.usda.gov/highlights/2010/01/cambodia/ (បានបើកមើលថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១០) ។

60 គម្រោង ACIAR/CAVAC ស្តីពី "ការលើកកម្ពស់ការបង្កើត និងផលិតភាពស្រូវនៅកម្ពុជា និងអូស្រ្តាលី ២០១០-២០១៣" គម្រោងនេះកំពុងអនុវត្តដោយ CARDI ភាគខាងត្បូងប្រទេសកម្ពុជា ។

និងការធ្វើស្រែផ្អែកលើកិច្ចសន្យា ក៏ត្រូវបានសិក្សានៅក្នុងប្រទេសកម្ពុជាដែរ[61] [62] [63] ប៉ុន្តែចាំបាច់ត្រូវបង្កើតឱ្យមានការយល់ដឹងអំពីទំនាក់ទំនងខ្សែសង្វាក់តម្លៃស្រូវជាមួយទីផ្សារអន្តរជាតិ (រាជរដ្ឋាភិបាលកម្ពុជា ២០១០ខ) ។ (ចំពោះព័ត៌មានលំអិតពេញលេញនៃរបកគំហើញស្រាវជ្រាវ សូមពិនិត្យមើលឯកសារពេញលេញដែលបានបង់លេខយោង) ។

## ៤.៥ កសិកម្មនិងការប្រែប្រួលធាតុអាកាស

ផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាសមកលើវិស័យកសិកម្ម គឺជាផ្នែកស្រាវជ្រាវថ្មីនៅកម្ពុជា ដូច្នេះកន្លងមកមានការសិក្សាតិចតួចណាស់អំពីបញ្ហានេះ ។ ការស្រាវជ្រាវបានរកឃើញថា ការប្រែប្រួលធាតុអាកាសបានប៉ះពាល់អវិជ្ជមានមកលើជីវភាពរស់នៅ ដោយប្រាក់ចំណូលគ្រួសារបានធ្លាក់ចុះជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៩-២០០៨ ដោយសារកត្តាពាក់ព័ន្ធជាច្រើន ដូចជា ការរានព្រៃធ្វើកសិកម្ម ការហាមឃាត់មិនឱ្យចូលទៅក្នុងព្រៃ ឬការខូតខាតផលដំណាំបណ្តាលមកពីរដូវប្រាំងវែង និងការធ្លាក់ភ្លៀងមិនស្មើ[64] [65] ។ ទាំងប្រជាជននៅជនបទ និងទីក្រុង បានដឹងពីឥទ្ធិពលនៃការប្រែប្រួលធាតុអាកាសមកលើកសិកម្ម និងសុខភាពមនុស្ស៖ ប្រជាជនងាយធ្លាក់ខ្លួនឈឺ ធាតុអាកាសកាន់តែក្តៅ ទឹកជំនន់និងព្យុះភ្លៀងកើតមានជាញឹកញាប់ ដែលបានប៉ះពាល់ជាអវិជ្ជមានមកលើដំណាំកសិកម្ម[66] ។ ក្រៅពីនេះ ការប្រែប្រួលធាតុអាកាស ក៏បានប៉ះពាល់ផងដែរដល់វិស័យជលផលនៅកម្ពុជា ដែលផ្តល់ការចិញ្ចឹមជីវិតដល់ប្រជាជនរាប់លាននាក់ និងផ្តល់រហូតដល់ ៨០% នៃប្រូតេអ៊ីនសត្វសរុបនៅក្នុងអាហារ[67] ។ ជាការឆ្លើយតបនឹងការគំរាមកំហែងនៃការប្រែប្រួលធាតុអាកាស មានការស្រាវជ្រាវមួយចំនួន អំពីវិធីបន្សាំជាមួយបញ្ហាប្រឈមថ្មីៗនៃគ្រោះថ្នាក់ផ្នែកធាតុអាកាស ។ CARDI កំពុងជ្រើសរើសពូជស្រូវគោល ដែលមានរយៈពេលខ្លី និងអាចផ្តល់ផលក្នុងរយៈពេលខ្លី ដើម្បីកាត់បន្ថយតម្រូវការទឹក[68] ។ NAPA ក៏កំពុងធ្វើការសិក្សាសាកល្បងអំពីការកែលំអសមត្ថភាពបន្សាំរបស់កសិករ ទៅនឹងការប្រែប្រួលធាតុអាកាស (NAPA ២០០៦)ផងដែរ ។

---

61 វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៨ ការធ្វើស្រែដោយផ្អែកលើកិច្ចសន្យានៅកម្ពុជា៖ ការពង្រឹងកសិករឱ្យឈានឡើងហួសពីកិច្ចសន្យា ឆ្ពោះទៅរកឯករាជ្យភាព ។

62 DGS ឆ្នាំ២០០៣ ឆ្ពោះទៅរកយុទ្ធសាស្ត្រកំណើន ដឹកនាំដោយវិស័យឯកជនសម្រាប់ប្រទេសកម្ពុជា ការវិភាគខ្សែសង្វាក់តម្លៃច្បាប់លេខ ១ Global Development Solutions, របាយការណ៍ LLC រៀបចំសម្រាប់ធនាគារពិភពលោក ។

63 Agrifood Consulting International 2002, ការសិក្សាអំពីខ្សែសង្វាក់តម្លៃស្រូវ៖ ប្រទេសកម្ពុជា របាយការណ៍រៀបចំសម្រាប់ធនាគារពិភពលោក ។

64 CDRI (ចេញផ្សាយឆាប់ៗ) មាគ៌ាមាននិរន្តរភាពដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ៈ ករណីសិក្សានៅកម្ពុជា របាយការណ៍ពិសេសរបស់ CDRI ស្តីពីកសិកម្ម និងការប្រែប្រួលធាតុអាកាស ។

65 BBC World Service Trust (ចេញផ្សាយក្នុងពេលឆាប់ៗ) ការយល់ដឹងរបស់សាធារណជនអំពីការប្រែប្រួលធាតុអាកាសនៅកម្ពុជា-ការប្រើប្រាស់វិធីសាស្ត្រ KAP៖ ការបង្ហាញរបកគំហើញនៅវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ខែកញ្ញា ឆ្នាំ២០១០ ។

66 របាយការណ៍ចុងក្រោយស្តីពី ការយល់ដឹងរបស់សាធារណជនអំពីការប្រែប្រួលធាតុអាកាសនៅកម្ពុជា ដោយប្រើប្រាស់ KAP នៅថ្នាក់ជាតិ នឹងត្រូវប្រកាសផ្សព្វផ្សាយក្នុងប៉ុន្មានខែខាងមុខដោយ BBC World Service Trust នៅកម្ពុជា ។

67 មជ្ឈមណ្ឌល WorldFish Centre ឆ្នាំ២០០៩ ការប្រែប្រួលធាតុអាកាស និងជលផល៖ ភាពងាយរងគ្រោះ និងការបន្សាំ នៅកម្ពុជា ។

68 ACIAR/CAVAC គម្រោងស្តីពី "ការលើកកម្ពស់ការអភិវឌ្ឍ Germplasm Development នៃស្រូវ ដើម្បីប្រែក្លាយប្រព័ន្ធផលិតកម្មនៅកម្ពុជា និងអូស្ត្រាលី" គម្រោងនេះកំពុងអនុវត្តដោយ CARDI សម្រាប់ឆ្នាំ២០១០ ដល់ ២០១៣ ។

### ៤.៦ កសិកម្ម និងសន្តិសុខស្បៀង ក្នុងវិបត្តិហិរញ្ញវត្ថុពិភពលោក

កម្ពុជាបានរងគ្រោះជាខ្លាំងពីការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ដូចប្រទេសដទៃទៀតនៅក្នុងតំបន់ដែរ ។ សសរស្តម្ភ ៣ នៃកំណើនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ-វិស័យកាត់ដេរសំលៀកបំពាក់ វិស័យសំណង់ និងវិស័យទេសចរណ៍ (ធនាគារពិភពលោកឆ្នាំ២០១០) ។ មានតែវិស័យកសិកម្មមួយប៉ុណ្ណោះ ដែលបន្តមានកំណើន ៥% ក្នុងអំឡុងឆ្នាំ២០០៨-២០០៩ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០) ។ ទោះបីជាវិស័យកសិកម្ម មានសុខភាពល្អ និងភាពធន់ទ្រាំក្នុងអំឡុងពេលមានវិបត្តិក្តី តែក៏មានការសិក្សាមួយចំនួនកំពុងវាយតម្លៃផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុពិភពលោកនេះ មកលើកសិកម្ម និងសន្តិសុខស្បៀង ។ ការសិក្សាទាំងនោះ រួមមាន៖ វិបត្តិស្បៀងអាហារ និងវិបត្តិហិរញ្ញវត្ថុ-ផលប៉ះពាល់លើកសិកម្ម និងអាទិភាពគោលនយោបាយសម្រាប់កំណើនកសិកម្មអំណោយផលដល់ប្រជាជនក្រីក្រ[69] ការគ្រប់គ្រងសេដ្ឋកិច្ចឆ្លងកាត់វិបត្តិ-ការពង្រឹងវិស័យសំខាន់ៗសម្រាប់កំណើននាពេលអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ ការអភិវឌ្ឍកសិកម្ម[70] ការប៉ះទង្គិចពីរជាន់លើប្រជាជនក្រីក្រ៖ សន្តិសុខស្បៀងនៅកម្ពុជា ក្នុងពេលមានវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច[71] តើគ្រួសារជនបទកម្ពុជាទប់ទល់យ៉ាងណាចំពោះការឡើងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ?[72] ការស្រាវជ្រាវនេះបានរកឃើញថា ការកាត់បន្ថយថ្លៃស្បៀងអាហារអាចផ្តល់អត្ថប្រយោជន៍ដល់អ្នកទិញស្បៀងអាហារ ប៉ុន្តែកសិករដាំដំណាំកសិកម្ម (ដំឡូងឈើ សណ្តែកសៀង ពោត និងកៅស៊ូ) បានខាតបង់ប្រាក់ចំណូលយ៉ាងច្រើនលើកលែងតែកសិករដាំស្រូវដែលនៅតែមានប្រាក់ចំណូលវិជ្ជមាន ។ ប្រាក់ចំណូលពិតនៃគ្រួសារជនបទបានធ្លាក់ចុះ ៣១% ការបរិភោគស្បៀងធ្លាក់ចុះ ៣២% និងចំណាយប្រើប្រាស់ក្រៅពីស្បៀងធ្លាក់ចុះ ១០% ចន្លោះខែកញ្ញា ២០០៨ និង ២០០៩ (គីមស៊ុន និងអ្នកឯទៀត ឆ្នាំ២០០៩) ។ ជាមធ្យម ចំណាយស្រូវអង្ករបរិភោគបានថយចុះ ៣៦% ក្នុងរយៈពេលដូចគ្នា ។

## ៥. កង្វះការយល់ដឹងពីគោលនយោបាយ និងការស្រាវជ្រាវគោលនយោបាយ ក្នុងវិស័យកសិកម្ម

ជាសំខាន់ ផ្នែកនេះវិភាគពីគោលនយោបាយបច្ចុប្បន្នរបស់រាជរដ្ឋាភិបាល ដែលផ្តល់អាទិភាពដល់វិស័យកសិកម្ម និងការស្រាវជ្រាវពីគោលនយោបាយមានស្រាប់ និងឆ្លុះបញ្ចាំងពីគោលនយោបាយ និងកង្វះការយល់ដឹងក្នុងវិស័យនេះ ។ CDRI ក៏បានពិគ្រោះយោបល់ជាមួយក្រសួងនានារបស់រាជរដ្ឋាភិបាល ដើម្បីកំណត់បញ្ហាត្រូវស្រាវជ្រាវជាអាទិភាពទៅអនាគត និងកសាងយុទ្ធសាស្ត្រស្រាវជ្រាវប្រចាំកម្ពុជារបស់ខ្លួនសម្រាប់ឆ្នាំ២០២០ នៅខែកក្កដា និង សីហា ២០១០។ បញ្ហាស្រាវជ្រាវអាទិភាពមួយចំនួនដែលកំណត់ឃើញក្នុងពេលពិគ្រោះយោបល់ ក៏បានដាក់បញ្ចូលក្នុងផ្នែកនេះដែរ ។

ចំណុចខ្វះខាតផ្នែកគោលនយោបាយ៖

- រាជរដ្ឋាភិបាលបានកំណត់វិស័យកសិកម្ម ជាក្បាលម៉ាស៊ីននៃកំណើនអំណោយផលដល់គ្រប់គ្នា នៅក្នុងកម្មវិធីគោលនយោបាយភាគច្រើននៃអាណត្តិការងាររបស់រាជរដ្ឋាភិបាល ។ទោះយ៉ាងណា ថវិការបស់រាជរដ្ឋាភិបាល

---

69 Theng Vuthy ឆ្នាំ២០០៩ វិបត្តិស្បៀងអាហារ និងវិបត្តិហិរញ្ញវត្ថុ ផលប៉ះពាល់លើកសិកម្ម និងលើអាទិភាពគោលនយោបាយសម្រាប់កំណើនកសិកម្មអំណោយផលដល់ប្រជាជនក្រីក្រ ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា លេខ ១៣ (២) CDRI ភ្នំពេញ ។

70 Nam Tum & Theng Vuthy ឆ្នាំ២០០៩ ការគ្រប់គ្រងសេដ្ឋកិច្ចឆ្លងកាត់វិបត្តិ ការពង្រឹងតាមវិស័យសំខាន់ៗសម្រាប់កំណើននាពេលអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ការអភិវឌ្ឍកសិកម្ម និងជនបទ ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា លេខ ១៣ (២) CDRI ភ្នំពេញ ។

71 Hossein J. Glenda R. & Pide L. ឆ្នាំ២០១០ ការប៉ះទង្គិចពីរជាន់លើប្រជាជនក្រក្រី៖ សន្តិសុខស្បៀងនៅកម្ពុជា ក្នុងពេលមានវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច ADR 2009/10, CDRI, ភ្នំពេញ ។

72 Tong Kimsun ឆ្នាំ២០១០ តើគ្រួសារនៅជនបទកម្ពុជា ទប់ទល់យ៉ាងណាចំពោះការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ? ADR 2009/2010, CDRI ភ្នំពេញ ។

ដែលបានវិភាជន៍ចំពោះវិស័យនេះ មានកម្រិតទាបជាខ្លាំង ប្រមាណជា ២% នៃថវិកាសរុប ឬតិចជាង ១% នៃ ផសស (តារាង ៤) ។ ចំណុចនេះបង្ហាញថា សកម្មភាពសម្រាប់ការអភិវឌ្ឍន៍កសិកម្ម មិនបានទទួលអាទិភាពខ្ពស់ដូចគ្នាពីសំណាក់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលឡើយ ។

- អនុវិស័យបសុសត្វ ក៏ជាផ្នែកមួយសំខាន់ណាស់សម្រាប់ផលិតកម្មកសិកម្ម សន្តិសុខស្បៀង និងការធ្វើពិពិធកម្មប្រាក់ចំណូលគ្រួសារ ។ ទោះយ៉ាងណា គោលនយោបាយរបស់រាជរដ្ឋាភិបាលគ្មានការណែនាំច្បាស់លាស់អំពីការលើកកម្ពស់វិស័យនេះទេ ។ គោលនយោបាយអាទិភាព ផ្តោតជាសំខាន់លើសេវាគ្រប់គ្រងជម្ងឺការបង្កាត់ពូជសត្វចំណីសត្វនិងសុវត្ថិភាពស្បៀងទាក់ទិននឹងការបរិភោគសាច់សត្វ។លើសពីនេះផែនការយុទ្ធសាស្ត្រតាមវិស័យ ក៏គ្មានការណែនាំច្បាស់លាស់ផ្នែកគោលនយោបាយ ឬមូលដ្ឋានគោលដើម្បីអនុវត្តអនុវិស័យបសុសត្វ ឲ្យបានសម្រេចតាម ផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០ និងកម្មវិធីសន្តិសុខស្បៀងនៅក្នុង SAW នោះឡើយ ។

- ក្នុងពេលជាមួយគ្នានេះ គេពុំឃើញមានផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យដំណាំកសិកម្មទេ ទោះបីវិស័យនេះកំពុងរីកចំរើនគួរឱ្យកត់សំគាល់ និងរួមចំណែកប្រមាណ ៥០% នៃ ផសស កសិកម្មក្តី (តារាង ១) ។ គោលនយោបាយយុទ្ធសាស្ត្របានកំណត់គោលដៅច្បាស់លាស់ សម្រាប់តែផលិតកម្មស្រូវ និងដំណាំកៅស៊ូប៉ុណ្ណោះ រីឯ ពោត សណ្តែកសៀង សណ្តែកបាយ និងដំឡូងឈើ ត្រូវបានផលិតទៅតាមតម្រូវការទីផ្សារ និងត្រូវប្រឈមមុខនឹងហានិភ័យ ដោយសារគ្មានការធានាផ្នែកតម្រូវការ ។ គេពុំឃើញមានគោលនយោបាយច្បាស់លាស់ ដើម្បីកែលំអមុខដំណាំដ៏មានសក្តានុពលទាំងនេះ សម្រាប់ផលិតកម្មផ្តោតទៅលើទីផ្សារនោះទេ ។

- គោលនយោបាយមួយចំនួន ផ្តោតលើការកែលំអផលិតកម្មកសិកម្ម ដើម្បីផ្តល់ស្បៀងអាហារដល់ប្រជាជនគ្រប់គ្នា ។ បន្ថែមលើនេះ កំណែទម្រង់ដីធ្លី ក៏បានបញ្ជាក់ច្បាស់អំពីការបែងចែកដីធ្លី ចំពោះគ្រួសារគ្មានដី (លទ្ធភាពបានទទួលដី) (រាជរដ្ឋាភិបាលកម្ពុជា ២០០៤ និង ២០០៦ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៥) ។ ទោះជាយ៉ាងណា គ្រួសារជនបទប្រមាណ ២៥% (ហង់ ឆ្នាំ២០១០) មានលទ្ធភាពតិចតួច ឬគ្មានលទ្ធភាពក្នុងការបានទទួលដីកសិកម្ម ។ ក្រុមទាំងនេះត្រូវប្រឈមមុខនឹងកង្វះស្បៀង និងភាពក្រីក្រ ។ វិធានការជាក់លាក់សម្រាប់ក្រុមទាំងនេះ មិនត្រូវបានដោះស្រាយ ហើយក៏គ្មានការចាត់វិធានការច្បាស់លាស់ដែរ ។

- ចំណុចដៅផ្នែកគោលនយោបាយ និងរបៀបរបបអនុវត្តមិនមានចែងច្បាស់លាស់ទេ ។ ផ្អែកលើឯកសារ ផយអជ ឆ្នាំ២០០៦-២០១០ មានការកំណត់ថា ទិន្នផលស្រូវត្រូវឡើងដល់ ២,៤តោនក្នុងមួយហិកតា ហើយផ្ទៃដីធ្វើស្រែត្រូវពង្រីករហូតដល់ ២,៥លានហិកតា នៅឆ្នាំ២០១០ ។ ទោះជាយ៉ាងណា ប្រទេសកម្ពុជាផលិតស្រូវបាន ២,៥តោនក្នុងមួយហិកតា តាំងពីឆ្នាំ២០០៥មកម្លេះ (តារាង ២ រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៨) ហើយផ្ទៃដីធ្វើស្រែបានអនុវត្តសម្រេចតាមផែនការ ២,៥លានហិកតា នៅឆ្នាំ២០០៦ (ក្រាហ្វិក ៥) ។ ផែនការទិន្នផលស្រូវ បានកែសម្រួលឡើងវិញដល់ ២,៨តោនក្នុងមួយហិកតា នៅឆ្នាំ២០១០ (រាជរដ្ឋាភិបាលកម្ពុជា ២០១០ក) ។ ចំណុចនេះបង្ហាញឱ្យឃើញអំពីការសម្របសម្រួល និង/ឬសហប្រតិបត្តិការមិនបានល្អក្នុងដំណើរការកសាងផែនការក្នុងចំណោមនាយកដ្ឋាន ឬក្រសួងពាក់ព័ន្ធនានា ដូចមានបញ្ជាក់នៅក្នុងគោលនយោបាយ ។

កង្វះការយល់ដឹងៈ

- ឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល គេឃើញមានការសិក្សាស្រាវជ្រាវស៊ីជម្រៅជាច្រើនអំពីការកែលំអនិងការពង្រីកប្រព័ន្ធស្រោចស្រព អភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអត្ថប្រយោជន៍សេដ្ឋកិច្ចនៃប្រព័ន្ធស្រោចស្រព ។ ប៉ុន្តែបច្ចុប្បន្ននៅមានកង្វះការយល់ដឹង និងការកសាងផែនការរយៈពេលវែង ទាក់ទងនឹងការគ្រប់គ្រងទឹកក្រោមដី ។ ផ្ទៃដីផលិតកម្មស្រូវមួយចំនួន បានចាប់ផ្តើមប្រើប្រាស់ស្រទាប់ទឹករាក់ក្រោមដី ដើម្បីស្រោចស្រពស្រូវរដូវប្រាំង និងវស្សា និងកាត់បន្ថយភាពរាំងស្ងួត ។ គេអាចប្រើប្រាស់ទឹកក្រោមដីធ្វើជាយុទ្ធសាស្ត្ររយៈពេលវែង សម្រាប់កាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលធាតុអាកាសនៅពេលអនាគតមកលើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង ។ ប៉ុន្តែការប្រើប្រាស់ទឹកក្រោមដីក្នុងរយៈពេលវែងអាចមានផលប៉ះពាល់អវិជ្ជមានមកលើដី និងផលិតភាពកសិកម្ម ពិសេសស្រទាប់ទឹករាក់ក្រោមដី ។ ចំណេះដឹងអំពីបញ្ហានេះសព្វថ្ងៃគេពុំទាន់មាននៅឡើយទេ ។

- ដូចបានបញ្ជាក់ខាងលើ ការសិក្សាអំពីគោលនយោបាយជាច្រើន បានពិនិត្យបញ្ហាការនេសាទទឹកសាបជាកិច្ចឆ្លើយតបនឹង គោលនយោបាយរបស់រាជរដ្ឋាភិបាលលើកំណែទម្រង់វិស័យជលផល ប៉ុន្តែពុំទាន់មានការសិក្សាពេញលេញអំពីនេសាទទឹកប្រៃទេ ។ សព្វថ្ងៃទឹកទន្លេមេគង្គមានកម្រិតទាបជាងមុនប្រហែល ៥ម៉ែត្រ ហើយទឹកទន្លេសាបមានកម្ពស់ ៣ម៉ែត្រ ទាបជាងកម្ពស់ទឹកកាលពីឆ្នាំមុន ដោយសារការសាងសង់ទំនប់នៅខ្សែទឹកខាងលើ ។ កម្ពស់ទឹកទាបនឹងមានផលប៉ះពាល់អវិជ្ជមានមកលើអេកូឡូស៊ីនេសាទទឹកសាប និងជម្រកត្រីនៅកម្ពុជា ប៉ុន្តែគេពុំទាន់ដឹងច្បាស់ទេពី ផលប៉ះពាល់នៃកម្ពស់ទឹកទាបមកលើចំនួនត្រីទឹកសាប ការបន្តពូជ និងសន្តិសុខស្បៀងនៅកម្ពុជា ។

- ផែនទីសន្តិសុខស្បៀង គេបានកសាងឡើងកាលពី ៤ឆ្នាំមុន ដូច្នេះស្ថានភាពអាចមានការផ្លាស់ប្តូរចាប់ពីពេលនោះមក ធ្វើឱ្យលំបាកដល់ការអនុវត្តគោលនយោបាយ ដើម្បីផ្តោតចំទៅលើក្រុមជនងាយរងគ្រោះតាមវិធីសមស្រប ។ ផែនទីសន្តិសុខស្បៀងនេះគួរធ្វើបច្ចុប្បន្នភាពឡើង ដើម្បីឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នូវគោលនយោបាយស្តីពីសន្តិសុខស្បៀង និងការការពារសង្គម ។

- មានការយល់ដឹងយ៉ាងច្រើនអំពីទំនាក់ទំនងរវាងកំណើន និងភាពក្រីក្រ និងសន្តិសុខស្បៀង ។ ទោះយ៉ាងនេះក្តីចំនួនគ្រួសារគ្មានដីធ្លីកំពុងកើនឡើងគួរឱ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារមានជនចំណូលថ្មី និងការអភិវឌ្ឍទីផ្សារដីធ្លី ។ គេនៅពុំទាន់បានដឹងនៅឡើយអំពីបញ្ហាប្រឈម និងអន្តរកម្មរវាង ភាពគ្មានដីធ្លីនិងអសន្តិសុខស្បៀង ជាមួយនឹង ការការពារសង្គមនិងភាពងាយរងគ្រោះរបស់ពួកគេ ។

- គោលនយោបាយរបស់រាជរដ្ឋាភិបាល មានគោលដៅកសាងសមត្ថភាពផ្នែកដីធ្លី និងចំណាត់ថ្នាក់ភាពសមស្របនៃដីធ្លី តាមរយៈ ការរួមចំណែកដល់ការកសាងផែនការប្រើប្រាស់ដី និងការបែងចែកតំបន់ដំណាំកសិកម្ម(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៥) ។ ក្រៅពីផែនទីប្រើប្រាស់ដីធ្លីដែលបានផលិតនៅឆ្នាំ២០០២ គេពុំឃើញមានផែនទីប្រើប្រាស់ដីធ្លីបានធ្វើបច្ចុប្បន្នភាពជាផ្លូវការ ដែលគេអាចរកបាននោះទេ ។ ចំណុចនេះបង្ហាញពី គម្លាតរវាងគោលនយោបាយ និងការអនុវត្ត ។ ការបែងចែកតំបន់កសិកម្ម និងការកសាងផែនការប្រើប្រាស់ដីធ្លី សំខាន់ខ្លាំងណាស់សម្រាប់ការលើកកម្ពស់វិស័យកសិកម្ម ការកសាងផែនការវិនិយោគ និងសក្តានុពលនៃការពង្រីកផ្ទៃដីដាំដុះ ដោយសារប្រទេសកម្ពុជាសម្បូរដីកសិកម្ម ។ ឧទាហរណ៍ គេប៉ាន់ស្មានថា ផ្ទៃដីធ្វើស្រែអាចពង្រីកបានរហូតដល់ ៣.៥លានហ.ត (USDA ឆ្នាំ២០១០) ។

- សេដ្ឋកិច្ចកម្ពុជា បាននិងកំពុងប្រែក្លាយពីមូលដ្ឋានកសិកម្ម ទៅកាន់មូលដ្ឋានឧស្សាហកម្ម ដែលនាំឲ្យមានកំណើនចំណាកស្រុកពីជនបទមកទីក្រុង កង្វះកម្លាំងពលកម្មក្នុងវិស័យកសិកម្ម និងកំណើនប្រាក់ឈ្នួល ។

ចំណុចនេះទំនងមានផលប៉ះពាល់អវិជ្ជមានដល់កំណើនការអភិវឌ្ឍវិស័យកសិកម្ម ប្រសិនបើផលិតកម្មកសិកម្មបន្តប្រើប្រាស់អតិពលកម្ម ។ ក្នុងបរិបទនេះ របៀបរបបផលិតកម្មកសិកម្ម ហាក់ដូចកំពុងផ្លាស់ប្តូរពីការប្រើកម្លាំងមនុស្ស ទៅជាការប្រើគ្រឿងយន្តកសិកម្មវិញ ប៉ុន្តែការផ្លាស់ប្តូរបច្ចេកវិទ្យាកសិកម្មក្នុងអំឡុងពេលអន្តរកាលសេដ្ឋកិច្ចនេះ ពុំទាន់មានការសិក្សានៅឡើយទេ ។ ម្យ៉ាងទៀត គប្បីធ្វើការប៉ាន់ប្រមាណអំពីចំណងទាក់ទងរវាងជនបទនិងទីក្រុង សន្តិសុខស្បៀងនៅទីក្រុង និងភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋផងដែរ ។

- គោលនយោបាយទាក់ទងនឹងការលើកកម្ពស់កសិកម្ម បានពិចារណាលើទិដ្ឋភាពជាច្រើននៃការអភិវឌ្ឍន៍កសិកម្ម ដូចជា ការសង់សងផ្លូវថ្នល់ជនបទ និងការរកទីផ្សារ ។ ទោះជាយ៉ាងណាក្តី ចំណេះដឹងអំពីវិធីនាំផលិតករខ្នាតតូចមកកាន់ទីផ្សារ មិនទាន់ផ្សព្វផ្សាយបានល្អទេ ។ បន្ថែមលើនេះ អនុក្រឹត្យស្តីពីការធ្វើកសិកម្មតាមរយៈកិច្ចសន្យាកំពុងតែតាក់តែង ហើយរំពឹងថា នឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗ ប៉ុន្តែរបៀបធ្វើកសិកម្មផ្អែកលើកិច្ចសន្យានេះផ្តល់អត្ថប្រយោជន៍យ៉ាងដូចម្តេចដល់ផលិតករខ្នាតតូច ហើយវាមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានយ៉ាងណា នៅពុំទាន់មានការសិក្សាទូលំទូលាយនៅឡើយទេ ។
- យុទ្ធសាស្ត្រកំណត់នៅក្នុងឯកសារ SAW គឺត្រូវកសាងមូលដ្ឋានស្ថាប័ន រដ្ឋបាល ការស្រាវជ្រាវ និងការអប់រំ ដើម្បីគាំទ្រ និងកែលំអប្រសិទ្ធភាពរបស់អ្នកធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ និងការគ្រប់គ្រងកសិកម្មនិងធនធានទឹក។ ប៉ុន្តែសព្វថ្ងៃមានវគ្គសិក្សាតិចតួចណាស់នៅតាមគ្រឹះស្ថានអប់រំឧត្តមសិក្សា ដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ឬ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ហើយវគ្គសិក្សាទាំងនោះ មិនទាក់ទងពេញលេញជាមួយផលិតកម្មកសិកម្ម ឬការចិញ្ចឹមជីវិតនៅជនបទទេ (ឯកសាររបស់លោក ង៉ោ គ្មានកាលបរិច្ឆេទ) ។ រឿងនេះឆ្លុះបញ្ចាំងគម្លាតរវាងការអភិវឌ្ឍធនធានមនុស្ស និងជំនាញចាំបាច់សម្រាប់អនុវត្តគោលនយោបាយ។
- គោលនយោបាយរបស់រាជរដ្ឋាភិបាល សង្កត់ធ្ងន់លើការកសាង និងពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំក្នុងតួនាទីជាអាជ្ញាធរអភិវឌ្ឍន៍ដើម្បីផ្ទេរបច្ចេកវិទ្យា (តួនាទីជាអ្នកផ្សព្វផ្សាយកសិកម្ម) និងចែករំលែកព័ត៌មានដល់កសិករ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៥ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០០៧) ។ គោលនយោបាយយុទ្ធសាស្ត្រនេះ ឆ្លើយតបច្បាស់លាស់ចំពោះកង្វះបុគ្គលិកផ្សព្វផ្សាយកសិកម្ម ដើម្បីលើកកម្ពស់ការងារផលិតកម្មរបស់កសិករ ។ ទោះយ៉ាងណា ចំណុចខ្លាំង និងចំណុចខ្សោយនៃគោលនយោបាយស្តីពីការផ្ទេរបច្ចេកវិទ្យាទៅដល់កសិករនេះ (ដូចជា បច្ចេកវិទ្យាកសិកម្មជាដើម) គេមិនទាន់ដឹងច្បាស់នៅឡើយទេ ។ គេក៏ពុំមានព័ត៌មានច្បាស់លាស់ដែរថា តើការកសាងសមត្ថភាព ឬការបណ្តុះបណ្តាលជាក់លាក់អ្វីដែលក្រុមប្រឹក្សាឃុំត្រូវការ ដើម្បីឱ្យពួកគេក្លាយទៅជាអ្នកសម្របសម្រួលបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាពនៅក្នុងសហគមន៍របស់ខ្លួន ។
- នៅក្នុងវិស័យបសុសត្វ គេឃើញមានការខ្វះចន្លោះយ៉ាងធំនៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងការស្រាវជ្រាវអំពីគោលនយោបាយ ។ ការស្រាវជ្រាវអំពីទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ចនៃវិស័យបសុសត្វ សំខាន់ជាខ្លាំង ប្រសិនបើគេចង់កែលំអផលិតភាព និងការងារផលិតកម្ម ព្រមទាំងការរកទីផ្សារសម្រាប់សហគ្រាសធុនតូច និងមធ្យម ។ ការសិក្សាអំពីផលសេដ្ឋកិច្ចនៃផលិតកម្មបសុសត្វខ្នាតតូច និងមធ្យម ក៏ត្រូវសិក្សាជាបន្ទាន់ដែរ។

## ៦. សំណួរសម្រាប់សន្តិសុខស្បៀងនាពេលអនាគត

កន្លងមកគេបានកំណត់ប្រធានបទសំខាន់ៗមួយចំនួន ដើម្បីតម្រែតម្រង់ការងារស្រាវជ្រាវនាពេលអនាគត ទោះបីក្របខ័ណ្ឌនេះអាចមិនបានក្តោបអស់ពីកង្វះខាតចំណេះដឹងក្តី គឺមាន ការគ្រប់គ្រងធនធានទឹក ការលើកកម្ពស់កសិកម្ម និងសន្តិសុខស្បៀង ជលផល និងបសុសត្វ ។ សំណួរស្រាវជ្រាវដែលត្រូវសិក្សា ដើម្បីលើកកម្ពស់វិស័យកសិកម្ម និងសន្តិសុខស្បៀង ព្រមទាំងកាត់បន្ថយភាពក្រីក្រ មានដូចខាងក្រោម ។

*ការគ្រប់គ្រងធនធានទឹក*

១. តើការគ្រប់គ្រងទឹកក្រោមដីមានសក្តានុពលប៉ុណ្ណាសម្រាប់ការអភិវឌ្ឍកសិកម្ម?

- តើទឹកក្រោមដីមានសក្តានុពលប៉ុណ្ណាសម្រាប់ការស្រោចស្រព និងក្នុងលក្ខណៈជាកត្តាជួយរក្សាតុល្យភាពទឹកនៅកម្ពុជា និងជាស្តុកទឹកបំរុងធម្មជាតិដ៏សំខាន់ដែលអាចផ្តល់ទឹកបានពេញៗមួយឆ្នាំ?
- តើអ្វីខ្លះជាចំណុចខ្លាំង និងចំណុចខ្សោយនៃទឹកក្រោមដីសម្រាប់អភិវឌ្ឍន៍សិកម្ម និងបរិស្ថាន?
- តើទឹកក្រោមដីផ្តល់តុល្យភាពសេដ្ឋកិច្ចអ្វីរវាង ផលប្រយោជន៍ និងផលប៉ះពាល់លើលក្ខណៈដី និងដីជាតិដីក្នុងរយៈពេលវែង?

២. តើធ្វើយ៉ាងណាអាចកែលំអប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកលើដី នៅក្នុងប្រព័ន្ធស្រោចស្រពដែលមានស្រាប់?

៣. តើធ្វើយ៉ាងណាអាចពង្រឹងការចូលរួមរបស់អ្នកប្រើប្រាស់ទឹកលើផ្ទៃដី ក្នុងការធ្វើជាម្ចាស់ និងការថែទាំប្រព័ន្ធស្រោចស្រពប្រកបដោយប្រសិទ្ធភាព? តើការវិនិយោគលើការថែទាំប្រព័ន្ធស្រោចស្រពផ្តល់ជាផលចំណូលសេដ្ឋកិច្ចអ្វីខ្លះ?

៤. តើមានទំនាស់ប្រភេទអ្វីខ្លះនៅជុំវិញភាពខ្សត់ទឹក និងការបែងចែកធនធានទឹក ហើយតើបញ្ហាទាំងនេះអាចដោះស្រាយយ៉ាងដូចម្តេចឲ្យបានសក្តិសិទ្ធិ? តើមានវិធីសក្តិសិទ្ធិអ្វីខ្លះដើម្បីកែលំអវិនិយោគសាធារណៈក្នុងការស្តារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព?

*ការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀង*

១. តើការបែងចែកធនធានសម្រាប់ការអភិវឌ្ឍ និងកំណើនកសិកម្ម អាចបង្កើនយ៉ាងណាបាន? តើការស្រាវជ្រាវកសិកម្មដើម្បីជម្រុញកំណើនកសិកម្ម អាចពង្រីកយ៉ាងណាបាន? តើធ្វើដូចម្តេចឱ្យចំណងទាក់ទងរវាងទីភ្នាក់ងារស្រាវជ្រាវ និងអ្នកប្រើប្រាស់បច្ចេកវិទ្យា កាន់តែមានប្រសិទ្ធភាព? តើវិធីណាប្រសើរបំផុតដើម្បីជម្រុញកសិករឲ្យទទួលយករបៀបធ្វើអន្តរាគមន៍បែបថ្មីលើផ្នែកផលិតកម្ម ដើម្បីបង្កើនផលិតភាព និងសន្តិសុខស្បៀង?

២. តើត្រូវប្រើបច្ចេកវិទ្យាសមស្រប និងធាតុចូលអ្វីខ្លះ ដើម្បីបង្កើនផលិតភាពរបស់កសិករខ្នាតតូចក្នុងការផលិតស្បៀងអាហារឲ្យបានគ្រប់គ្រាន់? តើមានឱកាសការងារផ្សេងអ្វីខ្លះដើម្បីបង្កើនប្រភពចំណូលនៅជនបទក្រៅពីចំណូលកសិកម្ម សំដៅលើកកម្ពស់ការចិញ្ចឹមជីវិត? តើកសិកម្មផ្អែកលើដំណាំស្រូវអាចធ្វើពិពិធកម្មយ៉ាងណាដើម្បីលើកកម្ពស់ការចិញ្ចឹមជីវិតនៅជនបទ និងការកាត់បន្ថយភាពក្រីក្រ?

៣. តើធ្វើដូចម្តេចអាចលើកកំពស់ប្រសិទ្ធភាពក្រុមប្រឹក្សាឃុំ ក្នុងតួនាទីជា មធ្យោបាយផ្ទេរបច្ចេកវិទ្យានៅក្នុងសហគមន៍របស់ពួកគេ? តើមានកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពអ្វីខ្លះសម្រាប់ក្រុមប្រឹក្សាឃុំ ក្នុងមុខងារជួយផ្ទេរបច្ចេកវិទ្យា និងតើការបណ្តុះបណ្តាលនោះមានប្រសិទ្ធភាពដូចម្តេច? តើធ្វើណាលើកកំពស់ការចូលរួមរបស់វិស័យឯកជនក្នុងការផ្ទេរបច្ចេកវិទ្យាដល់អ្នកផលិត? តើធ្វើដូចម្តេចអាចលើកកំពស់ការកសាងស្ថាប័ន និងការកសាងសមត្ថភាពរបស់ទីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដើម្បីជួយបង្កើនផលិតភាពកសិករឲ្យកាន់តែមានប្រសិទ្ធភាព? តើគេអាចបែងចែកធនធានបន្ថែមយ៉ាងណាដល់ទីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម?

៤. តើការកសាងផែនការប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ដំណាំកសិកម្ម អាចលើកកម្ពស់យ៉ាងណាបានដើម្បីជម្រុញកំណើនកសិកម្ម? តើផ្ទៃដីដាំដុះស្រូវអាចពង្រីកយ៉ាងដូចម្តេច ដើម្បីបង្កើនដំណាំកសិកម្ម និងជម្រុញការនាំចេញ? តើធ្វើយ៉ាងណាអាចពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រែក្លាយការប្រើប្រាស់ដីទំនេរ ឲ្យទៅជាការប្រើប្រាស់មានផលិតភាព?

៥. តើអាចធ្វើយ៉ាងណាអាចបង្កើនសម្បទានដីសង្គមកិច្ច សម្រាប់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួច? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះ ចំពោះសន្តិសុខស្បៀងរបស់គ្រួសារគ្មានដីធ្លី? តើគោលនយោបាយអ្វីខ្លះដែលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យ និងអសន្តិសុខស្បៀង សម្រាប់គ្រួសារគ្មានដីធ្លី? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះសម្រាប់គ្រួសារនៅតាមខេត្ត ដែលប្រឈមមុខនឹងអសន្តិសុខស្បៀងធ្ងន់ធ្ងរ?

៦. តើមានការផ្លាស់ប្តូរបច្ចេកវិទ្យាអ្វីនៅក្នុងសេដ្ឋកិច្ចអន្តរកាល? តើវិស័យកសិកម្មមានតួនាទីអ្វីនៅក្នុងកំណើនសេដ្ឋកិច្ច ឱកាសការងារ សន្តិសុខស្បៀងនៅជនបទនិងទីក្រុង និងការកាត់បន្ថយភាពក្រីក្រ?

៧. តើហានិភ័យចំពោះផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងអាចកាត់បន្ថយយ៉ាងណាបាន នៅក្រោមការគំរាមកំហែងនៃការប្រែប្រួលធាតុអាកាស? តើគប្បីរៀបចំយ៉ាងដូចម្តេច និងគួរប្រើប្រាស់យ៉ាងណានូវទឹកក្រោមដីដើម្បីកាត់បន្ថយការគំរាមកំហែងចំពោះដីកសិកម្ម?

*ការអភិវឌ្ឍអនុវិស័យជលផល*

១. តើកម្រិតកម្ពស់ទឹកទន្លេទាប មានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះមកលើ អេកូឡូស៊ីជលផល ជម្រកត្រី និងផលិតភាពនៅក្នុងអនុវិស័យនេសាទទឹកសាបនៅកម្ពុជា? តើធ្វើដូចម្តេចអាចគ្រប់គ្រងការប្រែប្រួលទាំងនេះបាន ដើម្បីឱ្យអេកូឡូស៊ីត្រី ជម្រកត្រី និងផលិតភាពត្រីមាននិរន្តរភាព?

២. តើការអភិវឌ្ឍ និងការកសាងសមត្ថភាពសហគមន៍នេសាទ អាចជម្រុញ និងពង្រឹងយ៉ាងណាបាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងធនធានជលផលធម្មជាតិប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ការបង្កើតប្រាក់ចំណូល សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ?

៣. តើធ្វើដូចម្តេចឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមហាផ្ទៃ) មានការសម្របសម្រួលកាន់តែប្រសើរ ដើម្បីធ្វើឱ្យការគ្រប់គ្រងវិស័យជលផលកាន់តែមានប្រសិទ្ធភាព?

៤. ធ្វើដូចម្តេចអាចលើកកម្ពស់ផលិតកម្មវារីវប្បកម្ម ដើម្បីកាត់បន្ថយការគំរាមកំហែងលើការនេសាទទឹកសាប ធម្មជាតិ? តើធ្វើដូចម្តេចអាចលើកកម្ពស់វារីវប្បកម្មនៅតំបន់ជនបទឆ្ងាយពីកន្លែងនេសាទទឹកសាប ដើម្បីបង្កើនការបរិភោគប្រូតេអ៊ីនសាច់សត្វ និងប្រាក់ចំណូល?

*ការអភិវឌ្ឍអនុវិស័យបសុសត្វ*

១. តើធ្វើដូចម្តេចអាចបង្កើនផលិតកម្មជ្រូក ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារក្នុងស្រុក? តើការងារផលិតកម្មមានអ្វីខ្លះ? តើមានហានិភ័យ និងឧបសគ្គអ្វីខ្លះ ដែលកសិករចិញ្ចឹមជ្រូកត្រូវប្រឈមមុខ? តើបទបញ្ញត្តិ និងគោលនយោបាយអ្វីខ្លះដែលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការនាំចូលជ្រូក និងជម្រុញការចិញ្ចឹមជ្រូកក្នុងស្រុក?

២. តើវិស័យបសុសត្វអាចលើកកម្ពស់យ៉ាងណាបាន ដើម្បីបង្កើនចំណូលជនបទ និងសន្តិសុខស្បៀង? តើមានទំនាក់ទំនងសំខាន់ៗអ្វីខ្លះ រវាង ផលិតកម្មបសុសត្វនិងផលិតកម្មកសិកម្ម ជាមួយនឹង ចំណូលគ្រួសារជនបទ និងសន្តិសុខស្បៀង? តើការចិញ្ចឹមបសុសត្វខ្នាតតូច ផ្តល់ចំណូលសេដ្ឋកិច្ចអ្វីខ្លះ? តើមានហានិភ័យ និងឧបសគ្គចំបងៗអ្វីខ្លះដែលសហគមន៍ជនបទប្រឈមមុខក្នុងការចិញ្ចឹមបសុសត្វ? តើហានិភ័យនិងឧបសគ្គទាំងនោះអាចកាត់បន្ថយយ៉ាងដូចម្តេចបាន?

៣. តើទីផ្សារបសុសត្វអាចអភិវឌ្ឍយ៉ាងដូចម្ដេច សម្រាប់ជួយដល់អ្នកចិញ្ចឹមខ្នាតតូច? តើពាណិជ្ជកម្មផ្លូវការ (ឧ. គោក្របី) អាចលើកកម្ពស់យ៉ាងដូចម្ដេច ដើម្បីពង្រីកទីផ្សារបសុសត្វនៅកម្ពុជា? តើត្រូវមានបទបញ្ញត្តិអ្វីខ្លះ ដើម្បីកែលំអទីផ្សារបសុសត្វ?

## ៧. សេចក្ដីសន្និដ្ឋាន

ឯកសារនេះបានបង្ហាញពីគោលនយោបាយរាជរដ្ឋាភិបាលបច្ចុប្បន្ន ក្នុងការជម្រុញការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។ ឯកសារបានពិនិត្យត្រួសៗនូវការស្រាវជ្រាវផ្អែកគោលនយោបាយមួយចំនួន ដែលផ្ដោតលើការអភិវឌ្ឍកសិកម្ម ការចិញ្ចឹមជីវិតនៅជនបទ និងសន្តិសុខស្បៀង ដើម្បីឆ្លើយតបនឹងគោលនយោបាយរាជរដ្ឋាភិបាល ។ ឯកសារនេះសំដៅផ្ដួចផ្ដើមបំផុសការពិភាក្សា ពុំមែនផ្ដល់ការវិភាគស៊ីជម្រៅនោះទេ ប៉ុន្តែក៏បានជួយឱ្យយើងរកឃើញនូវ កង្វះខាតមួយចំនួនក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងចំណេះដឹងសម្រាប់លើកកម្ពស់វិស័យកសិកម្ម ។ ឯកសារក៏បានលើកបង្ហាញនូវ ការស្រាវជ្រាវសំខាន់ៗដែលអាចតម្រែតម្រង់កម្មវិធីស្រាវជ្រាវសហការគ្នាជាមូលដ្ឋាន សម្រាប់ការស្រាវជ្រាវនាពេលអនាគត ។